ក្រសួងអប់រំ យុវជន និងកីឡា

សម្រាប់លក់

# ភាសាខ្មែរ



៤

គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ
www.elibraryofcambodia.org

ក្រសួងអប់រំ យុវជន និងកីឡា

# ភាសាខ្មែរ

## ថ្នាក់ទី ៤

បោះពុម្ពផ្សាយដោយ

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

អគារ ១៥៨ មហាវិថី ព្រះនរោត្តម ភ្នំពេញ

គណៈកម្មការនិពន្ធ លោកស្រី ឈិន ស៊ីវឡេង លោក យ៉ង់ កំស៊ាន
លោកស្រី ស៊ុន សូម៉ាណា លោកស្រី ជា ចាន់នារី

អ្នកខាយអត្ថបទ លោក អ៊ុំ បុប្ផា

វិចិត្រករ លោក ហ៊ុយ វណ្ណថេន លោក សេង វិសាល

អ្នករៀបរៀង លោកជំទាវ ទន់ សាអ៊ឹម

អ្នករចនាទំព័រ លោក ខែម ម៉ារី

គណៈកម្មការពិនិត្យ លោក យិន ធី លោកស្រី នូ សុវ៉ារី

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពី ក្រសួងអប់រំ យុវជន និងកីឡា តាមប្រកាសលេខ ២២១៤ អយក.ប្រក. ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០១០ ដើម្បីប្រើប្រាស់នៅតាមសាលារៀន ។

ហាមថតចម្លងសៀវភៅនេះ

រក្សាសិទ្ធិ ©
គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

បោះពុម្ពឆ្នាំ ២០១៦

ISBN 9-789-995-001-179

www.elibraryofcambodia.org

# អារម្ភកថា

ប្អូនៗកុមារា កុមារី ជាទីស្នេហា !

សៀវភៅភាសាខ្មែរថ្នាក់ទី៤ នេះ ត្រូវបាននិពន្ធស្របតាមកម្មវិធីសិក្សាថ្មី ។ សៀវភៅនេះនឹងជួយប្អូនៗក្នុងការអភិវឌ្ឍចំណេះដឹងគ្រឹះផ្នែកភាសាខ្មែរដូចជា បំណិននិយាយ ស្ដាប់ អាន សរសេរ និងវេយ្យាករណ៍ ។ សៀវភៅនេះ ក៏បានបង្ហាញផងដែរអំពីភាពរីករាយក្នុងការសិក្សា ភាពរីករាយក្នុងគ្រួសារ ប្រពៃណី ទំនៀមទម្លាប់ សណ្ឋានដី និងការរស់នៅរបស់ប្រជាជនខ្មែរយើង ។

តាមរយៈសៀវភៅនេះ ប្អូនៗនឹងរីករាយជាមួយអំណាន រឿងនិទាន ការសន្ទនា កំណាព្យ ចម្រៀង សំណេរពាក្យ ការបំពេញល្បះ ព្រមទាំងការចម្លងល្បះងាយៗ ។ ប្អូនៗអាចហាត់និយាយតាមអត្ថបទគំរូ ហាត់អាន ធ្វើលំហាត់ និងហាត់សរសេរដោយខ្លួនឯង ។

គណៈកម្មការនិពន្ធសង្ឃឹមថា សៀវភៅភាសាខ្មែរថ្នាក់ទី៤ថ្មីនេះ អាចផ្ដល់ចំណេះដឹងល្អៗ ដើម្បីពង្រឹងសមត្ថភាពផ្នែកភាសាខ្មែរ និងជួយឱ្យសតិបញ្ញាស្មារតីចម្រើនលូតលាស់ឆាប់រហ័សស្របតាមការអភិវឌ្ឍរបស់សង្គមជាតិ ។

សូមឱ្យប្អូនៗទទួលបានជោគជ័យក្នុងការសិក្សា ។

គណៈកម្មការនិពន្ធ

www.elibraryofcambodia.org

# បញ្ជីអត្ថបទ

ទំព័រ


មេរៀនទី ១ : កីឡានិងល្បែងកម្សាន្ត........................................ ១
មេរៀនទី ២ : សហគមន៍ជឿនលឿន........................................ ១៧
មេរៀនទី ៣ : ការគួរសម........................................ ៣៣
មេរៀនទី ៤ : រុក្ខជាតិប្រទេសយើង........................................ ៤៩
មេរៀនទី ៥ : មិត្តជិតស្និទ្ធ........................................ ៦៣
មេរៀនទី ៦ : មធ្យោបាយធ្វើទំនាក់ទំនង........................................ ៧៧
មេរៀនទី ៧ : ម្ហូបអាហារខ្មែរ........................................ ៩១
មេរៀនទី ៨ : សណ្ឋានដីប្រទេសយើង........................................ ១០៧
មេរៀនទី ៩ : ប្រភពទឹកនៅកម្ពុជា........................................ ១២១
មេរៀនទី ១០: សត្វនៅប្រទេសយើង........................................ ១៣៥
បទានុក្រម :........................................ ១៥១


www.elibraryofcambodia.org

មេរៀនទី ១

# កីឡានិងល្បែងកម្សាន្ត



ប្រជាជនខ្មែរភាគច្រើន និយមលេងល្បែងកម្សាន្ត ។ អ្នកខ្លះ ចូលចិត្តលេងល្បែង តាមរដូវកាល ឯខ្លះទៀតចូលចិត្តលេងល្បែងបែបណាមួយជាប្រចាំ ។ កីឡានិងល្បែង កម្សាន្ត នាំមកនូវភាពសប្បាយរីករាយ ការលូតលាស់ផ្នែកប្រាជ្ញា សុខភាព និង សាមគ្គីភាព ។



www.elibraryofcambodia.org

## ព្រឹត្តិការណ៍នៃរឿង

ក្នុងរឿងមួយ តែងមានហេតុការណ៍ផ្សេងៗកើតឡើង ។ សកម្មភាពឬអ្វីដែលតួអង្គធ្វើ និងជួបប្រទះ ឬអ្វីៗ ដែលកើតឡើងចំពោះតួអង្គគឺជា " ព្រឹត្តិការណ៍នៃរឿង" ។ ចូរអានរឿងខាងក្រោម ។ តើរឿងនេះ មានព្រឹត្តិការណ៍អ្វីខ្លះ ?

### *រឿង វៃនិងស្រមោច*

រដូវប្រាំង វៃហើរច្រៀងលេងគ្មានគិតខ្វល់ខ្វាយរកស្រូវអង្ករទុកឡើយ ។ ឯស្រមោចជាសត្វឧស្សាហ៍ ខំនាំគ្នារកស្បៀងទុក ។ រដូវភ្លៀងធ្លាក់មកដល់ វៃអត់អាហារក៏ហើរទៅខ្ចីស្បៀងស្រមោច ។ ស្រមោចសួរវៃ ៖" អើវៃ! កាលពីរដូវប្រាំង តើអ្នករវល់ធ្វើអ្វីបានជាមិនខំរកស្បៀងទុក ?" ។ វៃឆ្លើយ ៖"ខ្ញុំរវល់ហើរស្រែកច្រៀងលេងយ៉ាងសប្បាយ" ។ ស្រមោចតប ៖"វៃអើយ! បើពីដើមអ្នកធ្លាប់ច្រៀងលេង ឥឡូវច្រៀងទៀតទៅ ព្រោះការច្រៀងនាំឱ្យអ្នកឆ្អែត" ។ វៃនៅតែទទូចអង្វរស្រមោច ៖"ឱមិត្តអើយ! ខ្ញុំអត់បាយស្ទើរដាច់ពោះស្លាប់ទៅហើយ អាណិតចែកស្បៀងឱ្យខ្ញុំខ្ចីបន្តិចមក" ។ ស្រមោចឆ្លើយ ៖" ស្បៀងយើងមានខ្លះដែរ តែទុកល្មមកូនចៅយើង ពុំមានស្បៀងច្រើនចែករំលែកឱ្យអ្នកទេ " ។ វៃអស់សង្ឃឹម ក៏ហើរទៅវិញទាំងទុក្ខសោក ។

**រឿងនេះ មានព្រឹត្តិការណ៍ពីរគឺ ៖**

១. នៅរដូវប្រាំងវៃហើរច្រៀងលេងឥតខ្វល់ខ្វាយ រីឯស្រមោចខំរកស្បៀងទុក ។

២. រដូវភ្លៀងធ្លាក់វៃអត់ស្បៀង ក៏ទៅខ្ចីស្បៀងពីស្រមោច តែស្រមោចមិនឱ្យ ។

ព្រឹត្តិការណ៍នៃរឿង គឺជាហេតុការណ៍ដែលកើតឡើងនៅក្នុងរឿងនិទានផ្សេងៗ ។



www.elibraryofcambodia.org

## លំហាត់

ចូរអានរឿងខាងក្រោម រួចប្រាប់ព្រឹត្តិការណ៍នៃរឿង ។

### រឿង កុមារណារិន

ណារិន រស់នៅតាមមាត់ទន្លេ ។ ឪពុកណារិន បានបង្ហាត់ណារិនឱ្យចេះហែលទឹកតាំងពីក្មេង ។ ណារិន ព្យាយាមហ្វឹកហាត់ហែលទឹកយ៉ាងស្ទាត់ជំនាញ ។ ថ្ងៃមួយ មានក្មេងមួយក្រុមកំពុងហ៊ោកញ្ច្រៀវលេងទឹកទន្លេខាងក្រោយផ្ទះណារិន ។ មួយសន្ទុះក្រោយមកស្រាប់តែឮសំឡេងក្មេងៗស្រែក៖ “ ជួយផង ! ជួយផង មានអ្នកលង់ទឹកហើយ ! ” ។ ឮភ្លាមណារិនឆក់បានក្រមាស្ទុះរឹងទៅមាត់ទន្លេ ឃើញក្មេងម្នាក់កំពុងលិចអណ្តែតៗ ។ ណារិនលោតចុះក្នុងទឹក ហែលទៅជិតកុមារនោះ រួចបោះក្រមាឱ្យតោង ។ ណារិនហែលអូសរហូតដល់ច្រាំង ទើបស្រង់អ្នកលង់ទឹកឡើងលើគោក ។ អ្នកនៅទីនោះ នាំគ្នាជួយសង្គ្រោះអ្នកលង់ទឹកផុតពីគ្រោះថ្នាក់ ។ អ្នកភូមិសរសើរណារិនគ្រប់ៗគ្នា ។



### រឿង យ៉ារីមើលថែប្អូន

ចូរអានរឿង រួចឆ្លើយនឹងសំណួរខាងក្រោម ។



ថ្ងៃមួយ ពេលម្តាយឪពុកទៅធ្វើការបាត់ យ៉ារីនៅចាំផ្ទះមើលថែប្អូនតូច ។ នាងនាំប្អូនលេងបត់ក្រដាសធ្វើជាផ្កា ។ នាងបានដាក់ក្រដាស កន្ត្រៃ កាំបិតរាយប៉ាយជុំវិញខ្លួន ។ ប្អូនប្រុសនាងរីករាយណាស់ ។ វាវារចុះឡើងតាមឆក់ដណ្តើមក្រដាស កាំបិត កន្ត្រៃ



www.elibraryofcambodia.org

ពីបង ។ នៅពេលយ៉ារីមិនបានប្រយ័ត្ន ប្អូននាងឆក់ចាប់ត្រូវមុខកាំបិតមុតដៃហូរឈាមបន្តិច ។ ប្អូននាងយំយ៉ាងខ្លាំង ។ យ៉ារីភ័យណាស់ ស្ទុះទៅយកអាល់កុល និងសំឡីមកលាងឈាមចេញ រួចយកបង់រុំរបួសឱ្យប្អូន ។

ពេលម្ដាយឪពុកត្រឡប់ពីធ្វើការវិញ យ៉ារីនិយាយរឿងនេះប្រាប់ពួកគាត់ ។ ម្ដាយឪពុកនាងមិនបន្ទោសនាងទេ តែគាត់ណែនាំយ៉ារីដោយពាក្យផ្អែមល្ហែម ៖ " កូនដឹងទេ! ការលេងដោយប្រើវត្ថុមានមុខមុត ចុងស្រួច វានាំឱ្យមានគ្រោះថ្នាក់ បើយើងមិនប្រុងប្រយ័ត្ន ។ នេះមុតត្រឹមកដៃ ចុះបើចុងកាំបិតត្រូវភ្នែក នោះគ្រោះថ្នាក់កាន់តែធំហើយ ។ ថ្ងៃក្រោយ ពេលកូននាំប្អូនលេង កូនគួរជ្រើសល្បែងណាមានសុវត្ថិភាព និងមានប្រយោជន៍ដូចជាការគូររូបផាត់ពណ៌ ល្បែងសិក្សាទាក់ទងនឹងភាសាខ្មែរ ឬគណិតវិទ្យាជាដើម" ។ យ៉ារីឆ្លើយ ៖ "ចាសម៉ាក់! ខ្ញុំនឹងធ្វើតាមដំបូន្មាននេះ" ។

## សំណួរ

១. តើយ៉ារីធ្វើអ្វីខ្លះនៅផ្ទះ ?

២. តើប្អូនយ៉ារីកើតរឿងអ្វី ? ហេតុអ្វី ?

៣. តើម្ដាយយ៉ារីទូន្មាននាងដូចម្ដេចខ្លះ ?

៤. ពេលអ្នកមើលថែប្អូន តើអ្នកត្រូវនាំប្អូនលេងអ្វីខ្លះ ទើបមានសុវត្ថិភាព ?

## លំហាត់

ចូរជ្រើសរើសចម្លើយណា ដែលជាព្រឹត្តិការណ៍នៃរឿង ។

១. យ៉ារីនាំប្អូនលេងបត់ក្រដាសធ្វើផ្កា ។

២. ប្អូនយ៉ារីមុតដៃនឹងកាំបិត ។

៣. យ៉ារីខឹងប្អូនយ៉ាងខ្លាំង ។

៤. យ៉ារីជម្រាបម្ដាយពីរឿងប្អូនមុតដៃ ។

៥. ម្ដាយឪពុកបន្ទោសយ៉ារី ។

៦. ម្ដាយយ៉ារីទូន្មានយ៉ារី ។



www.elibraryofcambodia.org

# ចរិតលក្ខណៈរបស់តួអង្គ

យើងអាចស្គាល់ចរិតលក្ខណៈរបស់តួអង្គ តាមរយៈសម្តី កាយវិការតួអង្គនោះ ឬតាមការពណ៌នារបស់អ្នកនិពន្ធ ឬតួអង្គផ្សេងៗទៀត ។

ចូរអានរឿងវៃ និងស្រមោចឡើងវិញ ។ តើតួអង្គក្នុងរឿងនេះ មានចរិតលក្ខណៈដូចម្តេចខ្លះ?

ស្រមោចជាសត្វឧស្សាហ៍ព្យាយាម ប៉ុន្តែកំណាញ់មិនចេះជួយអ្នកអត់ឃ្លាន រីឯវៃជាសត្វខ្ជិលច្រអូស គិតតែពីសប្បាយភ្លេចខ្លួន ។

ចរិតលក្ខណៈរបស់តួអង្គមានដូចជា ស្លូត កាច ឧស្សាហ៍ ខ្ជិល ល្អ អាក្រក់... ។

## លំហាត់

តើកុមារណារិន មានចរិតលក្ខណៈដូចម្តេច ? ចូរគូសសញ្ញា ✓ ក្នុងប្រអប់ចម្លើយសមស្របមួយ ។

☐ ១. កុមារណារិន ជាមនុស្សខ្ជិលច្រអូស ។

☐ ២. កុមារណារិន ជាមនុស្សព្រហើន ។

☐ ៣. កុមារណារិន ជាមនុស្សក្លាហានហើយចិត្តល្អ ។

## សំណេរ

ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។

១. កីឡាករមានរាងកាយ.............................. ។

២. កុមារចូលចិត្តនាំគ្នាលេង..................ក្រោមពន្លឺខែ ។

៣. សិស្សស្រីមួយក្រុមមើលការប្រកួតកីឡា.............. ។

៤. ពូសុនចូលចិត្ត............ប្រដាល់ក្បាច់គុនបុរាណខ្មែរ ។

៥. កុមារីនេះ ហាត់ប្រាណ.............................. ។

ចូរតែងល្បះនឹងពាក្យ ៖ បាល់ទះ ហែលទឹក លេងវែក ។

www.elibraryofcambodia.org

# ការប៉ាន់ស្មានហេតុការណ៍ដែលកើតឡើងបន្ទាប់

ចូរអានរឿងខាងក្រោម ។ តើនឹងមានហេតុការណ៍អ្វីកើតឡើងចំពោះមាន់គក?

ចូរអានឧទាហរណ៍រួចពិនិត្យចម្លើយមួយសមស្រប ។

សត្វកញ្ជ្រោងមួយបានដេញចាប់មាន់គក រហូតដល់ក្បែរផ្ទះអ្នកភូមិ ។ ពេលមាន់គកស្រែក អ្នកភូមិក៏នាំគ្នាចេញមក ហើយដេញវាយកញ្ជ្រោង ។ កញ្ជ្រោងក៏បកក្រោយបោលយ៉ាងលឿន ។ មាន់គកឃើញដូច្នេះគិតថា កញ្ជ្រោងខ្លាចខ្លួន ក៏រត់ដេញកញ្ជ្រោងរហូតដល់កំបាំងភ្នែកអ្នកស្រុក ។

ក. មាន់គកនិងកញ្ជ្រោង ព្រមព្រៀងរាប់គ្នាជាមិត្ត ។ ( មិនអាច )

ខ. មាន់គក ត្រូវកញ្ជ្រោងស៊ី ។ ( អាច )

គ. កញ្ជ្រោងរត់ពួនមាន់គក ។ ( មិនអាច )

**ចម្លើយ ខ** សមហេតុផលជាង **ចម្លើយ ក និង គ** ។ ភាពពិតកញ្ជ្រោងមិនខ្លាចមាន់ទេ ហើយម្យ៉ាងទៀត មាន់និងកញ្ជ្រោងពុំអាចព្រមព្រៀងរាប់អានគ្នាឡើយ ។

ប៉ាន់ស្មានហេតុការណ៍មានន័យថា ទាយ ឬប្រមើលមើលហេតុការណ៍សមស្របណាមួយដែលអាចនឹងកើតមានឡើង ដោយផ្អែកលើព័ត៌មានដែលគេបានផ្តល់ឱ្យ ។

## លំហាត់

ចូរអានរឿងខាងក្រោម រួចប៉ាន់ស្មានហេតុការណ៍ដែលកើតឡើងចំពោះហ៊ីង ដោយជ្រើសរើសចម្លើយសមស្របមួយ ។

### រឿង គោនិងហ៊ីង

មានសត្វគោមួយ បានចុះទៅផឹកទឹកត្រពាំង ។ កូនហ៊ីងឃើញក៏ស្រែកហាម ៖ “ឈប់សិន! ឯងមិនត្រូវមកផឹកទឹកនៅទីនេះទេ ព្រោះជាត្រពាំងរបស់ខ្ញុំ” ។ គោឆ្លើយតប ៖ “ យើ! អាច្រមក់ ឯងចេះដឹងអី ប្រយ័ត្នយើងជាន់ស្លាប់ណា៎!” ។ កូនហ៊ីងឮដូច្នេះ



www.elibraryofcambodia.org

ក៏រត់ប្រាប់មេវា ៖ “ម៉ែ! ម៉ែ! មានសត្វអ្វីធំណាស់! វាមកផឹកទឹកត្រពាំងយើង ហើយគំរាមជាន់កូនឱ្យស្លាប់ទៀតផង” ។ មេហ៊ឹងសួរកូន ៖“ តើវាធំប៉ុនណា ?” ។ មេហ៊ឹងខំបំប៉ោងខ្លួនឱ្យធំ រួចសួរកូន ៖“ តើវាធំប៉ុននេះមែនទេ ?” ។ កូនហ៊ឹងឆ្លើយ ៖“ ទេ! ទេ! វាធំជាងនេះឆ្ងាយណាស់” ។ មេហ៊ឹងខំបំប៉ោងខ្លួនឱ្យធំជាងមុនទៀត រួចសួរកូន ៖“ តើវាធំប៉ុននេះមែនទេ ?” ។ កូនហ៊ឹងឆ្លើយ ៖“ ទេ! វាធំជាងនេះទៅទៀត” ។ មេហ៊ឹងខំបំប៉ោងខ្លួនឱ្យធំថែមទៀត... ។

១. មេហ៊ឹងបំប៉ោងខ្លួនបានធំជាងគោ ។

២. មេហ៊ឹងបែកពោះស្លាប់ ។

៣. មេហ៊ឹងឈប់បំប៉ោងខ្លួនតទៅទៀត ។

## ៦ រឿង ទន្សាយនិងខ្យង

បន្ទាប់ពីស្តាប់រឿង ចូរឆ្លើយនឹងសំណួរ ។




www.elibraryofcambodia.org

## សំណួរ

១. តើទន្សាយជួបសត្វអ្វី ? នៅឯណា ? នៅពេលណា ?

២. ហេតុអ្វីបានជាមានការប្រកួតរវាងទន្សាយនិងខ្យង ?

៣. តើខ្យងប្រើល្បិចដូចម្ដេច ដើម្បីបានឈ្នះការប្រកួត ?

៤. តើរឿងនេះ ចង់អប់រំយើងដូចម្ដេចខ្លះ ?

## លំហាត់

ក. ចូរគូសសញ្ញា ✓ នៅមុខចម្លើយណាមួយ ដែលជាចរិតលក្ខណៈរបស់ទន្សាយ ។

☐ ១. ទន្សាយជាសត្វស្លូតបូត ។

☐ ២. ទន្សាយជាសត្វអួតក្អេងក្អាង ។

☐ ៣. ទន្សាយជាសត្វកាចសាហាវ ។

ខ. ចូរជ្រើសរើសចម្លើយណា ដែលជាព្រឹត្តិការណ៍នៃរឿង ។

☐ ១. ទន្សាយទៅផឹកទឹកត្រពាំង ហើយបានជួបនឹងខ្យង ។

☐ ២. ខ្យងបបួលទន្សាយរត់ប្រណាំងគ្នា ។

☐ ៣. ទន្សាយរត់ប្រណាំងជាមួយខ្យង ។

គ. តើទន្សាយបានឃើញអ្វី នៅពេលដែលវាទៅដល់ទី ? ចូរអ្នកទាយមើលថា តើទន្សាយធ្វើដូចម្ដេច បន្ទាប់ពីចាញ់ការប្រកួត ។

## នាមសាធារណ៍ ឬសាធារណនាម

នាមគឺជាសម្ដីសម្គាល់មនុស្ស សត្វ រុក្ខជាតិ ទីកន្លែង ឬវត្ថុអ្វីមួយ ។ នាមមានច្រើនប្រភេទ ។ ក្នុងមេរៀននេះ អ្នកនឹងបានសិក្សាអំពីនាមសាធារណ៍ ឬសាធារណនាម ។

ចូរអានដោយពិនិត្យពាក្យមានគំនូសពីក្រោមក្នុងល្បះនីមួយៗ ។

www.elibraryofcambodia.org

១. កុមារីចូលចិត្តលេងព្រែះ ឯកុមារាចូលចិត្តលេងបាល់ទាត់ ។

២. ការលេងកីឡា នាំឱ្យមានសុខភាពល្អ ។

៣. សាលារៀននីមួយៗ មានទីធ្លាសម្រាប់ហ្វឹកហាត់កីឡា ។

៤. ណាត្រីវាយសីជាមួយបងប្រុសនាង ក្រោមដើមឈើ ។

៥. ស្វាទាំងនេះ ចេះសម្ដែងសៀករហាស្សកម្ម ។

ពាក្យ "កុមារី កុមារា កីឡា សាលារៀន ដើមឈើ ស្វា "សម្គាល់មនុស្ស វត្ថុ ទីកន្លែង រុក្ខជាតិ និងសត្វទូទៅ ។ វាជានាមសាធារណ៍ ឬសាធារណនាម ។

នាមសាធារណ៍ គឺជានាមសម្គាល់ មនុស្ស សត្វ រុក្ខជាតិ ទីកន្លែង វត្ថុ ទូទៅ មិនចំពោះ ។

## លំហាត់

ក. ចូរស្រង់ពាក្យជានាមសាធារណ៍ នៅក្នុងល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។

១. សិស្សានុសិស្ស មកប្រកួតកីឡានៅខេត្តយើង ។

២. កុមារចូលចិត្តលេងល្បែងកម្សាន្តផ្សេងៗ នៅសាលារៀន ។

៣. ប្រជាជនយើងនិយមលេងល្បែងប្រជាប្រិយ នៅពេលបុណ្យចូលឆ្នាំខ្មែរ ។

៤. ខ្ញុំនិងមិត្តខ្ញុំ នាំគ្នាជិះទោង ។

ខ. ចូរបំពេញល្បះខាងក្រោម ដោយនាមសាធារណ៍ឱ្យបានត្រឹមត្រូវ ។

១. នៅសាលារៀនយើង មានការប្រកួត...................... ។

២. ...............ភូមិខ្ញុំចូលចិត្តប្រណាំងកង់យឺត នៅពេលចូលឆ្នាំ ។

៣. គេបង្ហាត់.......................ឱ្យចេះសម្ដែងសៀករហាស្សកម្ម ។

គ. ចូររកពាក្យជានាមសាធារណ៍ឱ្យបានដប់ពាក្យ នៅក្នុងអត្ថបទអំណាន " រឿងយ៉ារីមើលថែប្អូន" ។



www.elibraryofcambodia.org

# កីឡានិងល្បែងមានសុវត្ថិភាព

ចូរអានអត្ថបទ រួចឆ្លើយនឹងសំណួរខាងក្រោម ។



កុមារចូលចិត្តលេងល្បែងកម្សាន្តផ្សេងៗ ជារៀងរាល់ថ្ងៃ ។ ល្បែងកម្សាន្តខ្លះ នាំមកនូវភាពសប្បាយរីករាយ សាមគ្គីភាព ការលូតលាស់ផ្នែកប្រាជ្ញាជាដើម តែល្បែងកម្សាន្តខ្លះទៀត អាចនាំឱ្យអន្តរាយដល់ខ្លួន និងបង្កការលំបាកដល់ឪពុកម្ដាយទៀតផង ។

ល្បែងកម្សាន្តខ្លះ ដូចជាការលេងទឹក ការឡើងដើមឈើ ការលេងគ្រាប់មិនទាន់ផ្ទុះ និងគ្រឿងផ្ទុះអាចធ្វើឱ្យអ្នករបួស ពិការ ឬបាត់បង់ជីវិត ។ ចំណែកការលេងបាល់ទាត់តាមទីសាធារណៈ ពិសេសតាមចិញ្ចើមផ្លូវ អាចនាំឱ្យខ្លួនអ្នកមានគ្រោះថ្នាក់ និងអាចបង្កគ្រោះមហន្តរាយដល់អ្នកដទៃផងដែរ ។

ល្បែងកម្សាន្តខ្លះ ផ្ដល់អត្ថប្រយោជន៍ ច្រើនណាស់ ។ ការលេងកីឡាបាល់ទាត់ បាល់ទះ បាល់បោះ វាយសី លោតអន្ទាក់ ហាត់ប្រាណអាចធ្វើឱ្យអ្នកលេងមានសុខភាពល្អ ។ ប៉ុន្តែការលេងកីឡាគប្បីរកកន្លែងសមរម្យ ទើបមានសុវត្ថិភាព ។ រីឯការកម្សាន្តខ្លះទៀតដូចជាការលេងអុក លេងវែក និងខ្លាស៊ីគោធ្វើឱ្យសប្បាយរីករាយផង លូតលាស់ផ្នែកប្រាជ្ញាផង ព្រោះអ្នកលេងត្រូវខំគិតត្រិះរិះពិចារណារកវិធីលេង ដើម្បីយកជ័យជម្នះលើដៃគូ ។

សិស្សានុសិស្សគ្រប់រូប គប្បីខិតខំសិក្សា និងលេងកីឡាដើម្បីទទួលបាននូវចំណេះវិជ្ជា សុខភាពល្អ និងប្រាជ្ញាស្មារតីភ្លឺថ្លា ។



www.elibraryofcambodia.org

## សំណួរ

១. តើល្បែងកម្សាន្តណាខ្លះ ដែលអ្នកគួរចៀសវាង ? ហេតុអ្វី ?

២. តើល្បែងកម្សាន្តណាខ្លះ ដែលអ្នកគួរលេង ? ហេតុអ្វី ?

៣. តើកុមារត្រូវធ្វើអ្វីខ្លះ ដើម្បីឱ្យមានសុខភាពល្អ និងមានចំណេះវិជ្ជា ?

## លំហាត់

ក. ចូរស្រង់ឈ្មោះល្បែងកម្សាន្តមានសុវត្ថិភាព និងគ្មានសុវត្ថិភាពឱ្យបានមួយមុខ៣ ។

ខ. ចូរស្រង់នាមសាធារណ៍ ពីក្នុងអត្ថបទអំណានខាងលើឱ្យបានប្រាំពាក្យ ។

## សំណេរ

ក. ចូរតែងល្បះដោយប្រើពាក្យ និងរូបភាពខាងក្រោម ។

១. កុមារី ៖ ................... ។

២. គ្រូកីឡា ៖ ................. ។

៣. ឆ្ងាយ ៖ ................... ។



ខ. ចូរតែងល្បះនឹងពាក្យ ៖

"បាល់ទាត់ ចោលឈូង វាយសី" ឱ្យបានមួយល្បះក្នុងមួយពាក្យ ។

គ. ចូរតែងកថាខណ្ឌខ្លីតាមសំណួរ និងរូបភាពខាងក្រោម ។

១. តើកុមារានេះកំពុងធ្វើអ្វី ?

២. តើគេហាត់លេងនៅឯណា ?

៣. តើគេព្យាយាមហាត់ដូចម្ដេចខ្លះ ?

៤. តើថ្ងៃក្រោយគេនឹងក្លាយជាអ្វី ?



www.elibraryofcambodia.org

# រឿង ជ័យជម្នះរបស់តុលា

ចូរអានអត្ថបទ រួចឆ្លើយនឹងសំណួរខាងក្រោម ។



តុលាជាសិស្សថ្នាក់ទី៤ នៃសាលាបឋមសិក្សា ។ តុលាមានរាងធាត់កន្ទ្រល ក្បាលពោះសុទ្ធតែខ្លាញ់ ភ្នែកលិប ដំណើរអឹកអ៊ាកៗ ។

ថ្ងៃមួយ សាលាមានកម្មវិធីប្រកួតរត់ប្រណាំងចម្ងាយ១០០ម៉ែត្រ ។ សិស្សជាច្រើនរត់យ៉ាងលឿនដល់ទី តាមពេលវេលាកំណត់ ។ ចំណែកតុលាវិញ រត់អឹកអ៊ាកៗក្រោយគេ មិនទាន់ទាំងបាន ៥០ម៉ែត្រផងហាត់តឃូស ទៅមុខលែងរួច ដកដង្ហើមតាមមាត់ និយាយលែងរួច ដាក់គូទអង្គុយចុះ ។ តុលាខ្មាសគេណាស់ ។ អ្នកគ្រូឃើញដូច្នេះ ក៏ហៅតុលាមកណែនាំ ៖ " ប្អូនត្រូវហាត់ប្រាណ លេងកីឡា ហាត់រត់ឱ្យបានទៀងទាត់ " ។ តុលាធ្វើតាមដំបូន្មានអ្នកគ្រូ ជាប្រចាំ ។ មិនយូរប៉ុន្មាន តុលាស្រកក្បាលពោះ ហើយស្រាលខ្លួនជាងមុន ។ វាអាចរត់ លោត លេងកីឡាដោយមិននឿយហាត់ ។

ថ្ងៃរត់ប្រណាំងលើកទី២មកដល់ជាថ្មី ។ ម្តងនេះ តុលារត់យ៉ាងលឿន ស្ទុះដល់ទីមុនគេ ។ អ្នកឈរមើលធ្វើភ្នែកស្លី ដោយនឹកស្មានមិនដល់ ។ បន្តិចមក ទើបគេនាំគ្នាទះដៃប្រាវអបអរសាទរ ។ សិស្សទាំងអស់ សរសើរតុលាគ្រប់ៗគ្នា ។



www.elibraryofcambodia.org

## សំណួរ

១. តើតុលាមានរូបរាងដូចម្ដេច ?

២. តើការរត់ប្រណាំងនេះធ្វើនៅឯណា ?ធ្វើដើម្បីអ្វី ?

៣. តើការរត់ប្រណាំងលើកទី១ តុលាទទួលបានលទ្ធផលដូចម្ដេច ? ហេតុអ្វី ?

៤. តើការរត់ប្រណាំងលើកទី២ តុលាទទួលបានលទ្ធផលដូចម្ដេច ? ហេតុអ្វី ?

## លំហាត់

ក. ចូរជ្រើសរើសចម្លើយណា ដែលជាព្រឹត្តិការណ៍នៃរឿង ។

១. ថ្ងៃមួយ សាលាមានកម្មវិធីប្រកួតរត់ប្រណាំង ។

២. តុលារត់ប្រណាំងបានពាក់កណ្ដាលទី ទៅមុខលែងរួច ដាក់គូទអង្គុយចុះ ។

៣. តុលាខំហាត់ប្រាណ រត់ លេងកីឡា ។

៤. សិស្សទាំងអស់សើចចំអកឱ្យតុលា ។

៥. ការរត់ប្រណាំងលើកទី២ តុលាទទួលបានជោគជ័យ ។

ខ. តើតុលាមានចរិតលក្ខណៈដូចម្ដេច ? ចូរគូសសញ្ញា✓ ក្នុងប្រអប់ចម្លើយសមស្របមួយ ។

☐ ១. ស្លូតបូត

☐ ២. ខ្ជិលច្រអូស

☐ ៣. ព្យាយាម ។

គ. ចូរជ្រើសរើសនាមសាធារណ៍ នៅក្នុងប្រអប់ខាងក្រោមឱ្យបានត្រឹមត្រូវ ។

| | | | | |
|---|---|---|---|---|
| សាលា | សិស្ស | នាង | ធាត់ | ក្បាលពោះ |
| ភ្នែក | អឹកអាក់ | ច្រើន | ទី | ពេលវេលា |
| មាត់ | អង្គុយ | កីឡា | ឈរ | អ្នកគ្រូ |



www.elibraryofcambodia.org

## ការណែនាំអំពីការលេងល្បែង

ចូរអានការសន្ទនាខាងក្រោម ។ តើគេនិយាយផ្តល់ការណែនាំដូចម្តេចខ្លះ ?

តារា : សួស្តីមិត្តទាំងអស់គ្នា! ថ្ងៃនេះ លោកគ្រូបានឱ្យខ្ញុំដឹកនាំមិត្តទាំងអស់គ្នាលេងល្បែង "ក្រពើដេញចាប់" ។

វិជ្ជា : តើល្បែងនោះគេលេងដូចម្តេចទៅ ?

តារា : ដំបូងគេគូសគំនូសពីរស្របគ្នាដែលមានចម្ងាយពីគ្នាប្រហែល៤ម៉ែត្រ ធ្វើជាស្ទឹងមួយសម្រាប់ក្រពើរស់នៅ ។ បន្ទាប់មក អ្នកលេងបាវទាំងអស់គ្នា ។ អ្នកចាញ់ត្រូវឈរនៅក្នុងស្ទឹងធ្វើជាក្រពើ ។ អ្នកឯទៀត ត្រូវឈរតាមមាត់ស្ទឹងទាំងសងខាង និងត្រូវរត់ឆ្លងស្ទឹងចុះឡើងៗ ។

វិជ្ជា : ចុះបើក្រពើចាប់បានត្រូវធ្វើដូចម្តេច ?

តារា : បើក្រពើចាប់បានអ្នកណា អ្នកនោះនឹងត្រូវក្លាយជាក្រពើទី២ ។ ក្រពើទី១ត្រូវកាន់ដៃក្រពើទី២ ឱ្យជាប់ និងត្រូវរត់ដេញចាប់ អ្នករត់ឆ្លងកាត់ ។ បើរបូតដៃក្រពើទី២ត្រូវរួចខ្លួន ។ បើចាប់បានម្នាក់ទៀត អ្នកនោះត្រូវក្លាយជាក្រពើទី៣ ។ ក្រពើទាំងបីត្រូវកាន់ដៃគ្នាឱ្យជាប់ និងដេញចាប់អ្នកឆ្លង ។ បើចាប់បានម្នាក់ទៀត ត្រូវបង្កើតក្រុមក្រពើថ្មីបន្ថែមទៀត ដោយអនុវត្តដូចមុនដដែល ។

វិជ្ជា : ខ្ញុំយល់ហើយ! អរគុណ!

### លំហាត់

ចូររៀបគ្នាជាក្រុមតូចៗ ។ ក្រុមនីមួយៗ ត្រូវមានអ្នកណែនាំក្នុងការលេងល្បែងងាយៗមួយ តាមការចងចាំដល់សមាជិកក្នុងក្រុមខ្លួន ។ ល្បែងមានដូចជា ល្បែងដណ្តើមស្លឹកឈើ លេងអ៊ូ ដណ្តើមផ្ទះ ឱបចង្កេះ ដណ្តើមកៅអី ... ។



www.elibraryofcambodia.org

# សំណេរ

ក. ចូរបំពេញល្បះដោយប្រើពាក្យក្នុងប្រអប់ខាងក្រោមឱ្យបានត្រឹមត្រូវ ។

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| បង្ហោះ | ជា | បុរាណ | លេង | ប្រជាប្រិយ | កុមារី | កីឡាករ | ការប្រកួត | សុខភាព | រាល់ | ខ្មែរ |

១. យុវជននាំគ្នា.............ទាញព្រ័ត្រពេលចូលឆ្នាំ.................... ។

២. ...........អាទិត្យ មានកម្មវិធីប្រកួតប្រដាល់ក្បាច់គុន............ខ្មែរ ។

៣. យើងទស្សនា.......................បាល់ទាត់តាមទូរទស្សន៍ ។

៤. ការលេងកីឡានាំឱ្យមាន.................ល្អ ។

៥. គាត់ជា..............................ជើងឯកខាងប្រដាល់សេរី ។

៦. បោះអង្គុញ់..............ល្បែង.......................ខ្មែរ ។

៧. បងខ្ញុំកំពុង...................ខ្លែងឯក នៅកណ្តាលវាលស្រែ ។

៨. ..............................ចូលចិត្តលេងត្រែះនិងលោតអន្ទាក់ ។

ខ. ចូរតែងល្បះទាក់ទងគ្នាតាមរូបភាពខាងក្រោម ។

១. .............................. ។

២. .............................. ។

៣. .............................. ។



គ. ចូរតែងល្បះនឹងពាក្យខាងក្រោម ។

១. ចូលចិត្ត ៖...................... ។

២. មិនចូលចិត្ត ៖.................... ។

៣. សប្បាយ ៖........................ ។

ឃ. ចូរតែងល្បះនឹងពាក្យជានាមសាធារណ៍ “ល្បែងកម្សាន្ត កីឡា សុខភាព” ក្នុង១ពាក្យឱ្យបានមួយ១ល្បះ ។



www.elibraryofcambodia.org

ង. ចូរតែងល្បះទាក់ទងគ្នាឱ្យបាន៣ល្បះតាមរូបភាពនីមួយៗខាងក្រោម ។









www.elibraryofcambodia.org

មេរៀនទី ២

# សហគមន៍ជឿនលឿន



សហគមន៍ ជាកន្លែងដែលប្រជាពលរដ្ឋរស់នៅធ្វើការងារ និងកម្សាន្ត ។ សហគមន៍ជឿនលឿន សំដៅសហគមន៍ដែលប្រជាជនមានការចេះដឹង មានជីវភាពធូរធារ មានសេចក្ដីសុខ សុវត្ថិភាព រស់នៅមានសណ្ដាប់ធ្នាប់ និងមានការរីកចម្រើនគ្រប់ផ្នែក ។



www.elibraryofcambodia.org

# តួអង្គនិងកាលអាកាស

## ក. តួអង្គ

មនុស្ស សត្វ រុក្ខជាតិ ឬអមនុស្ស ដែលមាននៅក្នុងរឿង ជាតួអង្គនៅក្នុងរឿងនោះ ។ ក្នុងចំណោមតួអង្គទាំងនោះ មានតួអង្គខ្លះសំខាន់មានសកម្មភាពច្រើន តួអង្គខ្លះទៀត មានសកម្មភាពតិចតួច ឬបន្ទាប់បន្សំតែប៉ុណ្ណោះ ។ នៅក្នុងរឿងខ្លី ព្រឹត្តិការណ៍នៅក្នុងរឿងច្រើនផ្តោតទៅលើជីវិតរបស់តួអង្គសំខាន់ ។ តួអង្គនោះហៅថា "តួអង្គឯក" ។

ចូរអានរឿង " ក្មេងសុចរិត " រួចបង្ហាញតួអង្គរង និងតួអង្គឯក ។

នៅពេលខ្ញុំកំពុងអង្គុយហូបគុយទាវ ស្រាប់តែមានក្មេងម្នាក់មកអង្វរខ្ញុំឱ្យជួយទិញកាសែត ។ ពេលនោះ ខ្ញុំមានក្រដាសប្រាក់ប្រាំម៉ឺនរៀល ។ ក្មេងនោះអង្វរខ្ញុំថា ចាំវាយកទៅដូរគេ ហើយវាយកមកឱ្យខ្ញុំវិញ ។ ខ្ញុំក៏ឱ្យប្រាក់នោះទៅវា ។ ខ្ញុំចាំវាយូរពេកមិនឃើញវាមកវិញ ខ្ញុំគិតថា ក្មេងនោះប្រាកដជាបោកប្រាស់ខ្ញុំ ។ ខ្ញុំក៏ធ្វើដំណើរទៅធ្វើការ ។

មួយអាទិត្យក្រោយមក នៅពេលដែលខ្ញុំដើរចូលហាងគុយទាវដដែល ខ្ញុំបានឃើញក្មេងពីថ្ងៃមុនមកឈរចាំខ្ញុំ ។ ពេលឃើញខ្ញុំ វាដើរមកជិតហើយហុចលុយឱ្យខ្ញុំគ្រប់ចំនួន ។ ខ្ញុំសួរវា ៖ " ហេតុអ្វីបានជាថ្ងៃមុនឯងគេចពីខ្ញុំ? " ។ វាឆ្លើយដោយទឹកមុខស្រងូត ៖ " ខ្ញុំបាទត្រូវម៉ូតូបុក ទើបមិនបានយកប្រាក់មកជូនលោកពូវិញ ។ ពេលនេះ ខ្ញុំបានធូរស្រាល ក៏យកមកជូនលោកពូវិញ " ។ ខ្ញុំពិនិត្យមើលជើងវា ឃើញមានរបួសមែន ។ ខ្ញុំក៏ឈប់សង្ស័យ ចំពោះក្មេងនោះទៅ ។ វាបានសុំទោសខ្ញុំ ហើយធ្វើដំណើរទៅលក់កាសែតបន្តទៀត ។

តួអង្គនៅក្នុងរឿងនេះមាន ៖ ក្មេងលក់កាសែត និងបុរសអ្នកទិញកាសែត ។

តាមសកម្មភាពតួអង្គខាងលើ ក្មេងលក់កាសែត ជាតួអង្គដែលសំខាន់ ។ វាជា " តួអង្គឯក" ។ ឯបុរសអ្នកទិញកាសែត ជា " តួអង្គរង " ។



www.elibraryofcambodia.org

តួអង្គឯក គឺជាតួអង្គសំខាន់បំផុត ហើយមានសកម្មភាព ច្រើនជាងគេនៅក្នុងដំណើររឿងទាំងមូល ។ តួអង្គរង គឺតួអង្គដែលពុំសូវសំខាន់ ។

ង. កាលអាកាស

កាលអាកាស គឺជាពេលវេលា និងទីកន្លែងដែលដំណើររឿងប្រព្រឹត្តទៅ ។ កាលអាចបង្ហាញពីថ្ងៃ យប់ រដូវណាមួយ ពេលកន្លងមក បច្ចុប្បន្ន ឬពេលខាងមុខ ។ អាកាសគឺជាកន្លែងដែលរឿងកើតឡើង ។

កាលអាកាសនៅក្នុងរឿងខាងលើគឺ ៖

កាល ៖ ពេលកំពុងហួបគុយទាវ មួយអាទិត្យក្រោយមក

អាកាស ៖ ហាងគុយទាវ ។

កាលអាកាស គឺជាពេលវេលា និងទីកន្លែងដែលដំណើររឿងប្រព្រឹត្តទៅ ។

លំហាត់

ចូរអានរឿង " ព្រះថោងនាងនាគ " រួចរកតួអង្គ និងកាលអាកាស ។

កាលពីព្រេងនាយ មានឈ្មួញសំពៅជនជាតិឥណ្ឌាម្នាក់នាម " ព្រះថោង " បានមកដល់ដីជំនួញនៅសមុទ្រខាងត្បូង ។ យប់មួយ ព្រះថោងបោះពលរេហ៍ចូលចតសម្រាកនៅកោះមួយ ។ កោះនេះ ជាកន្លែងដែលនាងនាគតែងកាឡាខ្លួនជាស្រីក្រមុំដ៏ស្អាត នាំអ្នកកំដរមកលេងទឹកជារៀងរាល់យប់ ។ ព្រះថោងឃើញនាងនាគ ក៏កើតក្តីស្រឡាញ់ ។ អ្នកទាំងពីរ មានទឹកចិត្តស្នេហាគ្នាទៅវិញទៅមក ។ ស្តេចនាគទ្រង់ជ្រាប ក៏យាងមកកោះនោះហើយរៀបអភិសេកបុត្រទាំងពីរតាមប្រពៃណី ។

ក្រោយមក ព្រះថោងចង់ទៅស្គាល់ឋានភុជង្គនាគ តែទ្រង់ពុំចេះជ្រែកទឹក ជ្រែកដីសោះ ។ នាងនាគក៏ឱ្យព្រះថោងតោងកន្ទុយមុជជ្រែកទឹក ជ្រែកដីបានទៅដល់ឋានភុជង្គនាគដូចប្រាថ្នា ។



www.elibraryofcambodia.org

# រឿង គ្រូពេទ្យភូមិយើង

ចូរអានអត្ថបទ រួចឆ្លើយនឹងសំណួរខាងក្រោម ។



នៅវេលាយប់មួយ ជីដូនខ្ញុំគ្រុនក្ដៅខ្លាំង រហូតដល់សន្លប់បាត់ស្មារតី ។ ម្ដាយខ្ញុំភ័យស្លន់ស្លោមិនដឹងជាធ្វើដូចម្ដេច ។ មួយសន្ទុះក្រោយមក គាត់ក៏សម្រេចចិត្តជូនលោកយាយទៅមណ្ឌលសុខភាព ។ អ្នកជិតខាងបានឮសំឡេងជជែកគ្នា ក៏បើកទ្វារចេញមកមើល ។ អ្នកខ្លះជួយកោសខ្យល់ ខ្លះទៅហៅរ៉ឺម៉កមកដឹកលោកយាយ ។ ពូប្រធានភូមិបានដឹងរឿងក៏ប្រញាប់មកជួយគ្រាហ៍លោកយាយ ហើយធ្វើដំណើរទៅជាមួយគ្រួសារខ្ញុំដែរ ។

ពេលទៅដល់មណ្ឌលសុខភាព លោកគ្រូពេទ្យវ័យក្មេងម្នាក់ដែលប្រចាំការ បានចេញមកសាកសួរ ដោយរាក់ទាក់បំផុត ។ យើងនាំគ្នាជួយគ្រាហ៍ លោកយាយចូលក្នុងបន្ទប់ ។ លោកគ្រូពេទ្យ ចាប់ផ្ដើមពិនិត្យជំងឺលោកយាយ ដោយយកចិត្តទុកដាក់ ។ បន្ទាប់មក លោកចាក់ថ្នាំជូនលោកយាយ ហើយប្រាប់ម្ដាយខ្ញុំកុំឱ្យបារម្ភ ព្រោះបន្តិចទៀតលោកយាយនឹងធូរស្រាលហើយ ។ លោកយកថ្នាំមកទុកជូនលោកយាយពិសា នៅពេលគាត់ដឹងខ្លួនហើយក៏ហួសទៅសម្រាក ។ មួយសន្ទុះក្រោយមក គាត់អញ្ជើញមកម្ដងទៀត ឃើញលោកយាយដឹងខ្លួន លោកនិយាយលួងលោមដោយសម្ដីផ្អែមល្ហែម គួរឱ្យកក់ក្ដៅ ។



www.elibraryofcambodia.org

ពេលលោកយាយបានធូរស្រាល ពូប្រធានភូមិក៏លាពួកយើងត្រឡប់ទៅផ្ទះវិញ ។ យើងនាំគ្នាសម្រាកនៅទីនោះមួយយប់ ។ លុះព្រឹកឡើង យើងនាំគ្នាអរគុណលោកគ្រូពេទ្យ ហើយនាំលោកយាយត្រឡប់មកផ្ទះវិញ ។

## សំណួរ

១. តើរឿងនេះ មានតួអង្គណាខ្លះ ?

២. តើអ្នកណាជាតួអង្គឯក ? អ្នកណាជាតួអង្គរង ?

៣. តើរឿងនេះ កើតឡើងនៅកន្លែងណា ? នៅពេលណា ?

## លំហាត់

ក. ចូរជ្រើសរើសចម្លើយ ដែលជាព្រឹត្តិការណ៍នៃរឿង ។

១. ជីដូនខ្ញុំគ្រុនក្តៅខ្លាំង រហូតដល់សន្លប់បាត់ស្មារតី ។

២. គ្រូពេទ្យមិនអើពើ នឹងជំងឺរបស់លោកយាយឡើយ ។

៣. អ្នកជិតខាងភ័យស្លន់ស្លោ នឹងជំងឺលោកយាយ ។

៤. ប្រធានភូមិខ្នះខ្នែង ជូនលោកយាយទៅមណ្ឌលសុខភាព ។

៥. គ្រូពេទ្យពិនិត្យព្យាបាល លោកយាយរហូតជាសះស្បើយ ។

ខ. ចូររកពាក្យមានន័យផ្ទុយនឹងពាក្យខាងក្រោម ។

| ធូរ | ផ្អែមល្ហែម | ក្មេង |
|---|---|---|
| ១. លំបាក | ១. បូបាច់ | ១. ចាស់ |
| ២. តឹង | ២. ពីរោះ | ២. ខ្ញី |
| ៣. រលុង | ៣. គំរោះគំរើយ | ៣. ទុំ |

គ. ចូររកពាក្យមានសូរដូចនឹងពាក្យ "លា សួរ" ដោយពន្យល់ន័យនៃពាក្យនីមួយៗផង ។



www.elibraryofcambodia.org

## សំណេរ

ក. ចូរបំពេញល្បះខាងក្រោម ដោយជ្រើសរើសពាក្យក្នុងប្រអប់ ។

| ច្បាប់ | រាងវៃ | ស្រឡាញ់ | ទុច្ចរិត | ហិង្សា | ការងារ | ល្បែង | ជឿនលឿន | រស់ | ល្អ |
|---|---|---|---|---|---|---|---|---|---|

១. ខ្ញុំខំរៀនដើម្បីអភិវឌ្ឍសហគមន៍ឱ្យបាន ............... ។

២. ប្រធានភូមិខ្ញុំជាស្ត្រី ដែលឆ្លាត ............ ជាងគេនៅក្នុងភូមិ ។

៣. គ្មាននរណាម្នាក់ លេង ............. ស៊ីសងនៅក្នុងភូមិឡើយ ។

៤. ប្រជាជន ............. រាប់អានគ្នាដូចបងប្អូន ។

៥. នគរបាលខិតខំបង្ក្រាបជន .............. ឱ្យអស់ពីភូមិ ។

៦. ប្រជាជនម្នាក់ៗ មាន .............. ធ្វើគ្រប់គ្នា ។

៧. យើងនាំគ្នាគោរព ............. និងគោរពសិទ្ធិគ្នាទៅវិញទៅមក ។

៨. សមាជិកសហគមន៍ស្គាល់ និងបំពេញតួនាទីរបស់ខ្លួនបាន ............. ។

៩. គេមិនដែលឃើញមានអំពើ ............... នៅក្នុងគ្រួសារឡើយ ។

១០. យើង .............. នៅ យ៉ាងសុខសាន្តជាមួយគ្នា ។

ខ. ចូរគូសភ្ជាប់កន្សោមពាក្យឱ្យបានជាល្បះសមស្រប ។

| ផ្នែកលេខ | ផ្នែកអក្សរ |
|---|---|
| ១. មេឃុំកនាំឃុំ / សង្កាត់ | ក. ខំរៀនសូត្រគ្រប់ៗគ្នា ។ |
| ២. គ្រូពេទ្យ | ខ. ចេះសាមគ្គីគ្នាណាស់ ។ |
| ៣. យើង | គ. ខំព្យាបាលអ្នកជំងឺ ។ |
| ៤. សិស្សានុសិស្ស | ឃ. ជួយរកការងារជូនប្រជាជន ។ |
| ៥. ប្រជាជនភូមិខ្ញុំ | ង. នាំគ្នាថែរក្សាសុខភាព ។ |



www.elibraryofcambodia.org

# រឿង ឃាតកៈទាំង ៧

បន្ទាប់ពីស្ដាប់រឿង ចូរឆ្លើយនឹងសំណួរ ។



## សំណួរ

១. តើភ្នាក់ងារមណ្ឌលសុខភាព ទៅផ្ទះលោកមេឃុំដើម្បីអ្វី ?

២. តើលោកមេឃុំយល់ព្រម ឬទេ ? ហេតុអ្វី ?

៣. តើភ្នាក់ងារមណ្ឌលសុខភាព និយាយពីរឿងអ្វីប្រាប់លោកមេឃុំ ?

៤. តើរឿងនេះ មានតួអង្គប៉ុន្មាននាក់ ? តួអង្គអ្វីខ្លះ ? តើតួអង្គទាំងនោះមានភារកិច្ចធ្វើអ្វី ?

៥. តើជំងឺទាំងប្រាំពីរមុខមានអ្វីខ្លះ ?

៦. តើគេបង្ការជំងឺទាំងប្រាំពីរមុខបានដោយសារអ្វី ?

## គុណនាម

ចូរអានឧទាហរណ៍ និងស្វែងយល់ពាក្យដែលមានគំនូសពីក្រោម ។

ភូមិខ្ញុំជាភូមិចាស់ពីបុរាណ តែមេភូមិខ្ញុំមានគំនិតជឿនលឿន ។ ប្រជាជនភូមិខ្ញុំ សុទ្ធតែជាមនុស្សពូកែ ។ ពួកគាត់ប្រកបរបរកសិកម្ម តាមបច្ចេកទេសថ្មី ។ ពួកគាត់មានជីវភាពធូរធារ និងមានសុខភាពល្អ ។ គ្រួសារនីមួយៗបានទិញឧបករណ៍ និងគ្រឿងប្រើប្រាស់ទំនើបៗថែមទៀត សម្រាប់បម្រើសេចក្ដីត្រូវការរាល់ថ្ងៃ ។



www.elibraryofcambodia.org

ពាក្យដែលមានគំនូសពីក្រោមជាគុណនាម រីឯពាក្យអក្សរដិតជានាម ។
គុណនាម " ចាស់" បញ្ជាក់ លក្ខណៈរបស់នាម " ភូមិ" ។
គុណនាម " ជឿនលឿន" បញ្ជាក់លក្ខណៈរបស់នាម " គំនិត " ... ។

គុណនាម ជាពាក្យបញ្ជាក់លក្ខណៈរបស់នាម ។ គុណនាម មានទីតាំងនៅខាងស្ដាំនាម ។

## លំហាត់

**ក.** ចូរជ្រើសរើសពាក្យបំពេញក្នុងប្រអប់ខាងក្រោម ឱ្យបានសមស្រប ។

| ស្អាត | មូល | ជ្រៅ | តឿ | ថ្លា | ផ្លូវ | មនុស្ស | ក្ដៅ | ធំ |
|---|---|---|---|---|---|---|---|---|

| | | |
|---|---|---|
| ១. យប់.................. | ២. .................. វែង | ៣. ទឹក.................. |
| ៤. មនុស្ស.................. | ៥.................... តូច | ៦. ដើមឈើ............ |
| ៧. អាកាសធាតុ............ | ៨.................. ក្លាហាន | ៩. ផែនដី.................. |

**ខ.** ចូររកគុណនាមនៅក្នុងល្បះខាងក្រោម ។

១. ប្រជាជនភូមិខ្ញុំ មានជីវភាពធូរធារ ។
២. គ្រួសារនីមួយៗប្រជុំ និងអនុវត្តតាមការណែនាំល្អៗ របស់មេឃុំ ។
៣. ប្រធានភូមិ ចែកម៉ាស៊ីនបូមទឹកថ្មីៗដល់កសិករ ។
៤. អ្នកធ្វើសិប្បកម្ម ខិតខំរកបច្ចេកទេសល្អៗ ។

**គ.** ចូរអានកថាខណ្ឌខាងក្រោម រួចស្រង់កន្សោមពាក្យដែលជាគុណនាម ។

នេះគឺជាសហគមន៍ថ្មី ដែលទើបនឹងបង្កើត ។ សហគមន៍នេះ មានទីតាំងធំទូលាយ មានបឹងតូចមួយនៅចំកណ្ដាល និងមានផ្លូវតូចធំខ្វាត់ខ្វែង ។ អមសងខាងផ្លូវធំ មានផ្ទះធំៗ ។ ប្រជាជនចេះថែរក្សាអនាម័យ ទើបពួកគេមានសុខភាពល្អ ។



www.elibraryofcambodia.org

## បរិបទបញ្ជាក់ ឬទីសេចក្ដីបញ្ជាក់

គេអាចយល់ន័យពាក្យពិបាកបានដោយប្រើវចនានុក្រម បទានុក្រម ឬស្វែងយល់ន័យពាក្យ ឃ្លា ល្បះនៅជុំវិញពាក្យពិបាកនោះ ។ ក្នុងមេរៀននេះ អ្នកនឹងសិក្សាពីវិធីស្វែងយល់ន័យពាក្យពិបាកតាមរយៈ ពាក្យ ឃ្លា ល្បះនៅជុំវិញពាក្យនោះដែលគេហៅថា " បរិបទ ឬទីសេចក្ដីបញ្ជាក់ " ។

ចូរអានឧទាហរណ៍នីមួយៗខាងក្រោម ។

១. សហគមន៍នេះ ប្រកបរបរសិប្បកម្ម មានត្បាញក្រមា ហូល ផាមួង ។

២. តាសៅខំផលិតនៃសាទុបករណ៍ដូចជា ទ្រូ លប ព្រួល ឈ្នាង អង្រុត ។

៣. ជនសុចរិត គឺជាជនរកស៊ីត្រឹមត្រូវ មិនបំបាត់ កេងបន្លំ ឬធ្វើអ្វីខុសច្បាប់ ។

៤. ប្រជាជនភូមិនេះ សម្បូរអក្ខរជន ព្រោះពួកគេភាគច្រើនបានទៅរៀនសូត្រ ។

៥. នគរបាលតាមដានចោរកម្ម និងបង្ក្រាបអំពើលួចប្លន់ទាំងនោះ ។

៦. ពូខ្ញុំលក់តុ ទូ កៅអី ។ គ្រឿងសង្ហារិមទាំងនោះ ធ្វើពីឈើប្រណិត ។

នៅក្នុងល្បះនីមួយៗខាងលើ អ្នកអាចយល់ន័យពាក្យអក្សរដិតដោយពាក្យ ឃ្លា ល្បះ ដែលមានគំនូសពីក្រោមបរិបទបញ្ជាក់របស់វា ។

> បរិបទបញ្ជាក់ ឬទីសេចក្ដីបញ្ជាក់របស់ពាក្យណាមួយ គឺជាពាក្យ ឃ្លា ល្បះ ដែលនៅជុំវិញ (ខាងមុខ ឬខាងក្រោយ) ពាក្យនោះ ហើយជួយឱ្យយល់ន័យពាក្យពិបាកនោះ ។

### លំហាត់

ចូរអានរួចស្រង់ពាក្យ ឃ្លា ឬល្បះដែលជួយឱ្យអ្នកយល់ន័យពាក្យអក្សរដិត ។

១. សហគមន៍ខ្ញុំ មានតំបន់ទេសចរណ៍ធម្មជាតិដូចជាទឹកឈូ ឆ្នេរសមុទ្រជាដើម

២. កន្លែងសក្ការបូជា គឺជាកន្លែងដែលគេគោរពបន់ស្រន់ ។

៣. នគរបាលសម្រួលចរាចរណ៍តាមផ្លូវ ដើម្បីឱ្យការធ្វើដំណើរទៅមកបានស្រួល



www.elibraryofcambodia.org

# សមាគមវាយនភ័ណ្ឌ

ចូរអានអត្ថបទ រួចឆ្លើយនឹងសំណួរខាងក្រោម ។




ប្រជាពលរដ្ឋនៅភូមិខ្ញុំភាគច្រើន ប្រកបរបរត្បាញហូល ផាមួង និងក្រមា ។ បច្ចុប្ប នេះ ពួកគាត់បានចងក្រងជាសមាគមមួយឈ្មោះថា “ សមាគមវាយនភ័ណ្ឌ ” ដើម្បី មានឱកាសជួយគ្នាទៅវិញទៅមក ទទួលបានការអភិវឌ្ឍដូចគ្នា និងការពារផលប្រយោជ រួមរបស់សមាគម ។ ពួកគេបានធ្វើការជ្រើសរើសប្រធានម្នាក់ និងអនុប្រធានសមាគម ម្នាក់ ដោយធ្វើការបោះឆ្នោត ។ សមាគមតែងអនុវត្តតាមសំណូមពររបស់សមាជិក និង បានខ្នះខ្នែងរកទីផ្សារនៅក្នុង និងក្រៅប្រទេស ដើម្បីងាយស្រួលក្នុងការលក់ផលិតផល គ្រប់ប្រភេទ និងទទួលបានតម្លៃខ្ពស់ ។ ម្យ៉ាងទៀត សមាគមបានបណ្តុះបណ្តាលសមាជិក ដោយបង្រៀនត្បាញ ការសូត្រ ថែទាំដង្កូវនាង ។ល។ ឱ្យចេះគ្រប់គ្នា ។ លើសពីនេះ សមាគមតែងតែប្រជុំផ្សព្វផ្សាយព័ត៌មានសំខាន់ៗដល់សមាជិកដូចជា ការអប់រំសុខភា គ្រោះមហន្តរាយ បច្ចេកទេសដាំដុះ និងការបោះឆ្នោត ។ ជាងនេះទៀត សមាគមបាន ស្វែងរកថវិកា ដើម្បីយកមកជួយសមាជិកឱ្យបានរីកចម្រើន និងចេញមុខដោះស្រាយការ លំបាករបស់សមាជិកជានិច្ច ។

ការចងក្រងជាសមាគម គឺជាគំនិតដ៏ជឿនលឿនមួយ ដែលប្រជាជនយើងគប្បី រួបរួមគ្នាបង្កើតនៅតាមតំបន់នានាដែលខ្លួនរស់នៅ ។



www.elibraryofcambodia.org

## សំណួរ

១. តើប្រជាជនបានបង្កើតសមាគមអ្វី ?

២. តើគេជ្រើសរើសតំណាងសមាគមដូចម្តេច ?

៣. តើគេបង្កើតសមាគមដើម្បីអ្វី ?

## លំហាត់

ចូរអានល្បះឡើងវិញ រួចស្រង់បរិបទបញ្ជាក់ ( ពាក្យ ឬឃ្លាដែលជួយឱ្យយល់ន័យនៃពាក្យអក្សរដិត ) ក្នុងល្បះខាងក្រោម ។

១. សមាគមបានបណ្តុះបណ្តាលសមាជិកដោយបង្រៀនត្បាញ ការសូត្រ ថែទាំដង្កូវនាង ។ល ។

២. សមាគមតែងប្រជុំផ្សព្វផ្សាយ**ព័ត៌មានសំខាន់ៗ** ដល់សមាជិកដូចជា **ការអប់រំសុខភាព គ្រោះមហន្តរាយ ការបោះឆ្នោតជាដើម** ។

## សំណេរ

ក. ចូរបំពេញល្បះខាងក្រោម ដោយគំនិតផ្ទាល់ខ្លួនឱ្យបានត្រឹមត្រូវ ។

១. យើងត្រូវរួមគ្នាសម្អាត.......................... នៅក្នុងសហគមន៍យើង ។

២. សហគមន៍មានសណ្តាប់ធ្នាប់........... លុះត្រាតែប្រជាជនចេះគោរព...... ។

៣. កសិករនាំគ្នាដាំដុះតាម................. ទំនើប ។

៤. មេដឹកនាំសហគមន៍ត្រូវ................. ចំពោះសមាជិក ។

៥. នៅភូមិយើង......................... ប្រព័ន្ធធារាសាស្ត្រខ្នាត់ខ្វែង ។

ខ. ចូរតែងល្បះដោយប្រើគុណនាមនីមួយៗខាងក្រោមឱ្យបានត្រឹមត្រូវ ។

១. រហ័ស ៖............................... ។

២. ថ្លៃថ្នូរ ៖............................... ។

៣. ធំ ៖............................... ។

៤. ខ្ពស់ ៖............................... ។



www.elibraryofcambodia.org



# សហគមន៍ថ្មី

ចូរអានអត្ថបទ រួចឆ្លើយនឹងសំណួរខាងក្រោម ។



នៅតំបន់ជនបទ មានសហគមន៍តូចមួយនៅឆ្ងាយដាច់ពីគេ ។ មើលពីចម្ងាយ
ឃើញហាក់ដូចជាព្រៃមួយដុំសែនឆ្ងាយសន្លឹម ។ ពេលចូលទៅដល់ នៅសងខាងផ្លូវមា
ផ្ទះរត់ជួររមេញ ។ សហគមន៍នេះ មានហេដ្ឋារចនាសម្ព័ន្ធជាច្រើនដូចជា ផ្លូវថ្នល់ ស្ពា
ប្រឡាយទឹកខ្វាត់ខ្វែង លូបង្ហូរទឹក សាលារៀន មណ្ឌលសុខភាព សាលាឃុំ ផ្សា
សម្រាប់បម្រើសេចក្តីត្រូវការរបស់ប្រជាជន ។ អ្នកដឹកនាំស្ថាប័ននីមួយៗ សុទ្ធតែជ
មនុស្សស្នេហាជាតិ ស្អាតស្អំ និងគោរពតួនាទីរបស់ខ្លួនបានល្អគ្រប់ពេលវេលា ។

អ្នកស្រុកនេះ ភាគច្រើនជាមនុស្សចេះដឹង ឧស្សាហ៍ព្យាយាម និងមានគំនិតជឿ
លឿន ។ ពួកគេចូលចិត្តស្តាប់ព័ត៌មានផ្សេងៗ ទាក់ទងនឹងការអប់រំ បញ្ហាសុខភាព និ
ខិតខំរៀនបច្ចេកទេសកសិកម្មថ្មីៗ ។ អ្នករស់នៅតំបន់នេះ មិនដែលទុកពេលវេលាឱ
នៅទំនេរឡើយ ។ គេច្រើនប្រកបរបរកសិកម្មដូចជា ដាំដំណាំ ធ្វើស្រែ ចិញ្ចឹមសត្វតា
បច្ចេកទេសទំនើប និងធ្វើសិប្បកម្ម ។ ប្រជាជននៅទីនេះ ជាមនុស្សសន្តិភាពនិយម
ពេលមានទំនាស់ គេតែងដោះស្រាយដោយអហិង្សា ។ ពួកគេរស់នៅមានសណ្តាប់ធ្នា
ល្អ ចេះគោរពច្បាប់ មានអធ្យាស្រ័យល្អ និងចេះជួយគ្នាទៅវិញទៅមក ។

អ្នកទៅដល់សហគមន៍ថ្មីនោះតែងសរសើរថា គឺជាសហគមន៍ដ៏សុខសាន្ត និ
ជឿនលឿនបំផុត ។



www.elibraryofcambodia.org

## សំណួរ

១. តើសហគមន៍នេះ ស្ថិតនៅឯណា ?

២. តើប្រជាជននៅក្នុងសហគមន៍ ជាមនុស្សដូចម្ដេច ?

៣. តើនៅក្នុងសហគមន៍ មានហេដ្ឋារចនាសម្ព័ន្ធអ្វីខ្លះ ?

៤. ហេតុអ្វីបានជាប្រជាជននៅក្នុងសហគមន៍ ចូលចិត្តស្ដាប់ការផ្សព្វផ្សាយព័ត៌មានផ្សេងៗ ?

៥. ហេតុអ្វីបានជាពួកគេ មិននិយមប្រើហិង្សា ?

## លំហាត់

ក. ចូរស្រង់គុណនាមពីក្នុងអត្ថបទខាងលើឱ្យបានចំនួនប្រាំ ។

ខ. ចូររកពាក្យន័យដូចនឹងពាក្យខាងក្រោម ។

| គេហដ្ឋាន | ទំនើប | ទំនាស់ | សន្តិភាព |
|---|---|---|---|
| ១. ផ្ទះ | ១. ចាស់ | ១. ការតវ៉ា | ១.ភាពថ្លៃថ្នូរ |
| ២. សាលា | ២. បុរាណ | ២. ជម្លោះ | ២.ភាពសុខសាន្ត |
| ៣. រោង | ៣. ថ្មី | ៣. ការជជែក | ៣.ភាពរុងរឿង |

គ. ចូររកពាក្យន័យផ្ទុយនឹងពាក្យ“អសន្តិសុខ ចូរផារ ឆ្ងាយ សកម្ម អហិង្សា” ។

ឃ. ចូររកពាក្យសូរដូចនឹងពាក្យ“ឃុំ” ។

ង. ចូរស្រង់ពាក្យ ឬឃ្លា ដែលជួយឱ្យយល់ន័យពាក្យអក្សរដិតក្នុងល្បះខាងក្រោម ។

សហគមន៍នេះ មានហេដ្ឋារចនាសម្ព័ន្ធជាច្រើនដូចជាផ្លូវថ្នល់ ស្ពាន ប្រឡាយទឹក លូបង្ហូរទឹក សាលារៀន មណ្ឌលសុខភាព សាលាឃុំ ផ្សារ ជាដើមសម្រាប់បម្រើសេចក្ដីត្រូវការរបស់ប្រជាជន ។



www.elibraryofcambodia.org

# សំណេរ

ក. ចូរគូសភ្ជាប់ផ្នែក"ក" និងផ្នែក"ខ" ឱ្យបានជាល្បះត្រឹមត្រូវ ។

| ក | ខ |
|---|---|
| ១. សហគមន៍ជនជាតិចាម | ក. នៅក្នុងសហគមន៍ថ្មី ។ |
| ២. ប្រធានសមាគម | ខ. ប្រារព្ធទិវាបរិស្ថាន ។ |
| ៣. ប្រជាជនរស់យ៉ាងសប្បាយ | គ. ធ្វើឱ្យសហគមន៍មានការរីកចម្រើន ។ |
| ៤. អាណាព្យាបាលគ្រប់រូប | ឃ. បង្រៀនបច្ចេកទេសចិញ្ចឹមត្រីដល់សមាជិក ។ |
| ៥. ប្រជាពលរដ្ឋនាំគ្នា | ង. ច្រើនប្រកបរបរនេសាទ ។ |
| ៦. យើងទាំងអស់គ្នាត្រូវចូលរួម | ច. ថែរក្សាសម្បត្តិសាធារណៈ ។ |
| ៧. មេដឹកនាំ | ឆ. នាំកុមារអាយុ៦ឆ្នាំទៅចុះឈ្មោះចូលរៀន ។ |

ខ. ចូរបំពេញល្បះខាងក្រោមឱ្យបានសមស្រប ។

១. នៅតាមជនបទ គេស្ថាបនា.................ខ្វាត់ខ្វែង ។

២. ប្រជាជនយើង នាំគ្នា............ដោយប្រើជីធម្មជាតិ ។

៣. ការគោរពច្បាប់ចរាចរណ៍ គឺជាការជួយកាត់បន្ថយ............. ។

៤. ជនជាតិភាគតិច បង្កើតសហគមន៍ការពារ................. ។

៥. គេនាំគ្នាកាត់បន្ថយការជក់...............ដើម្បីរក្សាសុខភាព ។

គ. ចូរតែងល្បះទាក់ទងនឹងរូបភាពខាងក្រោម ។



១. ......................................... ។

២. ......................................... ។

៣. ......................................... ។

៤. ......................................... ។

ឃ. ចូរតែងល្បះនឹងពាក្យ" ធូរធារ ក្រហម វែង ចាស់"ក្នុងមួយពាក្យឱ្យបានមួយល្បះ ។



www.elibraryofcambodia.org

# ការណែនាំក្នុងការប្រាប់ទិស

ចូរអានការណែនាំខាងក្រោម រួចឆ្លើយនឹងសំណួរ ។

ឌីណា: ជម្រាបសួរលោកពូ! ខ្ញុំសូមសួរបន្តិច តើមន្ទីរពេទ្យគន្ធបុប្ផាស្ថិតនៅឯណា?

លោកពូ : បើក្មួយចេញដំណើរពីរង្វង់មូលក្បាលថ្នល់ ត្រូវធ្វើដំណើរទៅជើងតាមមហាវិថីព្រះនរោត្តម ឆ្លងកាត់វិមានឯករាជ្យ ទៅត្រង់រហូតដល់វត្តភ្នំ ។

មន្ទីរពេទ្យគន្ធបុប្ផាស្ថិតនៅជ្រុងខាងជើង ឆៀងខាងលិចវត្តភ្នំ ។ សូមក្មួយមើលប្លង់នេះ ។




ឌីណា : អរគុណហើយលោកពូ! ជម្រាបលា !

## លំហាត់

ចូរចាប់ដៃគូសង្កេតប្លង់ខាងក្រោម រួចបកស្រាយប្រាប់ផ្លូវទៅកាន់មន្ទីរពេទ្យកុមារជាតិ ដោយចេញដំណើរពីស្ថានីយរថភ្លើង ។






www.elibraryofcambodia.org

## សំណេរ

ចូរសង្កេតរូបភាព និងអានការបកស្រាយក្នុងការប្រាប់ទិសទៅរកកន្លែងផលិតទឹកកក ។




ដំបូង ត្រូវធ្វើដំណើរចេញពីសាលាឃុំមកត្បូងត្រង់ រួចបត់ឆ្វេងបន្តិច ដល់សាលារៀន រួចបន្តដំណើរទៅមុខត្រង់ឃើញផ្សារនៅខាងស្តាំដៃ ទៅមុខបន្តិចទៀតឃើញសាលាស្រុកនៅខាងឆ្វេងដៃ រួចបត់ឆ្វេងបន្តិចនឹងដល់កន្លែងផលិតទឹកកក ។

## លំហាត់

ក. អ្នកស្ថិតនៅត្រង់ស្ថានីយរថភ្លើង ពេលនេះអ្នកចង់ធ្វើដំណើរទៅសាលារៀន ។ ចូរអ្នកសរសេរការណែនាំប្រាប់ទិស ដែលត្រូវទៅសាលារៀននោះឱ្យបានក្បោះក្បាយ ។




ខ. ចូរសរសេរការណែនាំប្រាប់ទិស ទៅរកផ្ទះរបស់អ្នក ដោយចេញដំណើរពីសាលារៀនរបស់អ្នក ។



www.elibraryofcambodia.org

មេរៀនទី ៣

# ការគួរសម



ខ្មែរយើង ប្រកាន់យកឥរិយាបថសមរម្យជានិច្ចក្នុងការរស់នៅ ។ ឥរិយាបថទាំងនោះមាន ការដើរ ការដេក ការឈរ ការអង្គុយ និងការនិយាយស្តី ។ អ្នកដែលមានឥរិយាបថឆ្គាំឆ្គង តែងត្រូវគេរិះគន់ ។ ចំណែកអ្នកមានឥរិយាបថល្អ អ្នកផងតែងកោតសរសើរ ស្រឡាញ់រាប់អានគ្រប់ទិសទី ។



www.elibraryofcambodia.org

## បទានុក្រម

បើអ្នកមិនយល់ពាក្យណាមួយនៅក្នុងសៀវភៅ អ្នកអាចប្រើវចនានុក្រម ឬបទានុក្រមដើម្បីមើលសូរអាន ថ្នាក់ពាក្យ និងសេចក្ដីពន្យល់ន័យរបស់ពាក្យនោះ ។ ចូរមើលគំរូបទានុក្រមខាងក្រោម ៖

| ក | ខ |
|---|---|
| កល(កល់) ន. ពុតត្បុត ល្បិច ឧបាយ យ៉ាងល្អិត ។<br>កល់ កិ. ទ្រពីក្រោម សែមពីក្រោមដើម្បីឱ្យស្មើមិនឱ្យល្អៀង ឬដើម្បីឱ្យហើប ឱ្យខ្ពស់ឡើង ។<br>កា ន. បំពង់សម្រាប់ដាក់ទឹក ៖ កាទឹក ។ | ខណ្ឌ (ខ័ន) ន. សង្កាត់ ប៉ែក កំណត់ បែកអាណាខេត្ត : ខណ្ឌដូនពេញ ។<br>**គ**<br>គ គុ. ឥតសម្ដី មនុស្សគ ។<br>គរ កិ. ធ្វើឱ្យជាគំនរ ។ |

ពាក្យនៅដើមជួរនីមួយៗ ជាពាក្យត្រូវពន្យល់ ។ ពាក្យទាំងនោះ ត្រូវបានតម្រៀបតាមលំដាប់តួអក្សរ (លំដាប់ព្យញ្ជនៈ និងលំដាប់ស្រៈ) ។ អក្សរនៅក្នុងវង់ក្រចក ជាសូរអានរបស់ពាក្យខាងដើម ។ អក្សរកាត់នៅបន្ទាប់ពីសូរអាន គឺជាថ្នាក់ពាក្យរបស់ពាក្យខាងដើម ។ បន្ទាប់ពីថ្នាក់ពាក្យ គឺជាសេចក្ដីពន្យល់ន័យរបស់ពាក្យខាងដើម ។

> បទានុក្រម គឺជាបញ្ជីពាក្យពិបាក ដែលស្រង់ចេញពីសៀវភៅ ។ ពាក្យទាំងនេះ ត្រូវបានរៀបតាមអក្ខរក្រម ដោយមានប្រាប់សូរអាន និងសេចក្ដីពន្យល់ន័យរបស់ពាក្យ ។ បទានុក្រម នៅផ្នែកខាងក្រោយនៃសៀវភៅ ។

### លំហាត់

ចូរអ្នកបើកបទានុក្រមនៅផ្នែកខាងក្រោយនៃសៀវភៅភាសាខ្មែរថ្នាក់ទី៤ ដើម្បីមើលសូរអាននិងន័យរបស់ពាក្យ “ ស្ទូរ បញ្ហា សាធារណៈ ប្រាជ្ញា ” ។



www.elibraryofcambodia.org

# ការគោរពឪពុកម្ដាយ

ចូរអានអត្ថបទ រួចឆ្លើយនឹងសំណួរខាងក្រោម ។



ឪពុកម្ដាយ ជាអ្នកមានគុណដ៏លើសលប់ចំពោះកូន ។ កូនគ្រប់រូបត្រូវមានឥរិយាបថល្អប្រពៃចំពោះពួកគាត់ ។ ពេលឪពុកម្ដាយហៅ កូនត្រូវឆ្លើយបាទ ឬចាសហើយមកជិតចាំស្ដាប់គាត់មានប្រសាសន៍ដោយយកចិត្តទុកដាក់ និងដោយទឹកមុខញញឹម ។ ពេលឪពុកម្ដាយប្រើបន្តិចបន្តួច ត្រូវរូតរះធ្វើដោយប្រញាប់ មិនត្រូវរត់គេច ឬធ្វើឫកពាមិនពេញចិត្តនោះឡើយ ។ លើសពីនេះទៀត កូនមិនត្រូវមានចរិតរឹងរូស មិនស្ដាប់ដំបូន្មានឪពុកម្ដាយនោះទេ ។

កូនត្រូវជម្រាបលាឪពុកម្ដាយពេលចេញទៅសាលារៀន និងជម្រាបសួរគាត់ពេលត្រឡប់មកពីសាលារៀនវិញ ដោយពោលពាក្យ ពុក ម៉ែ ឬប៉ា ម៉ាក់! កូនទៅរៀនហើយ ឬកូនមកពីរៀនវិញហើយ ។ បើចង់ទៅណាមកណា ត្រូវជម្រាបគាត់ឱ្យបានសមរម្យថា យើងទៅណា ទៅជាមួយអ្នកណា ទៅធ្វើអ្វី ពេលណាត្រឡប់វិញ ។ម្យ៉ាងទៀត កូនត្រូវចៀសវាងការនិយាយកុហកឪពុកម្ដាយ ។

ប្រសិនបើកូនគ្រប់រូប ប្រកាន់ខ្ជាប់នូវអាកប្បកិរិយាទាំងនេះ សេចក្ដីថ្លៃថ្នូរនឹងកើតមានដល់ខ្លួនអ្នក និងគ្រួសារអ្នក ។ លើសពីនេះ អ្នកនឹងមានអនាគតល្អ ហើយគ្រួសារនឹងជួបតែសុភមង្គលមិនខានឡើយ ។

## សំណួរ

១. ពេលឪពុកម្ដាយហៅ តើកូនត្រូវឆ្លើយដូចម្ដេច ?

២. ពេលឪពុកម្ដាយនិយាយ តើកូនត្រូវធ្វើដូចម្ដេច ?



www.elibraryofcambodia.org

៣. តើកូនត្រូវចៀសវាងអ្វីខ្លះ ?

៤. មុនពេលទៅ និងត្រឡប់ពីសាលារៀនវិញ តើកូនត្រូវធ្វើ និងនិយាយដូចម្ដេ

៥. តើកូនត្រូវធ្វើដូចម្ដេច បើចង់ទៅណាមកណា ?

## លំហាត់

ចូរប្រើបទានុក្រម ដើម្បីមើលសូរអាន និងពន្យល់ន័យនៃពាក្យខាងក្រោម ។

| | | | | | |
|---|---|---|---|---|---|
| ឥរិយាបថ | គុណ | ប្រសាសន៍ | ពាក្យពេចន៍ | ឫកពា | អាកប្បកិរិយា |

## កថាខណ្ឌ

### ក. បញ្ញត្តិកថាខណ្ឌ

កថាខណ្ឌ គឺជាល្បះមួយចំនួន ដែលសរសេរអំពីប្រធានបទមួយ ឬល្បះមួយក្រុ ដែលមានទំនាក់ទំនងគ្នា ហើយនិយាយអំពីគោលគំនិតណាមួយ ។

ការចាប់ផ្ដើមបន្ទាត់ គឺជាការចាប់ផ្ដើមនៃកថាខណ្ឌ ។

### ខ. គោលសំខាន់ៗនៃទម្រង់កថាខណ្ឌ

កថាខណ្ឌល្អមានលក្ខណៈដូចខាងក្រោម ៖

១. មានការណែនាំខាងដើម ដែលផ្ដោតទៅលើប្រធានបទ ។

២. ល្បះទាំងអស់ក្នុងកថាខណ្ឌ ត្រូវបង្ហាញពីគំនិតមួយ ឬប្រធានបទមួយ ។

៣. គំនិត មានទំនាក់ទំនងគ្នា តាមលំដាប់លំដោយ ។ ល្បះនីមួយៗ ត្រូវតភ្ជាប់គ្នា ដោយពាក្យភ្ជាប់សេចក្ដី ។

៤. ផ្ដល់សេចក្ដីលម្អិតគ្រប់គ្រាន់ ដើម្បីគាំទ្រគំនិតសំខាន់ ។

៥. ល្បះនីមួយៗត្រឹមត្រូវ តាមក្បួនវេយ្យាករណ៍ ។

៦. ប្រើទម្រង់ល្បះផ្សេងៗ ក្នុងការពណ៌នា ។

៧. ការបញ្ចប់ ឬសេចក្ដីសន្និដ្ឋាន ជាល្បះចុងក្រោយរបស់កថាខណ្ឌ ។



www.elibraryofcambodia.org

## ហាត់

ចូរស្រង់ល្បះខាងក្រោម រួចដាក់លេខតាមលំដាប់គំនិត ។ បន្ទាប់មក សរសេរល្បះ
នេះតគ្នាជាកថាខណ្ឌត្រឹមត្រូវ ។

កូនត្រូវគោរពស្រឡាញ់គាត់ ។

បើគាត់ហៅ កូនត្រូវឆ្លើយបាទ ឬ ចាសហើយរត់មកជិតដោយទឹកមុខញញឹម ។

កូនត្រូវប្រុងចាំស្ដាប់ប្រសាសន៍គាត់ ដោយយកចិត្តទុកដាក់ ។

មិនតែប៉ុណ្ណោះកូនល្អ ត្រូវប្រើសម្ដីទន់ភ្លន់ជានិច្ចទៅកាន់មាតាបិតា ។

កុមារគ្រប់រូបត្រូវប្រតិបត្តិដូចខាងលើ ដើម្បីឱ្យឪពុកម្ដាយអ្នកសប្បាយចិត្ត ។

ឪពុកម្ដាយជាអ្នកមានគុណ ។

## រឿង សេដ្ឋីនិងអ្នកលក់ធ្យូង



បន្ទាប់ពីស្ដាប់រឿង ចូរឆ្លើយនឹងសំណួរខាងក្រោម ។

១. តើគីមនិងវាសនាឈ្លោះគ្នារឿងអ្វី ?

២. តើវាសនាបានតិះដៀលគីមដូចម្ដេចខ្លះ ?

៣. តើឪពុកគីមធ្វើដូចម្ដេចខ្លះ ?

៤. ហេតុអ្វីបានជាឪពុកវាសនា ប្រាប់វាសនាឱ្យសុំទោសគីម ?

៥. តើរឿងនេះ ចង់អប់រំដូចម្ដេច ?



www.elibraryofcambodia.org

លំហាត់

ក. ចូរសរសេរអក្សរ "ត" នៅមុខចម្លើយត្រូវនឹងព្រឹត្តិការណ៍នៃរឿង ហើយសរសេរអក្សរ "ខ" នៅមុខចម្លើយ ដែលមិនមែនជាព្រឹត្តិការណ៍ខាងលើ ។

................ វាសនា និងគីមឈ្លោះគ្នាដណ្ដើមសៀវភៅ ។

................ វាសនា និងគីមក្លាយជាមិត្តនឹងគ្នា ។

................ ឪពុកវាសនា និងឪពុកគីមឈ្លោះប្រកែកគ្នា ។

................ លោកគ្រូឱ្យសេដ្ឋី សុំអភ័យទោសអ្នកលក់ធ្យូង ។

................ ឪពុកវាសនាមកប្ដឹងលោកគ្រូ ។

................ វាសនាសុំទោសគីម តាមការណែនាំរបស់ឪពុក ។

ខ. ចូរគូសសញ្ញា ✓ នៅមុខចម្លើយមួយ ដែលបង្ហាញភាពប្រែប្រួលនៃដំណើររឿង ។

☐ ១. រឿងនេះ បង្ហាញពីការឈ្លោះប្រកែកគ្នារវាងវាសនានិងគីម ។

☐ ២. រឿងនេះ បង្ហាញពីការសម្រុះសម្រួលរបស់លោកគ្រូ ។

☐ ៣. រឿងនេះ បង្ហាញពីតួអង្គទំនាស់ក្លាយជាមិត្តនឹងគ្នា ។

## ដំណើររឿង និងព្រឹត្តិការណ៍សំខាន់ៗនៃរឿង

រឿងមួយ តែងមានព្រឹត្តិការណ៍បន្តបន្ទាប់គ្នា ។ ព្រឹត្តិការណ៍ទាំងអស់ បង្កើតបានជាដំណើររឿង ។ ព្រឹត្តិការណ៍សំខាន់ៗនៃរឿង កើតឡើងពីបណ្ដុំព្រឹត្តិការណ៍បន្ទាប់បន្សំរួមបញ្ចូលគ្នា ។

ចូរអានរឿងខាងក្រោម ។ តើរឿងនេះ មានដំណើររឿង និងព្រឹត្តិការណ៍សំខាន់ៗនៃរឿងដូចម្ដេចខ្លះ ?



www.elibraryofcambodia.org

# រឿង ខ្លានិងកណ្តុរ

ថ្ងៃមួយ ខ្លាដើរស្វែងរកអាហារ ប្រទះនិងកណ្តុរកំពុងដេកលក់ ។ ខ្លាបានចាប់កណ្តុរប្រុងនិងត្របាក់ស៊ី តែកណ្តុរអង្វរ ៖ " សូមលោកកុំពិសាខ្ញុំអី ខ្ញុំតូចណាស់ ! បើលោកពិសាខ្ញុំ ខ្លួនខ្ញុំមិនបានមួយម៉ាត់ផង ! ហើយបើលោកទុកជីវិតខ្ញុំវិញ ខ្ញុំនិងដឹងគុណលោកអស់មួយជីវិត " ។ គាប់ជួនពេលនោះ ខ្លាពុំសូវឃ្លានអាហារ ក៏ធ្វើតាមការអង្វររបស់កណ្តុរ ។ ថ្ងៃក្រោយមក ខ្លាដើរស្វែងរកចំណីដូចធម្មតា ក៏ទៅជាប់អន្ទាក់ព្រាន ។ ខ្លាស្រែកឮសន្ធឹកពេញព្រៃ ។ កណ្តុរឮសំឡេងខ្លា ក៏រត់មករកមើល ។ វាស្គាល់ច្បាស់ជាខ្លាដែលទុកជីវិតវាពីថ្ងៃមុន ។ ជាការតបស្នងសងគុណវិញ កណ្តុរខំប្រឹងកកេរកាត់ខ្សែអន្ទាក់ទាល់តែដាច់រំបូតខ្លារួចជីវិតទៅ ។

(ដកស្រង់និងកែសម្រួលពីសៀវភៅរឿងនិទានថ្នាក់ទី១ ទំព័រទី១៨ បោះពុម្ពឆ្នាំ១៩៧៩)

ក្នុងដំណើររឿងនេះ មានព្រឹត្តិការណ៍សំខាន់ៗបី ៖

១. ខ្លាបម្រុងស៊ីកណ្តុរ តែដោយកណ្តុរអង្វរក៏លែងកណ្តុរវិញ ។

២. ខ្លាជាប់អន្ទាក់ព្រាន ។

៣. កណ្តុរជួយខ្លាឱ្យរួចជីវិត ។

ដំណើររឿង គឺជាលំដាប់លំដោយព្រឹត្តិការណ៍ក្នុងរឿងតាំងពីដើមដល់ចប់ ។ ព្រឹត្តិការណ៍សំខាន់ៗ គឺជាបណ្តុំព្រឹត្តិការណ៍បន្ទាប់បន្សំនៅក្នុងរឿងមួយ ។

## លំហាត់

ចូរអានរឿង រួចរកព្រឹត្តិការណ៍សំខាន់ៗដែលបង្កើតបានជាដំណើររឿង ។

### រឿង បងប្អូនបីនាក់

កាលពីព្រេងនាយមានបុរសម្នាក់មានកូនបីនាក់ ។ កាលបើដឹងថា ខ្លួនជិតស្លាប់ហើយ ក៏ហៅកូនទាំងបីមកជិត រួចនិយាយ ៖ " នែ៎កូនទាំងបី ! ឪពុកបានបង្ហាត់បង្រៀនណោះវិជ្ជាសព្វគ្រប់ល្មមរក្សាខ្លួនបានហើយ ។ ប៉ុន្តែឪពុកផ្តាំកូនជាចុងក្រោយ ត្រូវចេះស្រឡាញ់រួបរួមគ្នាកុំឈ្លោះប្រកែកបែកសាមគ្គីគ្នា " ។



www.elibraryofcambodia.org

គាត់បានប្រើឱ្យកូនច្បង ទៅយកអំពៅមួយដើមមកកាច់ ។ កូនច្បងកាច់អំពៅនេះ បាក់ជាពីរកំណាត់ ។ ឃើញអំពៅបាក់ គាត់បានបង្គាប់កូនបន្ទាប់យកអំពៅបីដើមមកចង ជាបាច់កាច់ឱ្យបាក់ ។ កូនបន្ទាប់ កាច់អំពៅមិនបាក់សោះ ។ ឃើញដូច្នេះ ឪពុកពោល ទៅកាន់កូន ៖ "ខ្លួនកូនបីនាក់ ប្រៀបដូចអំពៅបីដើមនេះ ។ បើពួកឯងចងសាមគ្គីគ្នានោះ ពិតជាបានសុខ និងបានជ័យជម្នះលើការងារគ្រប់មុខ " ។ កូនទាំងបីធ្វើតាមដំបូន្មាន ឪពុក បានសេចក្ដីសុខដរាបរៀងទៅ ។

(ដកស្រង់និងកែសម្រួលពីសៀវភៅរឿងនិទានថ្នាក់ទី១ ទំព័រទី៦៩ បោះពុម្ពឆ្នាំ១៩៧៩)

## អព្ភន្តរសញ្ញា ឬសញ្ញាក្បៀសបើកបិទ "..." ឬ « ... »

ចូរស្វែងយល់ការប្រើប្រាស់អព្ភន្តរសញ្ញា នៅក្នុងឧទាហរណ៍ខាងក្រោម ៖

១. ជីតាខ្ញុំមានប្រសាសន៍ ៖ "ក្មេងៗពេលជួបចាស់ទុំ ត្រូវគោរព និងលើកដៃសំពះ ទើបប្រពៃ" ។

២. ក្រុមង៉ុយបានលើកឡើងថា "ឃើញឫកគេល្អ ទោះបីមានក្រ យកគេជាញាតិ" ។

៣. «ថោកអីនិងដៃ ថ្លៃអីនឹងមាត់» ជាសុភាសិតខ្មែរ ។

៤. អត្ថបទនេះ ស្រង់ចេញពីសៀវភៅ " ប្រជុំរឿងព្រេងខ្មែរ ភាគ៥ " ។

៥. យើងកំពុងសិក្សាអំពី "សញ្ញាក្បៀសបើកបិទ ឬអព្ភន្តរសញ្ញា" ។

ពាក្យ ឃ្លា ល្បះ ក្នុងសញ្ញាក្បៀសបើកបិទនៃឧទាហរណ៍ខាងលើបញ្ជាក់អំពី ៖

- សម្ដីផ្ទាល់របស់អ្នកនិយាយ (ឧទាហរណ៍ទី១)
- សេចក្ដីដកស្រង់ពីបណ្ដាំ (ឧទាហរណ៍ទី២)
- ពាក្យ ឬសេចក្ដីដែលគេចង់បញ្ជាក់ (ឧទាហរណ៍ទី៣)
- ឈ្មោះសៀវភៅ (ឧទាហរណ៍ទី៤)
- ឈ្មោះវត្ថុ (ឧទាហរណ៍ទី៥)

សញ្ញាក្បៀសបើកបិទសម្រាប់ដាក់អមពាក្យ ឃ្លា ឬល្បះ ដើម្បីពន្លេចឡើងនូវ ឈ្មោះ មនុស្ស សត្វ ឬវត្ថុអ្វីមួយដែលសំខាន់ ឬសម្ដីផ្ទាល់របស់អ្នកនិយាយ ។



www.elibraryofcambodia.org

**កំណត់សម្គាល់** ៖ កាលណាក្បៀសបើកបិទប្រើអមសម្ដីផ្ទាល់ របស់អ្នកនិយាយគេប្រើសញ្ញា “ ៖ ” នៅខាងមុខ (មើលឧទាហរណ៍ទី១) ។

## លំហាត់

**ក. ចូរប្រើសញ្ញាក្បៀសបើកបិទនៅក្នុងល្បះខាងក្រោម ឱ្យបានត្រឹមត្រូវតាមកន្លែង ។**

១. អ្នកគ្រូនិយាយទៅកាន់សិស្ស ពេលទៅផ្ទះអ្នកត្រូវជម្រាបសួរអ្នកមានគុណ ។

២. នៅក្នុងរឿងកុលាបប៉ៃលិន តាចឹមផ្ដាំចៅចិត្រ ខ្លួនទីពឹងខ្លួន ។

៣. រឿងនេះ ដកស្រង់ចេញពី គតិលោកភាគទី១ ។

៤. សុភាសិតខ្មែរចែងថា លួចគេវាគ្រាន់ គេទាន់វាក្រែល ។

**ខ. ចូរតែងល្បះដោយប្រើអព្ភន្តរសញ្ញា ឬក្បៀសបើកបិទឱ្យបានបីល្បះ ។**



## កំណាព្យ : ច្បាប់ប្រុស

ច្បាប់ប្រុស ជាច្បាប់មួយប្រដៅកូនចៅឱ្យប្រកាន់កិរិយាល្អប្រពៃគ្រប់ពេលវេលា ។ ចូរអានច្បាប់នេះ រួចឆ្លើយនឹងសំណួរខាងក្រោម ។

### បទព្រហ្មគីតិ

រៀនបទរៀនបាទចាស　　កុំប្រឡាសលើរៀមច្បង
ស្រដីនឹងអ្នកផង　　ពាក្យឱ្យគួរកុំឯងអ៊ី ។
អឺ អើអញដាច់សាច់　　ឆ្លងពាក្យពេចន៍គេស្រដី
ដើមដៀលឱ្យអប្រិយ　　ស្រដីថា កូនអត់ពូជ ។
ចាស់ទុំមិនប្រដៅ　　ជេរកូនចៅទើបវាខូច
គេថាកូនអត់ពូជ　　មិនដឹងច្បាប់នឹងចាស់ទុំ ។
គេដៀលដល់ម៉ែឪ　　កេរ្តិ៍អាស្រូវស្អុយរហ៊ុម
គេស្ដីដើមដៀរជុំ　　ដំណៀលនោះមកដល់ចាស់ ។

( ដកស្រង់ចេញពីច្បាប់ប្រុសរបស់បណ្ឌិត ម៉ឺន មៃ )



www.elibraryofcambodia.org

## សំណួរ

១. តើច្បាប់នេះអប់រំអ្នកណា ?

២. តើច្បាប់នេះអប់រំកូនឱ្យធ្វើដូចម្ដេច ?

៣. កាលណាកូននិយាយស្ដីមិនសមរម្យ គេដៀលថាដូចម្ដេច ?

៤. កាលណាកូនមិនចេះគួរសម គេដៀលដល់អ្នកណា ?

## លំហាត់

**ក. ចូរពន្យល់ន័យរបស់ពាក្យខាងក្រោម ។**

| ច្រឡាស | កេរ្ដិ៍អាស្រូវ | ដំណៀល |
|---|---|---|

**ខ. ចូររកពាក្យចួននឹងពាក្យខាងក្រោម ។**

វគ្គទី១ ៖ ចាស ច្បង

វគ្គទី២ ៖ សាច់ ស្រដី

វគ្គទី៣ ៖ ប្រដៅ ខូច

វគ្គទី៤ ៖ ឪ រហ៊ុម

## សំណេរកថាខណ្ឌ

ដើម្បីសរសេរកថាខណ្ឌ គេត្រូវអនុវត្តតាមលំនាំនីមួយៗដូចខាងក្រោម ។

**១. ការប្រមូលគំនិត ៖** ការប្រមូលគំនិត គឺជាដំណាក់កាលដំបូងនៃការត្រៀមគំនិត ។ មុននឹងសរសេរប្រធានបទអ្វីមួយ អ្នកត្រូវប្រមូលព័ត៌មាន ឬគំនិតដែលទាក់ទ នឹងប្រធានបទនោះ ។ អ្នកត្រូវសរសេរគំនិតទាំងនោះ ក្នុងក្រដាសព្រាង ។ គំនិតទាំ នោះ ពុំទាន់មានលំដាប់លំដោយទេ ។

**២. សំណេរព្រាង ៖** កាលបើប្រមូលគំនិតបានហើយ អ្នកត្រូវជ្រើសរើសយកតែគំនិតណាដែលទាក់ទងនឹងប្រធានបទ ដែលអ្នកត្រូវសរសេរតែប៉ុណ្ណោះ គំនិតមិនទា ទងអ្នកត្រូវគូសចោល ។ បន្ទាប់មក អ្នកត្រូវរៀបចំគំនិតទាំងនោះតាមលំដាប់លំដោ បន្តមកទៀត អ្នកត្រូវចាប់ផ្ដើមសរសេរពង្រីកគំនិតនីមួយៗជាល្បះពេញលេញ ។



www.elibraryofcambodia.org

៣. កំណែលម្អ ៖ អ្នកត្រូវពិនិត្យសំណេរព្រាង ឱ្យបានគ្រប់ជ្រុងជ្រោយ ។

បន្ទាប់មក អ្នកត្រូវប្តូរសំណេរព្រាងរបស់អ្នកជាមួយមិត្តភក្តិ ដើម្បីជួយពិនិត្យកែលម្អគ្នាទៅវិញទៅមក ។ កំណែលម្អត្រូវផ្តោតទៅលើភាពគ្រប់គ្រាន់ ភាពត្រឹមត្រូវនៃគំនិត លំដាប់លំដោយគំនិត ទម្រង់ល្បះ និងអក្ខរាវិរុទ្ធ ។

៤. សំណេរសម្រេច ៖ អ្នកត្រូវសរសេរកិច្ចការរបស់ខ្លួនឡើងវិញ ឱ្យបានត្រឹមត្រូវ ។

## លំហាត់

ចូរពិនិត្យកថាខណ្ឌគំរូខាងក្រោម ។

នៅលើសកលលោក ពេលជួបគ្នា ឬលាគ្នា មនុស្សយើងតែងមានទម្លាប់សម្តែងការគួរសមចំពោះគ្នា ។ ប៉ុន្តែការគួរសមនេះ មានច្រើនបែប ប្លែកតាមជនជាតិនីមួយៗ ។ នៅអឺរ៉ុប គេសម្តែងការគួរសមដោយនិយមចាប់រលាក់ដៃគ្នា ។ ជនជាតិនៅអាស៊ីខ្លះ ជាពិសេសជាតិសាសន៍ខ្មែរ គេសម្តែងការគួរសមដោយឱនក្បាលបន្តិច រួចលើកដៃសំពះ ។ យើងត្រូវចេះសម្តែងការគួរសម ចំពោះអ្នកផងទាំងពួងទៅតាមទីកន្លែង និងតាមកាលៈទេសៈ ដើម្បីឱ្យបានជាមនុស្សថ្លៃថ្នូរ ។

ចូររៀបចំ រួចសរសេរព្រាងកថាខណ្ឌខ្លីមួយ ដែលមាន ៣-៥ ល្បះទាក់ទងនឹងប្រធានបទ ឬចំណងជើងណាមួយខាងក្រោម ដែលអ្នកពេញចិត្ត ។

ការគួរសមចំពោះភ្ញៀវ ការគោរពគ្រូ ការគោរពឪពុកម្តាយ ។

ចូរពិនិត្យកថាខណ្ឌរបស់អ្នកឡើងវិញ បន្ទាប់ពីសរសេររួចដោយផ្អែកលើសំណួរខាងក្រោម ។

១. តើអ្នកបានសរសេរចំណងជើងកថាខណ្ឌរបស់អ្នកហើយ ឬនៅ ?

២. តើល្បះទីមួយ អ្នកចាប់ផ្តើមបន្ទាត់ហើយ ឬនៅ ?

៣. តើអ្នកសរសេរពាក្យទាំងអស់ត្រឹមត្រូវហើយ ឬនៅ ?

៤. តើល្បះទាំងអស់និយាយទាក់ទងនឹងប្រធានបទហើយ ឬនៅ ?

៥. តើគំនិតនៅតាមលំដាប់លំដោយហើយ ឬនៅ ?



www.elibraryofcambodia.org

# រឿង កុមារចេះគួរសម

ចូរអានរឿង រួចឆ្លើយនឹងសំណួរខាងក្រោម ។



វេលារសៀលនៃថ្ងៃអាទិត្យមួយ កុមារីគន្ធាបានឮអាពាលព្រុសវ៉ូស! វ៉ូស! នាងដឹងច្បាស់ថា មានភ្ញៀវមករកនៅខាងក្រៅ ។ គន្ធាប្រញាប់ចាប់ឆ្កែចង រួចដើរទៅបើកទ្វារ ។ ពេលនោះ បុរសចំណាស់ម្នាក់សួរគន្ធាមុន ៖ “ពុកម៉ែរបស់ក្មួយនៅ ឬទេ ?” ។គន្ធាលើកដៃសំពះគាត់ ព្រមទាំងឆ្លើយដោយទន់ភ្លន់៖ “ចាស លោកអ៊ំ ! ម៉ែខ្ញុំនៅក្នុងផ្ទះបាយ ចំណែកពុកកំពុងធ្វើរបងព័ទ្ធចម្ការខាងក្រោយ ។ សូមលោកអ៊ំអញ្ជើញចូលទៅក្នុងផ្ទះសិន ខ្ញុំនឹងជម្រាបគាត់” ។ គន្ធានាំភ្ញៀវអង្គុយកន្លែងដ៏គួរសម រួចនាងចូលទៅក្នុងផ្ទះចាក់ទឹកមួយកែវយកមកជូនភ្ញៀវ និងនិយាយដោយទឹកមុខញញឹម៖ “លោកអ៊ំ! អញ្ជើញពិសាទឹក” ។ ភ្ញៀវនោះតបវិញ “អរគុណក្មួយ” ។ បន្ទាប់មក គន្ធាថយទៅជម្រាបឪពុកម្ដាយ ។

ពេលឪពុកម្ដាយកំពុងសន្ទនាជាមួយភ្ញៀវ ប្អូនប្រុសនាងម្នាក់រត់រឹងបម្រុងទៅរកឪពុកម្ដាយ ស្រាប់តែឃើញឪពុកម្ដាយមានភ្ញៀវ ក៏ឱនក្បាលគោរពបន្តិច រួចត្រឡប់ថយក្រោយវិញ ។ គន្ធាទៅជិតនិយាយខ្សឹបប្រាប់ប្អូន ៖ “អូនឯងកុំរត់កាត់មុខភ្ញៀវ ឬទៅរំខានពុកម៉ែមិនគួរសមទេ” ។

ពេលភ្ញៀវត្រឡប់ទៅផ្ទះវិញ ឪពុកម្ដាយគន្ធាសរសើរកូនស្រីដោយពេញចិត្ត ៖ “ កូនចេះគួរសមចំពោះភ្ញៀវណាស់! ចូរកូនរក្សាការគួរសម ចំពោះអ្នកដទៃឱ្យបានជាប់ជានិច្ច” ។



www.elibraryofcambodia.org

## សំណួរ

១. តើគន្ធាបានធ្វើអ្វីខ្លះ ចំពោះភ្ញៀវមុននឹងទៅជម្រាបឪពុកម្ដាយ ?

២. ពេលឪពុកម្ដាយកំពុងនិយាយជាមួយភ្ញៀវ តើមានអ្វីកើតឡើង ?

៣. ហេតុអ្វីបានជាឪពុកម្ដាយពោលសរសើរគន្ធា ?

៤. តើអ្នកចង់យកតម្រាប់តាមកុមារីគន្ធាដែរ ឬទេ ? ហេតុអ្វី ?

៥. តើរឿងនេះ កើតនៅកន្លែងណា ? ពេលណា ?

៦. តើរឿងនេះ មានព្រឹត្តិការណ៍សំខាន់ៗប៉ុន្មាន ? ចូររៀបរាប់ ។

## លំហាត់

ក. ចូរពន្យល់ពាក្យខាងក្រោមដោយប្រើវចនានុក្រម ។

| | | | | |
|---|---|---|---|---|
| វេលា | ទន់ភ្លន់ | សន្ទនា | រីង | រក្សា |

ខ. ចូរស្រង់ឃ្លា ដែលប្រើសញ្ញាឃ្លៀសបើកបិទពីក្នុងអត្ថបទខាងលើ ។

## សំណេរ

ចូរសរសេរកថាខណ្ឌខ្លីមួយ ដែលមាន ៣ ឃ្លាទាក់ទងនឹងរូបភាពខាងក្រោម ។





www.elibraryofcambodia.org

# ការប្រើភាសាតាមកាលៈទេសៈ

ថ្ងៃអាទិត្យ ប៊ុននិងមិត្តភក្តិបានទៅរកទិញសៀវភៅនៅឯផ្សារ ។ ពួកគេបាន អ្នកគ្រូសោភា ។

ចូរអានការសន្ទនារវាងអ្នកទាំងនេះ ។

| | | |
|---|---|---|
| ប៊ុន | : | អេ! បងស្រីឈប់សិន! តើបងអញ្ជើញទិញអ្វីហ្នឹង ? |
| អ្នកគ្រូ | : | អូ! ប៊ុន បងទើបទិញបានស្បែកជើងមួយគូ ។ តើពួកឯងមករកអ្វីដែរ ? |
| ប៊ុន | : | ខ្ញុំមកទិញសៀវភៅ ។ ខ្ញុំសូមលាបងសិនហើយ ។ |
| រីកា | : | អេ! ប៊ុន ម្ដេចក៏ឯងហៅគាត់អ៊ីចឹង ? គាត់ជាអ្នកគ្រូយើងណា៎! |
| ប៊ុន | : | ត្រូវហើយ! នៅសាលាគាត់ជាគ្រូយើង ខ្ញុំហៅគាត់អ្នកគ្រូ ។ នៅផ្សារខ្ញុំហៅ គាត់ថាបងស្រី ពីព្រោះគាត់ជាបងស្រីជីដូនមួយខ្ញុំ ។ |
| រីកា | : | អូ! អ៊ីចឹងទេឬ! ខ្ញុំខំតែឆ្ងល់ ។ |
| សុត | : | មែនហើយ! នេះមានន័យថា យើងត្រូវចេះនិយាយឱ្យបានត្រឹមត្រូវតាម កាលៈទេសៈ ។ |

## សំណួរ

១. តើប៊ុននិងមិត្តភក្តិ ជួបអ្នកគ្រូរបស់គេនៅឯណា ?

២. តើនៅផ្សារ ប៊ុនហៅអ្នកគ្រូដូចម្ដេច ?

៣. ហេតុអ្វីបានជាប៊ុនហៅអ្នកគ្រូថា បងស្រី ?

៤. តើនៅសាលា ប៊ុនហៅអ្នកគ្រូដូចម្ដេច ? ហេតុអ្វី ?

## លំហាត់

ពូរបស់អ្នក ជាគ្រូកីឡា ។ ថ្ងៃនេះ គាត់ចង់ឱ្យអ្នកទៅប្រាប់សិស្សរួមថ្នាក់របស់អ្នកឱ *ទៅហាត់ប្រាណ នៅម៉ោងក្រោយ ។ ចូរអ្នកចាប់គូដើម្បីសន្ទនារឿងនេះ ដោយប្រើគំនិ* ផ្ទាល់ខ្លួន ។



www.elibraryofcambodia.org

# ការសរសេររឿងខ្លី

ចូរអានរឿងម្ជុលបារាំង រួចឆ្លើយនឹងសំណួរ ។

កាលពីដើម មានយុវជនម្នាក់ឈ្មោះ កំសាន្ត កំព្រាឪពុកតាំងពីតូច ។ កំសាន្ត ខិតខំតស៊ូពុះពារការលំបាកគ្រប់បែបយ៉ាង រហូតបានបញ្ចប់ការសិក្សាផ្នែកធនាគារ ។

ថ្ងៃមួយ កំសាន្តបានទៅដាក់ពាក្យសុំចូលធ្វើការនៅធនាគារមួយ ។ ពេលទៅដល់ កំសាន្តលើកដៃសំពះដោយសុភាព រួចហុចពាក្យសុំចូលធ្វើការទៅលោកនាយកធនាគារ ។ លោកនាយកពិនិត្យមើលរួចហុចពាក្យនោះឱ្យមកកំសាន្តវិញ ព្រមទាំងប្រាប់ថា លោកស្តាយណាស់ដោយនៅពេលនេះ មានបុគ្គលិកគ្រប់គ្រាន់ហើយ បើលោកត្រូវការបុគ្គលិកបន្ថែមទៀត លោកនឹងឱ្យដំណឹង ។ កំសាន្ត ក៏សំពះលាត្រឡប់មកវិញ ។

ពេលកំពុងដើរត្រឡប់មកវិញ កំសាន្តឃើញម្ជុលបារាំងមួយ ក៏ឱនរើសទុក ។ ឃើញកាយវិការដូច្នេះ លោកនាយកគិតក្នុងចិត្ត ៖“យុវជននេះ មានសណ្តាប់ធ្នាប់ល្អ និងមានគំនិតចេះសន្សំសំចៃ” ។ លោកនាយក បានឱ្យកំសាន្តមកធ្វើការជាមួយគាត់ ។ មួយឆ្នាំបន្ទាប់ កំសាន្តត្រូវបានតែងតាំងជានាយករងធនាគារនោះទៅ ។

## សំណួរ

១. តើអ្នកណាជាតួអង្គឯក នៅក្នុងរឿងនេះ ?

២. តើរឿងនេះ មានព្រឹត្តិការណ៍សំខាន់ៗប៉ុន្មាន ? គឺអ្វីខ្លះ ?

៣. តើរឿងនេះ កើតនៅពេលណា ? នៅឯណា ?

## លំហាត់

ក. **ផ្អែកតាមគំរូខាងលើ ចូរអ្នករៀបចំសរសេររឿងខ្លីមួយ ដែលបង្កើតដោយខ្លួនឯង ។ មុននឹងសរសេរអ្នកត្រូវកំណត់ ៖**

- អ្នកណាជាតួអង្គឯកនៅក្នុងរឿង
- ព្រឹត្តិការណ៍សំខាន់មួយ ( តួអង្គបានធ្វើអ្វី ឬ ជួបហេតុការណ៍អ្វី )
- ទីកន្លែងនិងពេលវេលា ដែលរឿងបានកើតឡើង ។



www.elibraryofcambodia.org

១. ចូរអ្នកសរសេររឿងខ្លីមួយ តាមលំដាប់រូបភាពខាងក្រោម ។

# រឿង

១



២



៣



៤





www.elibraryofcambodia.org

មេរៀនទី ៤

# រុក្ខជាតិប្រទេសយើង



ប្រទេសកម្ពុជាយើង មានរុក្ខជាតិគ្រប់ប្រភេទ ។ រុក្ខជាតិខ្លះជាបន្លែ ខ្លះផ្ដល់ជាផ្លែ ខ្លះជារុក្ខជាតិបម្រើឱ្យឧស្សាហកម្ម ដែលយើងឱ្យឈ្មោះថា កសិឧស្សាហកម្ម ។ រីឯរុក្ខជាតិខ្លះទៀត យើងយកមកធ្វើជាឱសថបុរាណ សម្រាប់តែរោគផ្សេងៗ ។ រុក្ខជាតិទាំងអស់ផ្ដល់ប្រយោជន៍សំខាន់ណាស់ ដល់ជីវភាពរស់នៅរបស់ប្រជាជនទូទាំងប្រទេស ។



www.elibraryofcambodia.org

## រឿងពិត ឬពិតកថា

ចូរអ្នកអានកថាខណ្ឌខាងក្រោម ។ តើពិតកថា មានលក្ខណៈសម្គាល់ដូចម្ដេចខ្លះ

សម្ដេចសង្ឃរាជ ជួន ណាត ប្រសូតនៅថ្ងៃ១១រោច ខែផល្គុន ឆ្នាំវក ឆស័ក សករាជ ២៤២៧ត្រូវនឹងថ្ងៃទី១១ ខែមីនា ឆ្នាំ១៨៨៣ ។ លុះចម្រើនវ័យ១៤ឆ្នាំ លោបានបួសជាសាមណេរ នៅវត្តពោធិ៍ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ។ នៅឆ្នា១៨៩៩ លោកបាននិមន្តមកកាន់វត្តឧណ្ណាលោម ។ លោកបានរៀបរៀងវចនានុក្រមខ្មែតាំងពីឆ្នាំ១៩១៥ ហើយត្រូវបានបោះពុម្ពចុងក្រោយនៅឆ្នាំ១៩៦៧ ។

- ឈ្មោះសម្ដេចសង្ឃរាជ ជួន ណាត និងប្រវត្តិរបស់លោក ជារឿងពិត ។
- វចនានុក្រមខ្មែរ និងឆ្នាំរៀបរៀង បោះពុម្ព ជាការពិត ។

ដូច្នេះ កថាខណ្ឌខាងលើជាពិតកថា ឬរឿងពិត ។

> រឿងពិត ឬពិតកថាជាអត្ថបទសរសេរប្រាប់ពីមនុស្ស ទីកន្លែង ព្រឹត្តិការណ៍ពិត ដូចជាអត្ថបទទាក់ទងនឹងវិទ្យាសាស្ត្រ ហេតុការណ៍ប្រវត្តិសាស្ត្រ ឬប្រវត្តិផ្ទាល់ខ្លួន ។

## លំហាត់

ចូរអានកថាខណ្ឌខាងក្រោម រួចលើកចំណុចដែលបញ្ជាក់ថា អត្ថបទនេះជាពិតកថា ។

កាលពីថ្ងៃពុធ ទី២៧ សីហា ឆ្នាំ២០០៨ មន្ត្រីរដ្ឋបាលព្រៃឈើ ខេត្តកំពង់ចាមបានរុះរើក្បួនឬស្សីព្រៃមួយ ដែលចេញពីស្រុកសម្បូណ៌ ខេត្តក្រចេះទៅកាន់ឡូត៍លេខ៧ ស្ថិតនៅក្នុងស្រុកស្អាង ខេត្តកណ្ដាល ។ នៅពេលនោះ គេប្រទះឃើញឈ្នួញបង្កប់ឈើអាររួចប្រភេទឈើលេខ២ ទំហំ៥×១៥ចំនួន៤៦៥ម៉ែត្រគូប ។ ប៉ុន្តែ នៅក្នុងអាជ្ញាប័ណ្ណអនុញ្ញាតឱ្យនាំឬស្សីព្រៃចំនួន ២៨ ៨៣៤ដើម ។

(ដកស្រង់ពីកាសែតកោះសន្តិភាព ឆ្នាំ ២០០៨)



www.elibraryofcambodia.org

# ការផ្សព្វផ្សាយពីផលអាក្រក់នៃថ្នាំជក់

ចូរអានអត្ថបទខាងក្រោម រួចឆ្លើយនឹងសំណួរ ។



សេដ្ឋកិច្ចកម្ពុជា ពឹងផ្អែកលើវិស័យកសិកម្ម ។ អាស្រ័យហេតុនេះហើយ បានជារាជរដ្ឋាភិបាល យកចិត្តទុកដាក់យ៉ាងខ្លាំង លើការពង្រីកដំណាំឧស្សាហកម្មស្ទើរគ្រប់ទីកន្លែង ។ ក្រសួងកសិកម្ម ក៏បានយកចិត្តទុកដាក់ផ្សព្វផ្សាយ និងពន្យល់ដល់កសិករឱ្យទំដាំដំណាំផ្សេងៗ ដែលបម្រើឱ្យឧស្សាហកម្ម ។ ជាក់ស្តែង កាលពីចុងខែមិថុនា ឆ្នាំ ២០០៧កន្លងទៅនេះ បុគ្គលិកមន្ទីរកសិកម្ម ខេត្តកំពង់ចាម បានចុះទៅសួរសុខទុក្ខប្រជាជនក្នុងស្រុកក្រូចឆ្មារ ដែលនិយមដាំដំណាំថ្នាំជក់តាំងពីយូរណាស់មកហើយ ។ ជាមួយនេះដែរអស់លោកបានពន្យល់ពីផលអាក្រក់នៃការដាំថ្នាំជក់ ។ ពួកគាត់បានពន្យល់ថា ការដាំថ្នាំជក់ទាមទារពលកម្មខ្លាំង និងចំណាយប្រាក់ច្រើន សម្រាប់ទិញជី និងថ្នាំសម្លាប់សត្វល្អិត ចំណែកផលទទួលបានមិនចំណេញប៉ុន្មានឡើយ ។ម្យ៉ាងទៀត អ្នកដាំថ្នាំជក់រងគ្រោះថ្នាក់ក្នុងការងារជាច្រើន ដោយការប៉ះពាល់ថ្នាំសម្លាប់សត្វល្អិត និងការពុលដោយសារធាតុគីមីពុលនីកូទីន ។ កុមារនិងមនុស្សពេញវ័យ ច្រើនទទួលរងគ្រោះ



www.elibraryofcambodia.org

ដោយការជ្រាបចូលនៃនីកូទីនតាមស្បែក នៅពេលពួកគេប៉ះពាល់ស្លឹកថ្នាំជក់ ធ្វើឱ្យ ចង់ក្អួត ឈឺក្បាល ពិបាកដកដង្ហើម អស់កម្លាំង វិលមុខ ។ល ។ បន្ថែមលើនេះទៀត កសិករត្រូវកាប់បំផ្លាញព្រៃឈើយ៉ាងច្រើន ដើម្បីយកមកសម្ងួត និងចំហុយស្លឹកថ្នាំ ដែល ជាហេតុធ្វើឱ្យជាតិខាតបង់យ៉ាងច្រើន ។

នៅទីបញ្ចប់ គេបានណែនាំប្រជាកសិករឱ្យងាកមកដាំដំណាំកសិឧស្សាហកម្ម មាន ដំឡូង អំពៅ ល្ហុងខ្វង ស្វាយចន្ទីវិញ ព្រោះវាផ្តល់ប្រាក់ចំណូលច្រើនជាងការដាំថ្នាំជក់ ហើយមិនបង្កគ្រោះថ្នាក់ទៀតផង ។

## សំណួរ

១. តើអ្នកណា ចុះពន្យល់ប្រជាកសិករនៅស្រុកក្រូចឆ្មារ ?

២. តើបុគ្គលិកកសិកម្ម បានពន្យល់ពីផលអាក្រក់នៃថ្នាំជក់ដូចម្តេចខ្លះ ?

៣. តើគេចង់ឱ្យប្តូរពីដំណាំថ្នាំជក់ ទៅជាដំណាំអ្វីខ្លះ ? ហេតុអ្វី ?

## លំហាត់

ក. ចូរអានអត្ថបទឡើងវិញ រួចស្រង់ចំណុចដែលបញ្ជាក់ថា អត្ថបទនេះជាពិតកថា រឿងពិត ។

## នាមអសាធារណ៍

ចូរអានឧទាហរណ៍ដោយពិនិត្យពាក្យ ដែលមានគំនូសពីក្រោម ។

១. រតនាបេះផ្លែស្វាយខ្ចី ឯបុប្ផាញ៉ាំចេកពងមាន់ ។

២. ឪពុកខ្ញុំ កាប់ដើមពោតឱ្យអាត្មោតស៊ី ។

៣. មិត្តខ្ញុំចូលចិត្តទៅលេងគិរីរម្យ ។

៤. ទឹកជ្រោះប៊ូស្រា ស្ថិតនៅក្នុងខេត្តមណ្ឌលគិរី ។

៥. ក្រវាញជារុក្ខជាតិមួយ មានប្រយោជន៍ ។ គេយកផ្កាវាធ្វើថ្នាំកែរោគ ។



www.elibraryofcambodia.org

ពាក្យមានគំនូសពីក្រោម បញ្ជាក់ឈ្មោះមនុស្សម្នាក់ សត្វមួយ វត្ថុមួយ និងទីកន្លែងមួយ ច្បាស់លាស់ មិនទូទៅ ។ ពាក្យទាំងនេះ ជានាមអសាធារណ៍ ។

> នាមអសាធារណ៍ គឺជាពាក្យសម្គាល់មនុស្ស សត្វ វត្ថុ និងទីកន្លែងដោយចំពោះ មិនទូទៅ ។

## លំហាត់

ក. **ចូរចម្លងល្បះខាងក្រោម រួចគូសពីក្រោមពាក្យដែលជានាមអសាធារណ៍ ។**

១. អ្នកភូមិខ្ញុំ ប្រឡេះគ្រាប់ស្វាយចន្ទី ។

២. ពូព្រឹង គាបទឹកត្នោតធ្វើស្ករ ។

៣. តាសុខ ដឹកអាពាលទៅលាងទឹកត្រពាំង ។

៤. នៅខេត្តរតនគិរី មានចម្ការកាហ្វេច្រើន ។

៥. ឈើប្រណីតមាន បេង នាងនួន កកោះ ធ្នង់ ... ។

ខ. **ចូរអានកថាខណ្ឌខាងក្រោម រួចស្រង់នាមអសាធារណ៍នៅក្នុងអត្ថបទ ។**

ប្រទេសកម្ពុជាយើង មានដំណាំច្រើនប្រភេទណាស់ ។ នៅតំបន់ដីក្រហមដូចជា កំពង់ចាម មណ្ឌលគិរី រតនគិរី ប្រជាជននិយមដាំកៅស៊ូ ។ នៅតាមដងទន្លេមេគង្គ និងខេត្តមួយចំនួនទៀត គេនិយមដាំអំពៅ ច្រើនប្រភេទដូចជា អំពៅកែវ អំពៅក្ដាម អំពៅខ្មៅ អំពៅត្រែង និងអំពៅស្ករ ដើម្បីលក់ដូរ និងគាបយកទឹកធ្វើស្ករ ។ នៅខេត្តកំពតមានដំណាំទុរេន ដែលមានរសជាតិផ្អែមឈ្ងុយឆ្ងាញ់ ដាច់គេនៅប្រទេសយើង ។ ចំណែកឯខេត្តបាត់ដំបង សម្បូរក្រូចពោធិ៍សាត់ ដែលមានរសជាតិឆ្ងាញ់បំផុត ។ ខេត្តកំពង់ចាមសម្បូរចេក ដូង ម្នាស់ និងដំណាំផ្សេងៗទៀតជាច្រើន ។



www.elibraryofcambodia.org

## ៦ ការណែនាំអំពីរបៀបដាំផ្កា

ចូរស្តាប់ និងធ្វើតាមការណែនាំរបស់គ្រូអ្នកមួយដំណាក់ម្តងៗ ដោយមើលរូបភាខាងក្រោមជាជំនួយ ។




## ក ការប្រើចំណងជើងជំពូកដើម្បីរកព័ត៌មាន

ជួនកាលអ្នកត្រូវការរកព័ត៌មាន នៅក្នុងសៀវភៅ ប៉ុន្តែអ្នកមិនដឹងព័ត៌មាននោះស្ថិតនៅត្រង់ណា ហើយអ្នកត្រូវធ្វើដូចម្តេច ដើម្បីរកព័ត៌មាននោះឃើញ ។

ចូរអ្នកសិក្សាចំណងជើងជំពូក មេរៀន ក្នុងបញ្ជីអត្ថបទខាងក្រោម ។

### បញ្ជីអត្ថបទ

**ជំពូកទី១ ៖ ការសិក្សានិងការកម្សាន្តក្នុងសាលារៀន ........................... ១**

មេរៀនទី១ ៖ តម្លៃនៃការសិក្សា ........................................................ ២

បំណិន ៖ ផ្នែកនានានៃសៀវភៅមើល .................... ៥

វេយ្យាករណ៍ ៖ ល្បះនិងផ្នែកនៃល្បះ ........................... ៨

មេរៀនទី២ ៖ កីឡានិងល្បែងកម្សាន្តនៅសាលារៀន ............................ ១២

បំណិន ៖ ការប្រើបទានុក្រម ................................ ១៣

អំណាន ៖ ទិដ្ឋភាពល្បែងប្រណាំងកង់យឺត ............. ១៨



www.elibraryofcambodia.org

ជំពូកទី២ ៖ កន្លែងសំខាន់ៗនៅក្នុងសហគមន៍........................................៤៩

មេរៀនទី១ ៖ ស្ថាប័នសាធារណៈនៅក្នុងសហគមន៍........................................៥០

បំណិន ៖ ការពិតនិងមតិ........................................៥១

អំណាន ៖ សេចក្ដីសុខរបស់ប្រជាជន........................................៥២

ចូរអ្នកស្វែងរកព័ត៌មាន អំពីតួនាទីរបស់មន្ត្រីភូមិ ឃុំ ដោយប្រើចំណងជើងជំពូក មេរៀនខាងលើ ។

ព័ត៌មានអំពីតួនាទីរបស់ភូមិ ឃុំ ដែលអ្នកត្រូវការរកនៅក្នុងជំពូកទី ២ មេរៀនទី១ ត្រង់អំណាន " សេចក្ដីសុខរបស់ប្រជាជន" ព្រោះក្នុងខ្លឹមសារអំណាននេះនឹងនិយាយអំពីមន្ត្រីភូមិ ឃុំត្រូវធ្វើអ្វីខ្លះ ដើម្បីផ្ដល់សេចក្ដីសុខជូនប្រជាជន ។

**ដើម្បីរកព័ត៌មានអ្វីមួយ គេត្រូវ ៖**

១. មើលចំណងជើងជំពូក

២. មើលត្រួសៗចំណងជើងមេរៀន និងចំណងជើងតូចៗនៅក្នុងមេរៀន ដើម្បីរកព័ត៌មានដែលអ្នកត្រូវការ ។

៣. មើលលេខទំព័រដែលត្រូវនឹងព័ត៌មាននោះ ។

## លំហាត់

ចូរប្រើចំណងជើងមេរៀន នៅក្នុងសៀវភៅភាសាខ្មែរថ្នាក់ទី៤ (បញ្ជីអត្ថបទ)ដើម្បីរកមើលការអប់រំកូនប្រុស រួចរៀបរាប់ពីការអប់រំនោះ ។



## ភូមិពណ៌បៃតង

ចូរអានអត្ថបទខាងក្រោម រួចឆ្លើយនឹងសំណួរ ។

គ្រួសារសុភា រស់នៅតាមមាត់សមុទ្រ ។ នៅជុំវិញផ្ទះសុភា គ្មានដំណាំអ្វីបន្តិចបន្តួចឡើយ ។ ថ្ងៃមួយ គ្រូណែនាំសិស្សដែលមានលំនៅតាមមាត់សមុទ្រឱ្យដាំណាំនិងបន្លែផ្សេងៗ ។ សុភាព្រួយចិត្ត ក៏ពិគ្រោះជាមួយឪពុកម្ដាយ ។ ម្ដាយសុភាឱ្យយោបល់ ៖ " យើង



www.elibraryofcambodia.org

គួរលើករងដាំបន្លែនៅក្រោយផ្ទះ” ។ ឪពុកសុភាជំទាស់ ៖ “ កូនមិនអាចធ្វើរងដាំដំណាំបានទេ ព្រោះទឹកលិចដំណាំនឹងរលួយអស់ បើកូនចង់ដាំ កូនយកទូកចាស់របស់យើងនៅក្រោយផ្ទះមកធ្វើបង្គងដាក់វាឱ្យផុតពីទឹកប្រៃ រួចយកដី និងជីមកដាក់ក្នុងទូក កូនអាចដាំអ្វីៗតាមចំណង់” ។



ស្អែកឡើង ឪពុកសុភានិងសុភា នាំគ្នារកឈើមកកល់ទូក ។ ឯម្ដាយសុភា យកផើងមកដាក់ជីរួចដាក់លើធ្នើរ ។ បន្ទាប់មក គាត់យកគ្រាប់ពូជបន្លែមកកប់ក្នុងផើង ។ ឯសុភានិងប្អូនប្រុសយកកូនត្រប់ ម្ទេស ប៉េងប៉ោះ ជីរ ស្លឹកគ្រៃ មកដាំក្នុងទូក ។ ពីរខែក្រោយមកស្លឹកគ្រៃបែកគុម្ព ត្រប់ ប៉េងបោះ ម្ទេស ចេញផ្កា ផ្លែ គួរឱ្យចង់គយគន់ ។

សុភានិងគ្រួសាររីករាយយ៉ាងខ្លាំង ដោយឮពាក្យសរសើររបស់អ្នកភូមិ និងឃើញដំណាំជុំវិញផ្ទះមានពណ៌បៃតងស្រស់ ។ម្យ៉ាងទៀត ដំណាំទាំងនេះ អាចជួយផ្គត់ផ្គង់គ្រួសារសុភាបានមួយកម្រិតដែរ ។

## សំណួរ

១. តើសុភា មានគម្រោងចង់ធ្វើអ្វី ?

២. តើឪពុកម្ដាយសុភា ផ្ដល់យោបល់ដល់កូនដូចម្ដេចខ្លះ ?

៣. សុភានិងគ្រួសារ សម្រេចបំណងដែរ ឬទេ ?

៤. តើសុភាមានអារម្មណ៍ដូចម្ដេច ពេលឮពាក្យសរសើររបស់អ្នកភូមិ ?

៥. តើដំណាំទាំងនោះ អាចផ្គត់ផ្គង់គ្រួសារសុភាបានយ៉ាងដូចម្ដេច ?



www.elibraryofcambodia.org

## លំហាត់

ចូរប្រើចំណេះដឹងមេរៀន នៅក្នុងសៀវភៅភាសាខ្មែរថ្នាក់ទី៤ (បញ្ជីអត្ថបទ) ដើម្បីរកព័ត៌មាន អំពីប្រយោជន៍នៃទឹក ។ តើព័ត៌មាននេះ នៅក្នុងមេរៀនណា ? តើគេរៀបរាប់ដូចម្ដេចខ្លះ ?

## សំណេរ

ចូរសរសេរកថាខណ្ឌរៀបរាប់ពីផលប្រយោជន៍ នៃដើមត្នោតតាមសំណួរខាងក្រោម ។

១. តើដើមត្នោតមានរាងដូចម្ដេច ? តើមានពណ៌អ្វី ? រលោង ឬគគ្រើម ? កម្ពស់ប្រហែលប៉ុន្មានម៉ែត្រ ?

២. តើគេច្រើនដាំដើមត្នោតនៅឯណា ?

៣. តើដើមត្នោតធំៗផ្ដល់អ្វីខ្លះ ? ( ដើម ស្លឹក ធាង តាវ ផ្កា ផ្លែ )

៤. តើគេយកដើមត្នោតធ្វើអ្វីខ្លះ ? តើគេយក ស្លឹកត្នោត ធាង តាវ ផ្កា ផ្លែខ្ចី ទុំ ទឹកត្នោតធ្វើអ្វីខ្លះ ?

៥. តើអ្នកបន្តការដាំដើមត្នោតដែរ ឬទេ ? ព្រោះអ្វី ?





www.elibraryofcambodia.org

## ប្រធានបទរបស់កថាខណ្ឌ

អ្វីៗដែលអ្នកអាន ស្ទើរតែទាំងអស់ សុទ្ធតែកើតឡើងដោយល្បះមួយក្រុម ដែល គេហៅថា "កថាខណ្ឌ" ។ កថាខណ្ឌល្អ និយាយតែរឿងមួយប៉ុណ្ណោះ ។ រឿងដែល និយាយនៅក្នុងកថាខណ្ឌនោះមានឈ្មោះថា "ប្រធានបទរបស់កថាខណ្ឌ" ។

ចូរអ្នកសិក្សាកថាខណ្ឌខាងក្រោម ។ ល្បះនីមួយៗមានលេខសម្គាល់ ដើម្បីងាយ យល់ ។ នៅពេលអ្នកអាន ចូរអ្នកស្វែងយល់ថា តើល្បះទាំងអស់និយាយអំពីអ្វី ។

(១) ព្រៃឈើ មានប្រយោជន៍ច្រើនយ៉ាងណាស់ ។ (២) យើងយកឈើធ្វើជាគ្រឿង សំណង់ផ្សេងៗ ធ្វើគ្រឿងសង្ហារិម ធ្វើទូក កប៉ាល់... ។ (៣) ឈើខ្លះផ្ដល់ផ្លែ ផ្កា ស្លឹកឱ្យ យើងបរិភោគ ។ (៤) ឈើខ្លះទៀត អាចធ្វើជាឱសថព្យាបាលរោគ ។ (៥) មិនតែ ប៉ុណ្ណោះព្រៃឈើ ជាជម្រករបស់សត្វគ្រប់ប្រភេទ ។ (៦) លើសពីនេះទៅទៀត ព្រៃឈើ អាចទាក់ទាញទឹកភ្លៀង និងទប់ទឹកជំនន់បានទៀតផង ។

ល្បះនីមួយៗក្នុងកថាខណ្ឌខាងលើ និយាយអំពីប្រយោជន៍នៃព្រៃឈើ ។ ដូច្នេះ ប្រធានបទរបស់កថាខណ្ឌនេះគឺ "ប្រយោជន៍នៃព្រៃឈើ" ។

> ប្រធានបទរបស់កថាខណ្ឌ គឺអ្វីដែលល្បះនីមួយៗនៅក្នុងកថាខណ្ឌបាន និយាយ ។ ប្រធានបទរបស់កថាខណ្ឌ ជាកន្សោមពាក្យក្ដោបន័យរបស់កថាខណ្ឌទាំង មូល ។

### លំហាត់

ចូររកប្រធានបទរបស់កថាខណ្ឌខាងក្រោម ។ តើកថាខណ្ឌនេះនិយាយអំពីអ្វី ?

ឈូកជាដំណាំ ឱ្យផលកម្រៃយ៉ាងច្រើន ។ គេដាំឈូកនៅក្នុងបឹងនិងតាមវាលស្រែ ប្រដេញទឹក ។ គេអាចកាច់ស្លឹកឈូក ផ្កាឈូក ផ្លែឈូកខ្ចី និងទុំយកទៅលក់ ។ គេយក ក្រអីឈូក និងមើមឈូក ទៅធ្វើជាបន្លែយ៉ាងឆ្ងាញ់ពិសា ។ គេយកគ្រាប់ឈូកទុំ ទៅលីង ហូបមានរសជាតិឈ្ងុយឆ្ងាញ់ ។ គេយកមើមឈូកចាស់ៗទៅធ្វើម្សៅ ។ គេយកម្សៅឈូក ទៅធ្វើបង្អែម មានឱជារសណាស់ ។



www.elibraryofcambodia.org

# ដំណាំស្រូវ

ចូរអានអត្ថបទខាងក្រោម ។ តើអត្ថបទនេះនិយាយអំពីអ្វី ?



ដំណាំសំខាន់បំផុត នៅប្រទេសកម្ពុជាគឺស្រូវ ។ គេដាំស្រូវ ស្ទើរគ្រប់ទីកន្លែងទាំងអស់ ។ គេធ្វើស្រែពីរដងក្នុងមួយឆ្នាំ គឺស្រែវស្សា និងស្រែប្រាំង ។ ស្រែប្រាំង គេចាប់ធ្វើនៅពេលទឹកស្រក ។ គេធ្វើស្រូវប្រាំងនៅតាមមាត់បឹង ទំនាបទន្លេ មាត់ព្រែក ឬស្ទឹងដែលមានទឹកពុំដាច់ ។ ប្រជាជនមួយចំនួន ពិសេសប្រជាជននៅខេត្តបាត់ដំបង បន្ទាយមានជ័យចូលចិត្តដាំស្រូវផ្កាម្លិះ ផ្កាខ្ញី នាងអំ ផ្ការំដួល... ព្រោះស្រូវទាំងនេះមានឱជារសឆ្ងាញ់ពិសា ។

បច្ចុប្បន្ន វិស័យកសិកម្មកាន់តែអភិវឌ្ឍ ប្រជាកសិករច្រើនធ្វើស្រូវប្រពលវប្បកម្មនិងស្ទូងស្រូវមួយដើម តាមការណែនាំរបស់ក្រសួងកសិកម្ម ដើម្បីសន្សំសំចៃពូជ និងទទួលបានផលច្រើន ។ លើសពីនេះទៅទៀត កសិករបានទទួលការណែនាំឱ្យប្រើជីធម្មជាតិ និងជីកំប៉ុស ។ បច្ចុប្បន្ន កសិករមួយចំនួន បោះជំហានទៅប្រើគោយន្ត ដើម្បីភ្ជួរនិងប្រើម៉ាស៊ីនបូមទឹក ម៉ាស៊ីនបោកស្រូវជំនួសកម្លាំងគោក្របី ។ ពួកគាត់ទទួលផលបានច្រើន ធ្វើឱ្យជីវភាពពួកគាត់ធូរធារជាលំដាប់ ។



www.elibraryofcambodia.org

## សំណួរ

១. តើសេដ្ឋកិច្ចកម្ពុជាពឹងផ្អែកលើអ្វី ?

២. តើនៅប្រទេសកម្ពុជា គេធ្វើស្រូវប៉ុន្មានដងក្នុងមួយឆ្នាំ ?

៣. ហេតុអ្វីបានជាកសិករ ធ្វើស្រូវប្រពលវប្បកម្ម និងដាំស្រូវមួយដើម ?

៤. តើការប្រើជីធម្មជាតិ និងជីកំប៉ុសមានអត្ថប្រយោជន៍ដូចម្តេច ?

៥. តើកសិកម្មនៅកម្ពុជា មានការអភិវឌ្ឍដែរ ឬទេ ? ហេតុអ្វី ?

## លំហាត់

ក. ចូរស្រង់នាមអសាធារណ៍នៅក្នុងអត្ថបទ រួចពន្យល់របៀបប្រើនាមអសាធារណ៍ ។

ខ. ចូរអានអត្ថបទទាំងពីរកថាខណ្ឌរួចជ្រើសរើសប្រធានបទរបស់កថាខណ្ឌនីមួយៗ ។

កថាខណ្ឌទី១ ៖ ១. ការលំបាកក្នុងការធ្វើស្រូវប្រាំង
២. ពេលវេលា ទីកន្លែងសម្រាប់ធ្វើស្រូវប្រាំង
៣. របៀបថែស្រូវប្រាំង ។

កថាខណ្ឌទី២ ៖ ១. ការអភិវឌ្ឍនៃវិស័យកសិកម្មទំនើប
២. ការធ្វើស្រូវប្រពលវប្បកម្ម
៣. ការជីកប្រឡាយទឹក ។

គ. ចូរគូសសញ្ញា ✓ នៅមុខកន្សោមពាក្យ ដែលជាគំនិតសំខាន់ៗរបស់កថាខណ្ឌទី២ ។

- ☐ ១. ការស្ទូងស្រូវមួយដើម
- ☐ ២. ការធ្វើស្រូវប្រពលវប្បកម្ម
- ☐ ៣. ការធ្វើស្រែទាន់រដូវ
- ☐ ៤. ការប្រើជីធម្មជាតិ និងជីកំប៉ុស
- ☐ ៥. ការប្រើគោយន្ត ម៉ាស៊ីនបូមទឹក ម៉ាស៊ីនបោកស្រូវ
- ☐ ៦. ការធ្វើស្រូវប្រជេញទឹក ។



www.elibraryofcambodia.org

# ការណែនាំអំពីរបៀបដាំពោត

បូផាសួរជីតានាងអំពីរបៀបដាំពោត ។ ចូរអានការណែនាំខាងក្រោម ។

| | | |
|---|---|---|
| បូផា | : | លោកតា! ខ្ញុំចូលចិត្តញ៉ាំពោតណាស់ លោកពុកថាគាត់នឹងដាំពោត នៅតាមមាត់ទន្លេ ។ តើគេដាំពោតដូចម្ដេចលោកតា ? |
| លោកតា | : | មានអីចៅ ចាំតាប្រាប់ ។ ដំបូង គេភ្ជួររាស់ដីឱ្យស្អាត ។ បន្ទាប់មក ម្នាក់យកឈើបុកដែលមានចុងស្រួចបន្តិច មកបុករណ្ដៅ ចម្ងាយពីរណ្ដៅមួយទៅរណ្ដៅមួយទៀត ៧ ដ.ម ។ ម្នាក់យកគ្រាប់ពោតដែលត្រាំទឹករួច ២ ឬ ៣ គ្រាប់ដាក់ក្នុងរណ្ដៅនីមួយៗរួចលុបឱ្យជិត ។ |
| បូផា | : | តើប៉ុន្មានថ្ងៃទៅពោតដុះលោកតា ? ហើយនៅពេលវាដុះ គេធ្វើដូចម្ដេចទៀត ? |
| លោកតា | : | ពោតអាចដុះក្នុងរយៈពេលមួយអាទិត្យយ៉ាងយូរ ។ នៅពេលពោតដុះបានមួយចំអាមគេជ្រុំគល់វា និងដាក់ជីដើម្បីឱ្យវាឆាប់ធំ និងបានផ្លែល្អ ។ |
| បូផា | : | អរគុណលោកតា ! គិតទៅដូចជាមិនពិបាកសោះ ខ្ញុំនឹងជួយដាំពោតលោកពុកមិនខាន ។ |

ក្នុងការផ្ដល់ការណែនាំគេត្រូវប្រើពាក្យ ដំបូង បន្ទាប់ បន្ទាប់មកទៀត ទីបញ្ចប់ ឬចុងក្រោយ ។

## លំហាត់

ចូររៀបជាក្រុមតូច រួចនិយាយណែនាំមិត្តក្នុងក្រុមម្ដងម្នាក់ៗពីរបៀបដាំដំណាំអ្វីមួយ តាមលំដាប់លំដោយដូចជា ដាំផ្កា ជីរ ស្ពៃក្រៃ ម្ទេស ត្រប់ ត្រឡាច ឬឃ្លោក... ។



www.elibraryofcambodia.org

# អត្ថបទព័ត៌មាន

ចូរអានអត្ថបទព័ត៌មានខាងក្រោម ។ តើគេនិយាយអំពីអ្វីខ្លះ ?

កាលពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៩ ក្រសួងបរិស្ថានបានផ្ដល់ព័ត៌មាន ប្រជាជន ដែលរស់នៅជុំវិញបឹងទន្លេសាបទាំងអស់ ឱ្យជួយរក្សាបរិមាណទឹក ដោយ កាប់ព្រៃពន្លិចក្នុងទឹក ព្រោះវានាំឱ្យខូចគុណភាពទឹក និងនាំឱ្យកម្ពស់ទឹកឆាប់រាក់ ។ ទៀត ការកាប់ព្រៃលិចទឹកជុំវិញបឹងនឹងនាំឱ្យបាត់ជម្រកត្រី ជាហេតុធ្វើឱ្យបរិមាណ មច្ឆជាតិនានាថយចុះ ។ អ្នកមិនគោរពតាមបទបញ្ជានេះនឹងត្រូវទទួលទោសតាមច្បា

(ដកស្រង់និងសម្រួលពីកាសែតកោះសន្តិភាព ឆ្នាំ២០០

## លំហាត់

អ្នកបានស្គាល់អ្វីជាអត្ថបទព័ត៌មាន និងបានអានអត្ថបទព័ត៌មានរួចហើយ ចូរ សរសេរអត្ថបទព័ត៌មានខ្លីមួយស្ដីពី ប្រធានបទណាមួយដែលអ្នកពេញចិត្ត ក្នុងចំណោ ប្រធានបទខាងក្រោម ។

- ទិវាដាំកូនឈើ
- ការផ្សព្វផ្សាយអំពីការធ្វើជីកំប៉ុស
- ការជួយច្រូតស្រូវរបស់ប្រជាជន ។

ក្នុងអត្ថបទនោះអ្នកត្រូវបញ្ជាក់ ៖

- ពេលវេលាណាមួយ
- ទីកន្លែងពិតណាមួយ
- អ្នកណាមួយ ឬក្រុមណាមួយធ្វើសកម្មភាព ។

នៅពេលសរសេរព្រាងចប់ ចូរអ្នកពិនិត្យកិច្ចការ ឬសំណេរព្រាងរបស់អ្នកឡើ វិញ ដើម្បីកែលម្អ ៖

- អក្ខរាវិរុទ្ធ
- ឃ្លា ល្បះ និងលំដាប់លំដោយគំនិត ។



www.elibraryofcambodia.org

មេរៀនទី ៥

# មិត្តជិតស្និទ្ធ



មនុស្សគ្រប់រូប ត្រូវចេះស្រឡាញ់រាប់អានគ្នាជាមិត្ត ទើបមានសេចក្តីសុខចម្រើន ។ មិត្តល្អនាំយើងទៅរកសេចក្តីសុខចម្រើន រីឯមិត្តអាក្រក់នាំយើងទៅរកសេចក្តីទុក្ខ វិនាសអន្តរាយ ។ ដូច្នេះ មុននឹងសេពគប់មិត្ត ត្រូវប្រុងប្រយ័ត្នខ្លាចក្រែងជួបនឹងជំពូកមិត្តអាក្រក់ ។



www.elibraryofcambodia.org

## តម្លៃអប់រំនៃរឿង

រឿងនីមួយៗ សុទ្ធតែបង្កប់នូវតម្លៃអប់រំ ។ ចូរអានរឿងខាងក្រោម តើគេអប់រំដូចម្ដេច ?

### រឿង សត្វលលកនិងស្រមោចខ្មៅ

នៅលើដើមជ្រៃក្បែរមាត់ស្ទឹង មានសត្វលលកមួយរស់នៅ ។ ថ្ងៃមួយ លលកកំពុងទំនៅលើមែកឈើ គយគន់រកចំណី នៅខាងក្រោម ស្រាប់តែឃើញស្រមោចមួយហ្វូងកំពុងលង់ទឹក ។ ស្រមោចទាំងនោះខំតោងគ្នា ដើម្បីឡើងមកលើគោកវិញ ។ ប៉ុន្តែ ការខិតខំរបស់ពួកវាមិនបានសម្រេចសោះ ។ លលកឃើញដូច្នេះ មានចិត្តអាណិតអាសូរជាពន់ពេក ។ វាហើរទៅពាំមែកឈើងាប់មួយកំណាត់ យកមកដាក់ក្បែរហ្វូងស្រមោចទាំងនោះ ដើម្បីធ្វើជាស្ពាន ឱ្យស្រមោចតោងឡើង ។ ស្រមោចទាំងអស់ បានរួចផុតពីសេចក្ដីស្លាប់គ្រប់ៗគ្នា ។ ពួកស្រមោច បានថ្លែងអំណរគុណដល់លលក ដែលបានជួយសង្គ្រោះពួកគេ ។

ថ្ងៃក្រោយមក ពេលលលកកំពុងទំលើមែកឈើ ស្រាប់តែមានព្រានព្រៃដើរមកដល់ ។ ព្រានឃើញលលក ក៏តម្រង់ស្នាបម្រុងនឹងបាញ់ ។ ហ្វូងស្រមោចឃើញហើយ ក៏ស្រុះគ្នាជួយយកអាសាលលកវិញម្ដង ។ ឆ្លៀតពេលដែល ព្រានកំពុងតែស្រងៀវភ្នែកបម្រុងនឹងបាញ់ ពួកស្រមោចក៏នាំគ្នារោមខាំជើងព្រាន ។ ព្រានភ្ញាក់កន្ត្រាក់ជើង រួចទ្រូលជើងព្ញូសូរទឹបៗ ។ លលកឮស្នូរនោះ ក៏ងាកមកមើល ។ លុះដឹងថា ព្រានប៉ងបាញ់ខ្លួន លលកក៏ហើរចេញទៅ ។

(ដកស្រង់និងសម្រួល ពីគតិលោកភាគ ៩ ទំព័រទី ៣៣)

រឿងនេះ បានអប់រំយើងឱ្យចេះជួយយកអាសាអ្នកដទៃ នោះអ្នកដទៃនឹងជួយយកអាសាយើងវិញ ឬជួយគ្នាក្នុងគ្រាមានអាសន្ន ។

> តម្លៃអប់រំ គឺជាដំបូន្មាន បទពិសោធ សកម្មភាព ដែលអ្នកអានទាញយកអំពីខ្លឹមសារនៃរឿង ។



www.elibraryofcambodia.org

## លំហាត់

ចូរអានរឿងខាងក្រោម ។ តើរឿងនេះចង់អប់រំដូចម្ដេច ?

### រឿង ក្ដាន់ ក្អែក និងចចក

ក្ដាន់និងក្អែក ជាមិត្តនឹងគ្នារស់នៅយ៉ាងសុខសាន្ត ។ ថ្ងៃមួយ ចចកឃើញក្ដាន់ក៏ចូលទៅនិយាយបញ្ចុះបញ្ចូលទាល់តែក្ដាន់ទុកចិត្ត ។ សត្វទាំងពីរ សុំគ្នាធ្វើជាមិត្ត ។ ក្អែកដឹងពីល្បិចចចក ក៏ប្រាប់ក្ដាន់ឱ្យឈប់ទាក់ទង តែត្រូវក្ដាន់បដិសេធ ។ ល្ងាចមួយ ចចកឃើញអន្ទាក់ព្រាន ក៏បបួលក្ដាន់ទៅរកស៊ីទីនោះ ដើម្បីឱ្យក្ដាន់ជាប់អន្ទាក់ ។ ក្ដាន់ជឿតាមចចក ក៏ភ្លាត់ទៅជាប់អន្ទាក់ព្រាន ។ ក្ដាន់ស្រែកហៅឱ្យចចកជួយ តែចចកធ្វើមិនឮ រត់ពួនក្នុងគុម្ពោតព្រៃចាំមើលក្ដាន់រើបម្រះអស់កម្លាំង វានឹងស៊ី ។ ក្អែកពុំឃើញក្ដាន់ ខំហើររក ក៏ប្រទះឃើញក្ដាន់ជាប់អន្ទាក់ ។ ក្អែកប្រាប់ក្ដាន់ឱ្យធ្វើពុតជាងាប់ នៅពេលព្រានមកដល់ ។ ពេលព្រានដោះអន្ទាក់រួច វានឹងធ្វើសញ្ញាឱ្យក្ដាន់ស្ទុះបោលឱ្យលឿន ។ ព្រានមកដល់ឃើញក្ដាន់ជាប់អន្ទាក់ដេកស្ដូក ក៏ដោះក្ដាន់ដាក់ទៅម្ខាង ។ ក្អែកឃើញដូច្នោះ ក៏ស្រែកខ្វកៗ ។ ក្ដាន់ស្ទុះបោល ចូលទៅក្នុងព្រៃ ។ ព្រានក៏ស្ទុះទៅយកលំពែងពួយសំដៅក្ដាន់ តែជួនជាចំកន្លែងចចកសម្ងំនៅ ។ លំពែងនោះធ្លាក់ត្រូវចចកមរណា នាពេលនោះទៅ ។

(ដកស្រង់ និងកែសម្រួលពីគតិលោកភាគ៥)



### រឿង ស្មាន់ ទីទុយ និងអណ្ដើក

ចូរអានអត្ថបទ រួចឆ្លើយនឹងសំណួរខាងក្រោម ។

កាលពីព្រេងនាយ មានស្មាន់ ទីទុយ និងអណ្ដើកយកគ្នាជាគ្នើ ។ ថ្ងៃមួយ ស្មាន់ចេញទៅរកស៊ី ក៏ជាប់អន្ទាក់ព្រាន ។ ទីទុយនិងអណ្ដើកបាត់ស្មាន់យូរពេក នាំគ្នាដើររកលុះដល់ជាយព្រៃ ក៏ឃើញស្មាន់ជាប់អន្ទាក់ ។ ទីទុយនិងអណ្ដើក ស្ម័គ្រទទួលជួយដោះទុក្ខមិត្ត ។ ទីទុយហើរទៅពាំទឹកមកស្រោចខ្សែអន្ទាក់ឱ្យទន់ ឯអណ្ដើកក៏ខំខាំកកេរផ្ដាច់ខ្សែអន្ទាក់ ។ ទីទុយនិងអណ្ដើក ព្យាយាមខាំកាត់អន្ទាក់ទើបបានពីរធ្នុង ក៏ជួនជាព្រានព្រៃ



www.elibraryofcambodia.org



មក ។ សត្វទាំងពីរប្រាប់ស្មាន់ថា ព្រានមកជិតដល់ហើយ ឱ្យស្មាន់ខំប្រឹងបោលកន្ត្រាក់ខ្លួ
ឯង ព្រោះខ្សែអន្ទាក់នៅសល់តែមួយផ្លូងទៀតទេ ។ ពេលនោះ ព្រានព្រៃក៏មកដ
ល្មម ។ ទីទុយនិងអណ្ដើកក៏ចូលទៅពួនក្នុងព្រៃ ចាំមើលដំណើរស្មាន់ ។ ឃើញព្រានម
ដល់ជិតខ្លួន ស្មាន់ស្ទុះកន្ត្រាក់ផ្ដាច់អន្ទាក់នោះបាន ហើយបោលចូលព្រៃបាត់ ។ ព្រាននឹ
ស្ដាយស្មាន់ណាស់ រត់ដេញតាម តែតាមមិនទាន់ ក៏ទៅប្រទះនឹងអណ្ដើកដែលពួន
វិញ ។ ព្រានចាប់អណ្ដើក ហើយក៏វិលមកធ្វើអន្ទាក់នោះទៀត ។ ទីទុយឃើញព្រា
ចាប់អណ្ដើកបាន ក៏ប្រាប់ស្មាន់ ឱ្យក្លែងធ្វើជាបាក់ជើងដើរទៅក្បែរព្រានព្រៃ ប្រើឧបា
កលមាយាឱ្យព្រានព្រៃដេញ ។ ឆ្លៀតពេលនោះ ស្មាន់ត្រូវរត់គេចមកក្រោយ ខាំ
អណ្ដើកបោលចូលព្រៃឱ្យរួចពីដៃព្រាននោះ ។ ស្មាន់ដើរជិតដល់ព្រាន ក៏ធ្វើអាការជាច
ជើងម្ខាង បោលបោះតែជើងបីចំពោះមុខព្រាន ។ ព្រានស្មានថា ស្មាន់បាក់ជើងមែន
ចោលអណ្ដើកទៅលើគុម្ពស្បូវរត់តាមស្មាន់ ។ ស្មាន់ដឹងថា ព្រានចោលអណ្ដើកហើ
ក៏រឹតតែធ្វើកលបោកឱ្យព្រានដេញចេញផុតពីព្រៃស្បូវ ។ បានឱកាសល្អ ស្មាន់បោល
មកក្រោយ ពាំអណ្ដើកបោលផ្លោះចូលទៅក្នុងព្រៃធំ ។ ទីទុយហើរ នាំផ្លូវដរាបដល់
មួយ ដែលផុតព្រានដើរទៅដល់ ។ សត្វទាំងបីនាំគ្នារស់នៅក្នុងព្រៃជាសុខសាន្ត ។

(ដកស្រង់និងសម្រួលពីសៀវភៅ កម្រងអត្ថបទអក្សរសិល្ប៍ ថ្នាក់ទី៥ បោះពុម្ពឆ្នាំ១៩៨



www.elibraryofcambodia.org

## សំណួរ

១. តើស្មាន់ ទីទុយ និងអណ្ដើកត្រូវជាអ្វីនឹងគ្នា ?

២. តើទីទុយនិងអណ្ដើកជួយស្មាន់ដូចម្ដេចខ្លះ ?

៣. តើទីទុយនិងស្មាន់ជួយអណ្ដើកដូចម្ដេចខ្លះ ?

៤. តើអ្នកមានចំណាប់អារម្មណ៍ដូចម្ដេច ចំពោះរឿងនេះ ? ព្រោះអ្វី ?

## លំហាត់

ក. តើរឿងនេះចង់អប់រំដូចម្ដេច ? ចូរជ្រើសរើសចម្លើយត្រឹមត្រូវមួយ ។

☐ ១. មិត្តល្អត្រូវគោរពសិទ្ធិគ្នាទៅវិញទៅមក ។

☐ ២. មិត្តល្អត្រូវនាំគ្នាស្វែងរកលាភ ។

☐ ៣. មិត្តល្អត្រូវជួយគ្នាក្នុងគ្រាមានអាសន្ន ។

ខ. ចូររកពាក្យន័យដូចនឹងពាក្យ " ភ្លើ ប្រហារ " ។

គ. ចូររកពាក្យសូរដូចនឹងពាក្យ "ទុក្ខ គុម្ព" ។

ឃ. ចូរប្រើវចនានុក្រមដើម្បីអាន និងរកន័យរបស់ពាក្យ ។

| | | | | | |
|---|---|---|---|---|---|
| ព្រាន | អន្តរាយ | ក្លែង | ប្រព្រឹត្ត | អាស្រ័យ | អាការ |

ង. តើរឿងនេះបានបញ្ចប់ដូចម្ដេច ? ចូរជ្រើសរើសចម្លើយត្រឹមត្រូវមួយ ។

☐ ១. រឿងនេះបញ្ចប់ដោយឱ្យតួអង្គ ដែលចេះជួយគ្នាត្រូវបែកបាក់គ្នា ។

☐ ២. រឿងនេះបញ្ចប់ដោយឱ្យតួអង្គ ដែលចេះជួយគ្នាបានទទួលជោគជ័យ ។

☐ ៣. រឿងនេះបញ្ចប់ដោយឱ្យតួអង្គ ដែលចេះជួយគ្នាត្រូវរងគ្រោះ ។



www.elibraryofcambodia.org

# កថាខណ្ឌពណ៌នាអំពីមនុស្ស

អ្នកបានយល់បញ្ញត្តិកថាខណ្ឌរួចហើយ ចូរអ្នកសរសេរកថាខណ្ឌខ្លីៗពណ៌នាពី ម្ដាយរបស់អ្នកតាមរូបភាព និងសំណួរខាងក្រោម ។



**លំហាត់ ក**

- តើម្ដាយអ្នកឈ្មោះអ្វី ?
- តើគាត់មានអាយុប៉ុន្មានឆ្នាំ ?
- តើគាត់ប្រកបរបរអ្វី ?
- តើម្ដាយអ្នកមានរាងរៅដូចម្ដេច?
- តើគាត់មាន សម្បុរ មុខ សក់ ភ្នែក មាត់ ច្រមុះ ដៃ ជើង ដូចម្ដេច ?
- តើគាត់ស្លៀកពាក់ដូចម្ដេច ?
- តើគាត់មានដំណើរ សម្ដីសំដៅដូចម្ដេច?

**លំហាត់ ខ**

- តើម្ដាយអ្នកជាមនុស្សដូចម្ដេច ? (ស្លូតបូត កាច មានប្រាជ្ញា ឧស្សាហ៍ ព្យាយាម ឃ្មាត់ចត់...)
- តើគាត់មានទំនាក់ទំនងដូចម្ដេច ជាមួយមនុស្សនៅក្នុងផ្ទះ ? ជាមួយអ្នកជិតខាង?
- តើគាត់ធ្វើអ្វីខ្លះរៀងរាល់ថ្ងៃ ?
- តើគាត់ចូលចិត្តអ្វី ?
- តើអ្នកមានទឹកចិត្តដូចម្ដេច ចំពោះម្ដាយអ្នក ?





www.elibraryofcambodia.org

# ការពណ៌នាអំពីតួអង្គ

គេអាចស្គាល់តួអង្គ តាមរយៈការពណ៌នារបស់អ្នកនិពន្ធ ឬតួអង្គផ្សេងទៀតនៅក្នុងសាច់រឿង ។ ចូរអានរឿងខាងក្រោម តើអ្នកនិពន្ធបានពិពណ៌នាអំពីតួអង្គដូចម្ដេចខ្លះ ?

## រឿង ទឹកចិត្តប្អូន

កាលពីដើម មានយុវជនម្នាក់អាយុ ១៨ឆ្នាំឈ្មោះ វាសនា ។ វាសនា មានរូបរាងសង្ហា និងមានចរិតស្លូតបូត ។ វាសនារស់នៅជាមួយបងប្រុស ដែលមានប្រពន្ធរួចហើយ ។ ទាំងពីរនាក់បងប្អូន ស្រឡាញ់គ្នាណាស់ ។

ថ្ងៃមួយ មានសត្រូវបរទេសចូលមកឈ្លានពានទឹកដី ។ មេទ័ព បានតម្រូវឱ្យយុវជនទាំងអស់ចូលបម្រើកងទ័ព ។ វាសនានិងបងប្រុស បានចូលបម្រើក្នុងជួរកងទ័ព ។ ថ្ងៃមួយពេលចេញច្បាំង បងប្រុសត្រូវសត្រូវចាប់បាននាំយកទៅ ។ វាសនាគិតថា ខ្លួននៅលីវគ្មានប្រពន្ធកូន ឯបងខ្លួនមានប្រពន្ធកូន សូវខ្លួនស្លាប់ចុះ ឱ្យបងរស់នៅចិញ្ចឹមប្រពន្ធកូនប្រសើរជាង ។ គិតហើយ វាសនាកន្ត្រាក់ដាវរត់ទៅស្កាត់ពួកខ្មាំង ។ វាសនាប្រយុទ្ធជាមួយសត្រូវ ដោយស្រែកប្រាប់ឱ្យបងរត់ ទុកឱ្យខ្លួននៅតទល់នឹងសត្រូវ ។ បងរត់រួចវាសនានៅតស៊ូនឹងខ្មាំង ដោយបញ្ចេញអស់នូវចំណេះគុនទាំងប៉ុន្មាន ។ ជាសំណាងល្អកងទ័ពជំនួយមកដល់ធ្វើឱ្យសត្រូវរត់ខ្ចាត់ខ្ចាយអស់ទៅ ។

រឿងនេះ គេពណ៌នាអំពីតួអង្គវាសនា ដោយរៀបរាប់ ឈ្មោះ អាយុ រូបរាង ចរិតការរស់នៅ សកម្មភាព និងទឹកចិត្ត ។

> ការពណ៌នាអំពីតួអង្គ គឺការរៀបរាប់ពី រូបរាង តួនាទី ចរិតលក្ខណៈ (គុណសម្បត្តិ គុណវិបត្តិ) សកម្មភាព ចំណង់ចំណូលចិត្ត របស់តួអង្គ ដែលអ្នកនិពន្ធបានបង្ហាញនៅក្នុងសាច់រឿង ។

### លំហាត់

ចូរអ្នកអានរឿងណាមួយ រួចសរសេរពណ៌នាតួអង្គណាមួយនៅក្នុងរឿងនោះ ។

www.elibraryofcambodia.org

# ៦ រឿង នាយល្អ

បន្ទាប់ពីស្តាប់រឿង ចូរឆ្លើយនឹងសំណួរ ។



## សំណួរ

១. ហេតុអ្វីបានជាហ្វូងព្រាបជាប់លប់ ?

២. តើមេហ្វូងហាមហ្វូងព្រាបដូចម្តេច ?

៣. តើព្រាបទាំងអស់បានរួចពីសេចក្តីស្លាប់ ដោយវិធីណា ?

៤. តើអ្នកមានចំណាប់អារម្មណ៍ដូចម្តេចចំពោះរឿងនេះ ? ព្រោះអ្វី ?

## លំហាត់

ក. **តើរឿងនេះចង់អប់រំដូចម្តេច ? ចូរជ្រើសរើសចម្លើយត្រឹមត្រូវមួយ ។**

☐ ១. សាមគ្គីភាពនាំឱ្យបាត់បង់លាភសក្ការៈ ។

☐ ២. សេចក្តីក្លាហាននាំឱ្យទទួលបានជោគជ័យ ។

☐ ៣. សាមគ្គីភាពជាកម្លាំងនាំឱ្យរួចផុតពីសេចក្តីអន្តរាយ ។

ខ. **ចូរធ្វើការពណ៌នាតួអង្គព្រាបមេហ្វូង និងហ្វូងព្រាប ។**



www.elibraryofcambodia.org

# សព្វនាម

ចូរអានឧទាហរណ៍នីមួយៗខាងក្រោម ។ ពាក្យមានគំនូសពីក្រោមជាសព្វនាម ។

១. ខ្ញុំ មានមិត្តជិតស្និទ្ធច្រើន ។

២. ពួកយើង តែងជួយធុរៈគ្នាទៅវិញទៅមក ។

៣. សុខា ជាមិត្តល្អរបស់ខ្ញុំម្នាក់ ។ វា ជាកូនកំព្រាឪពុកម្ដាយ ។

៤. តើអ្នកណាជាមិត្តភក្ដិថ្មីរបស់ឯង ? ធារ៉ា ។

៥. មិត្តល្អ តែងជួយគ្នាក្នុងគ្រាមានអាសន្ន ។ នេះ ជាទង្វើដ៏ប្រពៃ ។

ពាក្យ " ខ្ញុំ ពួកយើង" បង្ហាញបុគ្គលចូលរួមក្នុងការប្រាស្រ័យទាក់ទងគ្នា ។

ពាក្យ " វា" ប្រើជំនួសនាមសុខា ដែលនិយាយរួចមកហើយ ។

ពាក្យ " អ្នកណា" ប្រើជំនួសនាមធារ៉ា ដែលគេនិយាយនៅពេលបន្ទាប់ ។

ពាក្យ " នេះ" ប្រើជំនួសល្បះ ដែលនិយាយរួចមកហើយ ។

ពាក្យ " ខ្ញុំ ពួកយើង វា អ្នកណា នេះ" ជាសព្វនាម ។

សព្វនាម ជាពាក្យសម្រាប់ប្រើជំនួសនាម ឬកន្សោមនាម និងសម្រាប់បង្ហាញបុគ្គលចូលរួមក្នុងការប្រាស្រ័យទាក់ទងគ្នា ។

## លំហាត់

ក. **ចូរស្រង់សព្វនាមនៅក្នុងល្បះខាងក្រោម ។**

១. ខ្ញុំតែងទៅលេងផ្ទះកុលាប ពីព្រោះខ្ញុំនិងនាងស្រឡាញ់រាប់អានគ្នាណាស់ ។

២. មិត្តរួមថ្នាក់ បានជួយប្រាក់កាស និងសម្ភារៈផ្សេងៗដល់សារិន ព្រោះវាមានជីវភាពខ្សត់ខ្សោយ ។

៣. តើឯងចូលចិត្តអ្នកណា ?

៤. បូផា ជាសិស្សឧស្សាហ៍រៀនសូត្រ ។ នាងប្រឡងជាប់លេខមួយរាល់ឆ្នាំ ។

**ចូរតែងល្បះ ដោយប្រើសព្វនាម ៖ គាត់ ខ្ញុំ ឯង អ្នកណា ។**



www.elibraryofcambodia.org

# កល្យាណមិត្ត

ចូរអានអត្ថបទ រួចឆ្លើយនឹងសំណួរខាងក្រោម ។



នៅសាលារៀន ខ្ញុំមានមិត្តភក្តិច្រើនណាស់ ។ យើងស្រឡាញ់រាប់រកគ្នាបីដូចបងប្អូន រួមឧទរ ។ មិត្តខ្ញុំជាមិត្តល្អ គួរឱ្យមានទំនុកចិត្ត និងការកក់ក្តៅ ។ មិត្តល្អ មានសន្តានចិត្ត ស្មោះស បរិសុទ្ធ ឥតលាក់លៀម ឥតពុតត្បុត ។ យើងលើកសរសើរមិត្ត ដែលបាន ប្រព្រឹត្តល្អ ហើយពន្យល់ណែនាំមិត្តខ្លះ ដែលប្រព្រឹត្តខុសឆ្គងឱ្យមានចរិត ចរិយាត្រឹមត្រូវ អនុវត្តតាមការទូន្មានប្រៀនប្រដៅរបស់លោកគ្រូ ។ គ្រប់កាលៈទេសៈ មិត្តល្អតែងជួយ ធុរៈគ្នា ជួយឧបត្ថម្ភគ្នា ឱ្យមានសេចក្តីសុខក្សេមក្សាន្ត ។ យើងមិនដែលបោះបង់ចោលគ្នា នៅគ្រាអាសន្នឡើយ ។ មិត្តល្អ គឺជាកល្យាណមិត្ត ។

ដូច្នេះយើងយល់ថា កុលបុត្រ កុលធីតា ត្រូវពិនិត្យពិចារណាឱ្យបានច្បាស់លាស់ មុន នឹងចងស្ពានមេត្រីនឹងជនណាម្នាក់ ។ ពុទ្ធភាសិតមួយបានពោលថា“ ត្រូវរាប់រក បុគ្គលល្អប្រកបដោយសប្បុរសធម៌ដ៏ឧត្តម ដែលមានលក្ខណៈជាកល្យាណមិត្ត” ។



www.elibraryofcambodia.org

## សំណួរ

១. នៅសាលារៀន តើអ្នកមានមិត្ត ឬទេ ?

២. តើមិត្តរបស់អ្នក មានលក្ខណៈយ៉ាងណាខ្លះ ?

៣. តើមនុស្សប្រភេទណា ដែលយើងគួរយកជាមិត្ត ?

៤. ក្នុងការរាប់រកមិត្ត តើពុទ្ធសុភាសិតបានពោលថាដូចម្តេច ?

## លំហាត់

ចូរស្រង់សព្វនាម ចេញពីអត្ថបទអំណាន និងពន្យល់ពីរបៀបប្រើសព្វនាម ។

## ការពណ៌នាពីមិត្តល្អ

ចូរអានការសន្ទនាខាងក្រោម រួចកត់សម្គាល់លក្ខណៈរបស់មិត្តល្អ ។



នីសា : សួស្តី ផានិត! នេះគឺ ភារុនជាមិត្តរបស់ខ្ញុំ ។

ផានិត : សួស្តី ភារុន! រីករាយណាស់ដែលបានស្គាល់ឯង ។ តើអ្នកទាំងពីរស្គាល់គ្នាយូរហើយមែន ឬទេ ?

នីសា : មែនហើយ ! ភារុនជាមិត្តល្អរបស់ខ្ញុំ ។ ភារុនស្លូតបូត ចិត្តល្អ ស្មោះត្រង់ និងមានអធ្យាស្រ័យល្អចំពោះមិត្តភក្តិ ។

ផានិត : ប្រសើរណាស់! ពិតជាគួរឱ្យរាប់អានមែន ។

នីសា : ផានិតដឹងទេ ភារុន រៀនពូកែណាស់ ។ ពេលទំនេរ គេតែងបបួលមិត្តភក្តិធ្វើលំហាត់ ឬចូលបណ្ណាល័យដើម្បីអានសៀវភៅ ។

ផានិត : ខ្ញុំចូលចិត្តមិត្តបែបនេះណាស់! ខ្ញុំសុំរាប់អានភារុនផងបានទេ ?

ភារុន : មានអី! ខ្ញុំរីករាយនឹងរាប់អានឯង ។

## លំហាត់

ចូររៀបគ្នាជាក្រុម ។ ក្រុមនីមួយៗ ត្រូវរៀបចំគំនិតពណ៌នាពីមិត្តល្អណាម្នាក់ រួច
យប្រាប់សិស្សទាំងអស់គ្នា ។



www.elibraryofcambodia.org

# អត្ថបទពណ៌នាអំពីមនុស្ស

អត្ថបទមួយ អាចមានមួយ ឬច្រើនកថាខណ្ឌ ។ ការចាប់ផ្ដើមកថាខណ្ឌ គេត្រូវចូលបន្ទាត់ ។

ចូរអានអត្ថបទខាងក្រោម និងស្វែងយល់ការពណ៌នានៅក្នុងផ្នែកនីមួយៗ ។



លោកគ្រូខ្ញុំឈ្មោះ សុផាត ។ គាត់ មានអាយុ៥៥ឆ្នាំ ។ គាត់មានរាងទាបក្រអាញ សម្បុរសណ្ដែកបាយ សក់រួញអង្កាដី ។ មុខគាត់ មានរាងពងក្រពើ ភ្នែកធំៗ ចិញ្ចើមក្រាស់ ច្រមុះស្រួច ។ គាត់មានទឹកមុខញញឹមគួរឱ្យចូលចិត្ត ។ ដៃជើងរបស់គាត់ មានសាច់ដុំធំៗទំនងជាមនុស្សមានកម្លាំងណាស់ ។ លោកគ្រូខ្ញុំនិយាយមួយៗច្បាស់ៗ និងមានសំឡេងពីរោះគួរឱ្យចង់ស្ដាប់ ។ គាត់តែងស្លៀកសម្លៀកបំពាក់សមរម្យជានិច្ច ។

លោកគ្រូខ្ញុំជាមនុស្សរួសរាយ រាក់ទាក់ និងមានទឹកចិត្តល្អ ។ លើសពីនេះ គាត់មានចរិតស្លូតបូត តែម៉ឺងម៉ាត់ក្នុងការងារ ។ គាត់ឧស្សាហ៍ព្យាយាម និងមានអធ្យាស្រ័យល្អណាស់ ។ ពេលសិស្សមានកំហុស គាត់ពុំដែលសម្លុត បន្តុះបង្អាប់ ឬប្រើហិង្សាឡើយ ។ គាត់តែងនិយាយណែនាំ ដាស់តឿន លួងលោមសិស្សដោយពាក្យផ្អែមល្ហែម ។ អ្នកផងចាត់ទុកគាត់ជាមនុស្សថ្លៃថ្នូរ ។

លោកគ្រូខ្ញុំ ជាមនុស្សសកម្មក្នុងការងារ ។ គាត់យកចិត្តទុកដាក់ ក្នុងការបង្រៀនណាស់ ។ នៅផ្ទះគាត់ឆ្លៀតដាំដំណាំ ចិញ្ចឹមសត្វ ដើម្បីជាជំនួយក្នុងការដោះស្រាយជីវភាពប្រចាំថ្ងៃ ។ លើសពីនេះ គាត់តែងចូលរួមយ៉ាងសកម្មក្នុងការងារអភិវឌ្ឍសហគមន៍ ។ ពេលទំនេរ លោកគ្រូខ្ញុំចូលចិត្តលេងកីឡាវាយសី និងលេងប៊ូល ។

ខ្ញុំនិងមិត្តភក្តិ គោរពស្រឡាញ់លោកគ្រូខ្ញុំណាស់ ព្រោះគាត់ខំបង្រៀន និងអប់រំសិស្សឱ្យក្លាយជាមនុស្សល្អ ។



www.elibraryofcambodia.org

## សំណួរ

១. តើអត្ថបទនេះ ពណ៌នាពីអ្នកណា ?

២. តើអត្ថបទនេះ ចែកជាប៉ុន្មានកថាខណ្ឌ ?

៣. តើកថាខណ្ឌទី១ រៀបរាប់ពីអ្វី ?

៤. តើកថាខណ្ឌទី២ រៀបរាប់ពីអ្វី ?

៥. តើកថាខណ្ឌទី៣ រៀបរាប់ពីអ្វី ?

៦. តើកថាខណ្ឌទី៤ រៀបរាប់ពីអ្វី ?

តាមធម្មតា ក្នុងការពណ៌នាអំពីមនុស្ស ក្នុងតួសេចក្តីត្រូវចែកជាពីរផ្នែកធំៗ ៖

**១. រូបសម្បត្តិ**

ភិនភាគ ឬរូបរាងខាងក្រៅ ៖ មាឌ កម្ពស់ សម្បុរ ទម្រង់មុខ មាត់ ច្រមុះ ភ្នែក ត្រចៀក ចង្កា ដៃជើង សម្លៀកបំពាក់ គ្រឿងតុបតែងខ្លួន... ។

ឥរិយាបថ ៖ ដេក ដើរ ឈរ អង្គុយ និយាយស្តី... ។

**២. ចរិយាសម្បត្តិ**

គុណសម្បត្តិ៖ ប្រាជ្ញា សមត្ថភាព ទម្លាប់ល្អ ភាពហ្មត់ចត់ ការឧស្សាហ៍ព្យាយាម... ។

គុណវិបត្តិ ៖ កាច ព្រហើន ហិង្សា ខ្ជិល ខ្ជីខ្ជា... ។

## លំហាត់

ក. **ចូរអ្នកសរសេរអត្ថបទពណ៌នាអំពីឪពុក ឬជីតារបស់អ្នក មួយកថាខណ្ឌម្តងៗតាមលំដាប់លំដោយដូចខាងក្រោម ។**

កថាខណ្ឌទី១ ៖ ឈ្មោះ អាយុ រូបសម្បត្តិរបស់គាត់

កថាខណ្ឌទី២ ៖ ចរិយាសម្បត្តិរបស់គាត់

កថាខណ្ឌទី៣ ៖ ចំណាប់អារម្មណ៍របស់អ្នកចំពោះគាត់ ។



www.elibraryofcambodia.org

៦.	ចូរអ្នកសរសេរអត្ថបទខ្លី ពណ៌នាពីមិត្តភក្តិណាម្នាក់របស់អ្នក ។ ចូរអ្នកអនុវត្តតាមគម្រោងខាងក្រោម ។

## គម្រោងតែង

១. សេចក្តីផ្តើម

ឈ្មោះ មិត្តភក្តិ អាយុ ថ្នាក់រៀន ។

២. តួសេចក្តី

ពណ៌នាអំពីរូបរាង ឬភិនភាគពិសេសផ្សេងៗ ៖

- លក្ខណៈទូទៅ ៖ អាយុ មាឌ កម្ពស់ សម្បុរ ...
- ឥរិយាបថ ៖ ការដើរ ការនិយាយស្តី ការលេង ...
- ការស្លៀកពាក់ ៖
- គុណសម្បត្តិ ៖ ឧស្សាហ៍ ព្យាយាមរៀនសូត្រ មករៀនទៀងទាត់ គោរពវិន័យ មានប្រាជ្ញាឈ្លាសវៃ ជួយធុរៈឪពុកម្តាយ ... ។

៣. សេចក្តីបញ្ចប់

ចំណាប់អារម្មណ៍របស់អ្នកចំពោះមិត្តភក្តិនោះ (តើអ្នកស្រឡាញ់ ឬចូលចិត្តចងមិត្តជាមួយមិត្តភក្តិនោះដែរ ឬទេ ?)

ពេលសរសេររួច ចូរអ្នកពិនិត្យសំណេរលើចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម ។

១. តើអ្នកបានដាក់ចំណងជើងអត្ថបទហើយ ឬនៅ ?

២. តើល្បះទាំងអស់សុទ្ធតែរៀបរាប់ពីមិត្តអ្នកមែន ឬទេ ?

៣. តើល្បះមានលំដាប់លំដោយ ឬនៅ ?

៤. តើអក្ខរាវិរុទ្ធត្រឹមត្រូវ ឬទេ ?

៥. តើកថាខណ្ឌនីមួយៗចាប់ផ្តើមបន្ទាត់ហើយ ឬនៅ ?



www.elibraryofcambodia.org

មេរៀនទី ៦

# មធ្យោបាយធ្វើទំនាក់ទំនង



វិទ្យាសាស្ត្រកាន់តែរីកចម្រើន មធ្យោបាយសម្រាប់ទាក់ទងក៏កាន់តែទំនើប និងសម្បូរបែប រីឯមធ្យោបាយផ្សព្វផ្សាយកាន់តែអភិវឌ្ឍឈានឡើងជាលំដាប់ តាំងពីគ្រាន់តែឮសូរសំឡេង ទៅឃើញរូបភាព ។ ទំនាក់ទំនងផ្ទាល់មាត់ ឬសរសេរសារដោយឃើញរូបភាពផង នាំឱ្យមនុស្សស្គាល់គ្នាកាន់តែច្រើន ។



www.elibraryofcambodia.org

## ការបង្ហាញមូលហេតុនៃព្រឹត្តិការណ៍

អ្វីៗដែលកើតមានឡើង មានទំនាក់ទំនងគ្នាជានិច្ច ។ ព្រឹត្តិការណ៍មួយកើតមានឡើង តែងតែនាំឱ្យព្រឹត្តិការណ៍ផ្សេងទៀតកើតឡើងដែរ ។ ចូរអានឧទាហរណ៍ខាងក្រោម តើក្រុមពាក្យមានគំនូសពីក្រោម និងក្រុមពាក្យដែលសរសេរជាអក្សរទ្រេតមានទាក់ទំនងគ្នាដូចម្តេច ។

១. ព្រឹកនេះ <u>លក្ខិណាសប្បាយចិត្តណាស់</u> *ពីព្រោះនាងបានទទួលសំបុត្រមួយច្បាប់ពីម្តាយមីងដែលនៅបរទេស ។*

២. *បងប្រុសរបស់សុខាបានបាត់ទូរស័ព្ទដៃ* <u>ទើបគាត់ទៅទិញទូរស័ព្ទថ្មីមួយទៀត ។</u>

**ក្នុងឧទាហរណ៍ទី១**

- ពីព្រោះនាងបានទទួលសំបុត្រមួយច្បាប់ ពីម្តាយមីងដែលនៅបរទេស ៖ ជាហេតុ ឬ មូលហេតុ
- លក្ខិណាសប្បាយចិត្តណាស់ ៖ ជាផល ឬ ព្រឹត្តិការណ៍ ។

**ក្នុងឧទាហរណ៍ទី២**

- បងប្រុសរបស់សុខា បានបាត់ទូរស័ព្ទដៃ ៖ ជាមូលហេតុ
- ទើបគាត់ទៅទិញទូរស័ព្ទថ្មីមួយទៀត ៖ ជាផល ឬព្រឹត្តិការណ៍ ។

ព្រឹត្តិការណ៍ ឬផល គឺជាលទ្ធផលដែលកើតមានឡើងអាស្រ័យដោយហេតុ ។ ហេតុ ឬមូលហេតុ គឺរឿងអ្វីមួយដែលកើតឡើង ។

*គេប្រើពាក្យ "ពីព្រោះ ដោយសារ មកពី" ដើម្បីសម្គាល់មូលហេតុ និងពាក្យ "ទើប ហេតុនេះ ដូច្នេះ" ដើម្បីសម្គាល់ផល ឬព្រឹត្តិការណ៍ ។*



www.elibraryofcambodia.org

លំហាត់

ចូរអានឧទាហរណ៍ខាងក្រោមរួចបង្ហាញមូលហេតុ និងព្រឹត្តិការណ៍ ឬផល ។

១. ឪពុកសំមិនហ៊ានចេញទៅនេសាទត្រីទេថ្ងៃនេះ ពីព្រោះគាត់បានស្តាប់វិទ្យុផ្សាយថានឹងមានខ្យល់ព្យុះខ្លាំង នៅពេលរសៀល ។

២. ទូរស័ព្ទនេះខូច ទើបខ្ញុំហៅចេញមិនបាន ។

៣. បងខ្ញុំហៅជាងមកជួសជុលទូរទស្សន៍ ពីព្រោះយើងមើលរូបភាពមិនឃើញ ។

៤. ចិន្តាប្រារព្ធពិធីបុណ្យខួបកំណើត នៅវេលាម៉ោងប្រាំ ។ ដល់ម៉ោងកំណត់ឪពុកនាងនិយាយទូរស័ព្ទមកប្រាប់ថា ឡានគាត់ត្រូវបែកកង់ ។ នាងពន្យារពេលប្រារព្ធពិធី ពីព្រោះត្រូវរង់ចាំឪពុកនាងត្រឡប់មកវិញ ។



## ការសន្ទនាតាមទូរស័ព្ទ

ម្តាយសាន បានទៅសួរសុខទុក្ខលោកយាយរបស់គេនៅស្រុកកំណើត ។ ម្តាយសាន បាននិយាយទូរស័ព្ទមកសាន ។

ចូរស្តាប់ការសន្ទនារវាងសាន និងម្តាយ រួចឆ្លើយនឹងសំណួរខាងក្រោម ។



១. តើម្តាយសាន និយាយទូរស័ព្ទទៅកាន់អ្នកណា ?

២. នៅពេលទទួលទូរស័ព្ទ តើសាននិយាយដូចម្តេច ?

៣. តើម្តាយសាន សួរសានអំពីអ្វីខ្លះ ?

៤. តើសានកំពុងធ្វើអ្វី ?

៥. តើគេសួរម្តាយពីអ្វីខ្លះ ?

៦. នៅពេលបញ្ចប់ការសន្ទនា តើគេនិយាយដូចម្តេច ?



www.elibraryofcambodia.org

# ការបង្ហាញអារម្មណ៍របស់តួអង្គ

គេអាចស្គាល់អារម្មណ៍ ឬចិត្តរំភើបរបស់តួអង្គនៅក្នុងរឿង តាមរយៈពាក្យពេចន៍ ឬល្បះ ដែលអ្នកនិពន្ធជ្រើសរើសយកមកសម្ដែង ដើម្បីបង្កើត ឬបំផុសអារម្មណ៍រំភើបបែបណាមួយដល់អ្នកអានដូចជា ព្រួយ កើតទុក្ខ ភ័យ អរ រីករាយ ឬខឹងសម្បាជាដើម ។

ចូរអានកថាខណ្ឌខាងក្រោម ។

ព្រឹកមួយ ពេលរៀបចេញទៅសាលារៀន ធីតាបានទទួលសំបុត្រមួយច្បាប់ពីឪពុកមារបស់នាង ។ ធីតាប្រញាប់បើកសំបុត្រអានភ្លាម ។ ពេលអានចប់ នាងមានទឹកមុខញញឹមពព្រាយ ហើយរត់ទៅប្រាប់ម្ដាយថា លោកពូរបស់នាងនឹងនាំកូនចៅមកលេងគ្រួសារនាង ហើយថែមទាំងទិញរបស់របរផ្ញើនាងទៀតផង ។

ក្នុងចម្លើយទាំង៣ខាងក្រោមនេះ ចម្លើយទី១ បង្ហាញអារម្មណ៍របស់ធីតា ។

១. ធីតាសប្បាយចិត្ត ព្រោះឪពុកមារបស់នាងនឹងមកលេង ។

២. ធីតាមិនសប្បាយចិត្ត ព្រោះខ្លាចឪពុកមាមិនបានមកលេង ។

៣. ធីតាព្រួយចិត្ត ព្រោះនាងនឹកឪពុកមាខ្លាំងណាស់ ។

## លំហាត់

ចូរអានកថាខណ្ឌខាងក្រោម រួចបង្ហាញអារម្មណ៍របស់តួអង្គ ។

ក. ល្ងាចនេះ វីរៈអង្គុយរង់ចាំឪពុកដែលបានសន្យាថា ទិញកូនវិទ្យុមួយឱ្យគេស្ដាប់ ។ វីរៈដើរចេញមកក្រៅមើលទៅផ្លូវ រួចចូលទៅអង្គុយវិញ ។ មួយសន្ទុះ គេក្រោកដើរ ហើយចេញមកឈរនៅមាត់ទ្វារម្ដងទៀត ព្រោះចង់ឃើញវិទ្យុ ។

ខ. កល្យាណអង្គុយសញ្ចប់សញ្ចឹងមិននិយាយស្ដីរកមិត្តភក្ដិសោះ នៅវេលាព្រឹកនេះ ។ ជួនកាល គេឃើញនាងដកដង្ហើមធំម្ដងៗ ព្រមទាំងមានទឹកភ្នែករលីងរលោងទៀតផង ។ នៅពេលគេសួរនាង នាងប្រាប់ថា ជីដូននាងកំពុងឈឺធ្ងន់ ។



www.elibraryofcambodia.org

# ដំណើរកម្សាន្តរបស់គន្ធា



ល្ងាចថ្ងៃសៅរ៍សប្តាហ៍មុន គន្ធានិងគ្រួសារបានឃើញទិដ្ឋភាពដ៏ស្រស់ត្រកាលរបស់ខេត្តមណ្ឌលគិរីតាមទូរទស្សន៍ ។ នាងបានឃើញភ្នំទាប ខ្ពស់យ៉ាងច្រើន វាលស្មៅពណ៌បៃតងស្រស់ ទឹកជ្រោះ ទឹកធ្លាក់ និងផ្ទះសម្បែងរបស់ជនជាតិភាគតិច ។ គន្ធាពេញចិត្តនឹងទេសភាពព្រៃភ្នំណាស់ ។ ចប់កម្មវិធីនោះ នាងនិយាយទៅកាន់ម្តាយ ៖ " អ្នកម៉ែ ! កូនចង់ទៅលេងខេត្តមណ្ឌលគិរីណាស់ ។ តើលោកឪពុក អ្នកម៉ែជូនកូនទៅបាន ឬទេ?" ។ ម្តាយគន្ធាឆ្លើយតប ៖ " មានអីកូន! ម៉ែក៏ចង់ឃើញផ្ទាល់ភ្នែកដែរ" ។ ឪពុកគន្ធាបន្ថែម ៖ "ចាំដល់ពេលចូលឆ្នាំខ្មែរ យើងនឹងទៅកម្សាន្តទាំងអស់គ្នា " ។

ថ្ងៃរង់ចាំបានមកដល់ គ្រួសារគន្ធានាំគ្នាជិះរថយន្តទេសចរណ៍មួយ ដែលផ្ទុកអ្នកដំណើរពេញ ។ ពេលធ្វើដំណើរមកដល់ស្លាកមួយផ្ទាំង ដែលមានសរសេរអក្សរធំៗ " មណ្ឌលគិរីស្វាគមន៍" គន្ធាមើលឃើញ ។ ឪពុកនាងនិយាយទៅកាន់កូន ៖ " អង្គុយចុះទៅកូន! រថយន្តកំពុងឆ្លងកាត់ផ្លូវឡើងភ្នំ ចុះភ្នំ" ។ គន្ធាអង្គុយចុះហើយសួរឪពុក ៖ "កូនចង់



www.elibraryofcambodia.org

ឃើញទឹកជ្រោះប៊ូស្រា និងផ្ទះរបស់ជនជាតិភាគតិចណាស់ ។ តើយើងទៅលេងកន្លែងនោះដែរឬទេ ពុក ?" ។ ឪពុកគន្ធាឆ្លើយ ៖ " ទៅណាកូន! ពុកជូនកូនគ្រប់កន្លែងដែលកូនបានឃើញតាមទូរទស្សន៍ " ។ នៅតាមផ្លូវ គន្ធានិងអ្នកដំណើរឯទៀតគយគន់ទេសភាពព្រៃភ្នំ និងរលកស្មៅយ៉ាងជក់ចិត្តរហូតដល់ទីក្រុង ។

គន្ធាដើរកម្សាន្តគ្រប់ទីកន្លែង ។ នាងសប្បាយនឹងស្ដាប់សន្ទឹកទឹកធ្លាក់ និងចុះងូតទឹកជ្រោះដ៏ត្រជាក់ជាមួយគ្រួសារ និងទេសចរដទៃទៀត ។

## សំណួរ

១. តើតើល្ងាចថ្ងៃសៅរ៍ គន្ធាបានមើលទូរទស្សន៍ឃើញអ្វី ?

២. តើនៅខេត្តមណ្ឌលគិរីមានអ្វីខ្លះ ដែលគួរឱ្យចាប់អារម្មណ៍ ?

៣. តើគន្ធាចង់ឃើញអ្វី ?

៤. តើនាងបានធ្វើអ្វីខ្លះ នៅពេលទៅដល់ខេត្តមណ្ឌលគិរី ?

## លំហាត់

ក. ហេតុអ្វីដែលនាំឱ្យគន្ធាចង់ទៅកម្សាន្ត នៅខេត្តមណ្ឌលគិរី ? ចូរជ្រើសរើសចម្លើយមួយត្រឹមត្រូវ ។

☐ ១. គន្ធាទំនេរ នៅក្នុងឱកាសចូលឆ្នាំខ្មែរ ។

☐ ២. គន្ធាបានឃើញទិដ្ឋភាពដ៏ស្រស់ របស់ខេត្តមណ្ឌលគិរីតាមទូរទស្សន៍ ។

☐ ៣. គន្ធាចង់ដើរកម្សាន្តឱ្យបានគ្រប់ខេត្ត ។

ខ. តើគន្ធាមានអារម្មណ៍ដូចម្តេច ពេលធ្វើដំណើរ ? ចូរជ្រើសចម្លើយមួយ ។

☐ ១. គន្ធាពិបាកចិត្ត ព្រោះខ្លាចមិនបានដើរលេងគ្រប់កន្លែង ។

☐ ២. គន្ធាភ័យព្រួយ ព្រោះរថយន្តបើកឡើងភ្នំចុះភ្នំ ។

☐ ៣. គន្ធាសប្បាយចិត្ត ព្រោះបានដើរកម្សាន្តគ្រប់កន្លែងដែលនាងចង់ ។



www.elibraryofcambodia.org

# សំណេរ

ក. ចូរបំពេញល្បះនឹងពាក្យខាងក្រោមឱ្យបានត្រឹមត្រូវ ។

| ទូរស័ព្ទ | ផ្ទះ | ទំនិញ | របៀបប្រើ | ព័ត៌មាន | រៀនសូត្រ |
|---|---|---|---|---|---|

ឪពុកខ្ញុំ ទើបនឹងទិញ ... ថ្មីមួយ ។ ខ្ញុំបានជម្រាបសួរគាត់ អំពី ... ទូរស័ព្ទនោះ ។ ពេលខ្លះ ខ្ញុំបាននិយាយទៅកាន់មិត្តភក្តិខ្ញុំតាមទូរស័ព្ទនោះ ដើម្បីសួរ ... ផ្សេងៗ ទាក់ទងនឹងការ... ។ ម្ដាយខ្ញុំចូលចិត្តប្រើវា នៅពេលគាត់ចង់ដឹងតម្លៃ ... ផ្សេងៗ ។ ចំណែកឪពុកខ្ញុំ និយាយទូរស័ព្ទមកកាន់គ្រួសារញឹកញាប់ណាស់ នៅពេលណាគាត់អញ្ជើញទៅណាឆ្ងាយពី ... ។

ខ. ចូរបំពេញល្បះខាងក្រោមតាមរូបភាពឱ្យបានសមស្រប ។



១. ខ្ញុំនិងប្អូន......... នាំគ្នាមើល..................... ។

២. ខ្ញុំឃើញ............................................... ។

៣. ខ្ញុំនិងប្អូន ........................................... ។

គ. ចូរតែងល្បះនឹងពាក្យ "សំបុត្រ ទូរស័ព្ទ វិទ្យុ ទូរទស្សន៍" ឱ្យបានមួយល្បះក្នុងពាក្យនីមួយៗ ។



www.elibraryofcambodia.org

## សញ្ញាអស្តា ឬសញ្ញាលេខប្រាំបី ( ៏ )

ឧទាហរណ៍ ៖

១. ខ្ញុំចូលចិត្តស្តាប់វិទ្យុ គាត់ក៏ចូលចិត្តដូចខ្ញុំដែរ ។

២. ហ៏ ! យកសំបុត្រនេះទៅអានចុះ ។

៣. ទូរស័ព្ទដ៏ទំនើបនេះ ជារបស់បងខ្ញុំ ។

៤. អុញ្ញនឹ៏! ម៉េចក៏មិនចូលចិត្តស្តាប់ព័ត៌មានថ្មីៗ?

> សញ្ញាអស្តា ឬលេខប្រាំបី ( ៏ ) ប្រើសម្រាប់សម្គាល់ស្រៈខ្លី ។

សញ្ញាអស្តា សម្រាប់ប្រើនៅលើព្យញ្ជនៈបួនតួគឺ ក ដ ន ហ ។

## លំហាត់

ក. ចូរប្រើសញ្ញាលេខប្រាំបីនៅក្នុងល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។

១. ព្រឹកមិញ ខ្ញុំបានទទួលព័ត៌មានដសំខាន់មួយ ។

២. អុញ្ញន! វិទ្យុនេះខូចបាត់ ។

៣. ហ! យកទូរស័ព្ទនេះទៅប្រើចុះ ។

៤. ឯងកចូលចិត្តមើលការប្រកួតកីឡាតាមទូរទស្សន៍ដែរមែន ឬទេ ?

ខ. ចូរតែងល្បះដោយប្រើពាក្យ ក៏ នឹ៏ ហ៏ ដ៏ ។

គ. ចូរជ្រើសរើសពាក្យ ក៏ នឹ៏ ដ៏ ហ៏ ដើម្បីបំពេញកថាខណ្ឌខាងក្រោមឱ្យបានត្រឹមត្រូវ ។

យើងនាំគ្នាអង្គុយស្តាប់ចម្រៀង ... ពីរោះក្រោមម្លប់ឈើ ... ត្រជាក់ ។ បន្ទាប់ម
អ្នកខ្លះបន្តដំណើរទៅមុខ ។ ខ្លះទៀត ... ត្រឡប់មកគេហដ្ឋានរបស់ខ្លួនវិញ ។



www.elibraryofcambodia.org

# កំណាព្យ ៖ មធ្យោបាយទាក់ទងគ្នា



## បទពាក្យ៧

មធ្យោបាយទាក់ទងច្រើនអនេក
តាមបែបប្លែកៗច្រើនអស្ចារ្យ
អ្នកខ្លះទាក់ទងតាមអក្ខរា
សរសេរជាសារផ្ញើទៅមក ។
ខ្លះទៀតនិយមប្រើទូរស័ព្ទ
និយាយរ៉ាយរ៉ាប់សាសងរក
មិត្តភក្តិបងប្អូនតាមលៃលក
ហៅទៅហៅមកឆាប់ទាន់ចិត្ត ។
វិទ្យុ ទូរទស្សន៍ កុំរំលង
ស្ដាប់ផងមើលផងដឹងការពិត
គ្រប់ទីបទាំងប្រាំទោះឆ្ងាយជិត
ទាក់ទងជិតស្និទ្ធបានគ្រប់គ្រា ។
មធ្យោយបាយចុងក្រោយផ្ដល់ព័ត៌មាន
ទោះបីក្រមានកុំរួញរា
ប្រើអ៊ីនធឺណិតទាក់ទងគ្នា
ស្រាវជ្រាវការងារតាមប្រាថ្នា ។

## លំហាត់

ចូររកពាក្យចួននឹងពាក្យខាងក្រោម ។

វគ្គទី១ ៖ អនេក អស្ចារ្យ ។

វគ្គទី ២ ៖ ទូរស័ព្ទ រក ។



www.elibraryofcambodia.org

## [១១] សំណេរ

ក. ចូរភ្ជាប់កន្សោមពាក្យក្នុងផ្នែក ក ទៅនឹងផ្នែក ខ ឱ្យបានជាល្បះត្រឹមត្រូវ ។

| ក | ខ |
|---|---|
| ១. វិទ្យាសាស្ត្រជឿនលឿន | ក. មិនមានប្រអប់សំបុត្រនៅតាមផ្ទះទេ ។ |
| ២. ប្រជាជនភាគច្រើន | ខ. ផ្ញើទៅមិត្តភក្តិ ។ |
| ៣. នៅជនបទឆ្ងាយៗ | គ. ចូលចិត្តមើលទូរទស្សន៍ជាងស្ដាប់វិទ្យុ ។ |
| ៤. ខ្ញុំចូលចិត្តសរសេរសំបុត្រ | ឃ. ទើបមានឧបករណ៍ប្រើប្រាស់ទំនើបៗ ។ |
| ៥. គេដំឡើងអង់តែនទូរទស្សន៍ | ង. នៅគ្រប់ទីរួមស្រុក ។ |

ខ. ចូរបំពេញល្បះខាងក្រោមឱ្យបានសមស្រប ។

១. ចាស់ៗ ចូលចិត្តស្ដាប់ ... តាមវិទ្យុ ។

២. ពេលបុណ្យទានម្ដងៗ គេច្រើនបញ្ចាំង ... តាមទូរទស្សន៍ ។

៣. នៅពេលមានភ្លៀងផ្គរយើងមិនត្រូវ ... ទេ ព្រោះវានាំឱ្យមាន ... ។

៤. គេផ្សាយដំណឹងមរណភាពតាម ... រាល់ថ្ងៃ ដើម្បីឱ្យ ... ឬ ... នៃសពបានដឹង ។

គ. ចូរបំពេញពាក្យចួនក្នុងកំណាព្យ ដោយជ្រើសរើសពាក្យក្នុងប្រអប់ខាងក្រោម ។

| កីឡា | ចាស់ | ណាស់ | សំឡេង | បាន | កាលណា | ប៉ុន្មាន | ក្មេង |
|---|---|---|---|---|---|---|---|

ទូរទស្សន៍ ឃើញរូបឮ ... ទាក់ទាញចិត្ត ... ឱ្យទស្សនា

រឿងល្ខោន យីកេនិង ... រៀនចប់ ... ឆ្លៀតកម្សាន្ត ។

អ្នកស្ដាប់វិទ្យុ ច្រើនមនុស្ស ... រីករាយខ្លាំង ... មិនរំខាន

ស្ដាប់ហើយ ស្ដាប់ទៀតចងចាំ ... ព័ត៌មាន ... ប្រាប់គ្នីគ្នា ។



www.elibraryofcambodia.org



# ទំនាក់ទំនងនៅសម័យវិទ្យាសាស្ត្រ

ចូរអានអត្ថបទខាងក្រោម ។ តើឧបករណ៍អ្វីខ្លះ ដែលមនុស្សប្រើប្រាស់ជាមធ្យោបាយសម្រាប់ទាក់ទង និងសម្រាប់ផ្សព្វផ្សាយព័ត៌មាន?



វិទ្យុជាមធ្យោបាយផ្សព្វផ្សាយ និងទទួលព័ត៌មានផ្សេងៗតាមរយៈរលកធាតុអាកាស ។ ស្ថានីយវិទ្យុផ្សាយកម្មវិធីជាសាធារណៈដល់មនុស្សម្នាទូទៅដូចជារឿងល្ខោន យីកេ ចម្រៀងតន្ត្រី ដើម្បីលម្ហែកម្សាន្ត ។ មិនតែប៉ុណ្ណោះ ប្រជាជនទូទាំងប្រទេសអាចស្តាប់ព័ត៌មានសំខាន់ៗ និងដឹងពីព្រឹត្តិការណ៍ជាតិ និងអន្តរជាតិដោយស្តាប់វិទ្យុ ។ លើសពីនេះ គេអាចស្តាប់ដំណឹងផ្សេងៗ ដូចជាដំណឹងសួររកបងប្អូនដំណឹងពីគ្រោះធម្មជាតិ ឬការអប់រំអំពីគ្រោះថ្នាក់នៃជំងឺថ្មីៗប្លែកៗ របៀបបង្ការជំងឺផ្សេងៗ ។ល ។



ក្រៅពីបានផ្សព្វផ្សាយតាមរយៈវិទ្យុ វិទ្យាសាស្ត្របានបង្កើតឧបករណ៍ផ្សព្វផ្សាយ និងទទួលព័ត៌មានមួយបែបទៀត ដែលគេអាចឮសំឡេងផង មើលឃើញរូបភាពផងនោះ គឺទូរទស្សន៍ ។ ទូរទស្សន៍អាចផ្សព្វផ្សាយរូបភាពពិតៗ តាមរយៈការផ្សាយបន្តផ្ទាល់ពីតំបន់ជាច្រើននៃពិភពលោក ឬក៏ផ្សាយពីប្រទេសកម្ពុជាទៅដល់បណ្តាប្រទេសផ្សេងទៀត ។



www.elibraryofcambodia.org



ក្រៅពីវិទ្យុនិងទូរទស្សន៍ បច្ចេកវិទ្យាបានបង្កើតឧបករណ៍មួយទៀត សម្រាប់ជួយមនុស្សក្នុងការទាក់ទងគ្នានោះ គឺទូរស័ព្ទ ។ តាមរយៈទូរស័ព្ទ គេអាចនិយាយផ្ទាល់ ទោះនៅជិតក្តី ឆ្ងាយក្តី បានយ៉ាងលឿន ឆាប់រហ័សទាន់ចិត្ត ។ ទូរស័ព្ទខ្លះដាក់នៅមួយកន្លែង តភ្ជាប់នឹងខ្សែបណ្តាញរបស់ទូរស័ព្ទ គេច្រើនហៅថាទូរស័ព្ទលើតុ “ ទូរស័ព្ទម្យ៉ាងទៀត គេអាចយកតាមខ្លួន ព្រោះវាមិនប្រើបណ្តាញ ។ ទូរស័ព្ទបែបនេះ គេហៅថាទូរស័ព្ទចល័ត ។

ចាប់តាំងពីវិទ្យាសាស្ត្របានបង្កើតវិទ្យុ ទូរទស្សន៍ និងទូរស័ព្ទមកមនុស្សអាចស្តាប់ មើល និងនិយាយទាក់ទងគ្នាបានគ្រប់ពេលវេលា ទោះឆ្លងប្រទេស ឬឆ្លងទ្វីបក៏ដោយ ។

## សំណួរ

១. តើវិទ្យុផ្សព្វផ្សាយកម្មវិធីអ្វីខ្លះ ?

២. តើវិទ្យុផ្សព្វផ្សាយតាមរយៈអ្វី ?

៣. តើវិទ្យុនិងទូរទស្សន៍ មានលក្ខណៈខុសគ្នាដូចម្តេច ?

៤. តើការបញ្ជូនព័ត៌មានតាមទូរស័ព្ទ មានលក្ខណៈដូចម្តេច ?

៥. តើទូរស័ព្ទមានប៉ុន្មានបែប ?

## លំហាត់

តើពាក្យណាមួយមានន័យដូចគ្នានឹងពាក្យ “ជាសាធារណៈ” ? ចូរជ្រើសរើសចម្លើយមួយត្រឹមត្រូវ ។

☐ ១. សំខាន់ៗ

☐ ២. ប្លែកៗ

☐ ៣. ជាទូទៅ ។



www.elibraryofcambodia.org

# ការនិយាយទូរស័ព្ទទៅកាន់មិត្ត

សុខាបាននិយាយទូរស័ព្ទទៅបបួលគន្ធាឱ្យមករៀនសូត្រជាមួយនាង នៅពេលវិស្សមកាល ។ ចូរអានការសន្ទនារវាងសុខា និងគន្ធាតាមទូរស័ព្ទ ។

គន្ធា ៖ ជម្រាបសួរ! ខ្ញុំគន្ធានិយាយ ។

សុខា ៖ សួស្តីគន្ធា! តើឯងស្តាប់សំឡេងខ្ញុំបាន ឬទេ ? ខ្ញុំគឺសុខាណា៎!

គន្ធា ៖ អូ !សួស្តីសុខា! តើឯងសុខសប្បាយដែរ ឬទេ ?

សុខា ៖ ចា៎! ខ្ញុំសុខសប្បាយទេ ។ ចុះឯងវិញ ?

គន្ធា ៖ ខ្ញុំក៏សុខសប្បាយដែរ ។ ខ្ញុំនឹកឯងណាស់ ។

សុខា ៖ គន្ធា!ខ្ញុំចង់បបួលឯងមករៀនធ្វើលំហាត់នៅផ្ទះខ្ញុំ ។ តើឯងយល់យ៉ាងម៉េចដែរ?

គន្ធា ៖ អូល្អណាស់! ខ្ញុំនឹងទៅរៀនជាមួយឯង ។ បើដូច្នេះ យើងគិតចាប់ផ្តើមពីថ្ងៃស្អែកតែម្តងទៅ ។

សុខា ៖ មែនហើយ ។ ខ្ញុំលាសិនហើយណា៎! ស្អែកជួបគ្នា ។

គន្ធា ៖ ចា៎ លាហើយ!

## សំណួរ

១. តើអ្នកណា ជាអ្នកនិយាយទូរស័ព្ទទៅរកអ្នកណា ?

២. តើអ្នកទទួលទូរស័ព្ទចាប់ផ្តើម ដោយប្រើពាក្យអ្វី ?

៣. នៅពេលបញ្ចប់ការសន្ទនា តើគេនិយាយពាក្យអ្វី ?

## លំហាត់

ចូរចាប់គូ រួចនិយាយសាសងគ្នាតាមទូរស័ព្ទ ដើម្បីសួរសុខទុក្ខ និងណាត់គ្នាទៅទិញសៀវភៅនៅបណ្ណាគារ ។



www.elibraryofcambodia.org

## ៥ ការសរសេររឿងនិទាន

ចូរអានរឿងខ្លីខាងក្រោម ដោយស្វែងយល់ការពណ៌នាតួអង្គ និងទីកន្លែង ។

### រឿង វាសនាអ្នកនេសាទ

ចំណាប់ ជាកូនរបស់ស្រីមេម៉ាយម្នាក់រស់នៅក្នុងខណ្ឌព្រៃនប់ ខេត្តព្រះសីហនុ ។ គេជាសិស្សពូកែ មានចិត្តល្អ ហើយស្លូតបូត ។ គេមានប្អូនស្រីម្នាក់ឈ្មោះ ចំណាន ។ ម្តាយគេចង់ឱ្យកូនស្រីឈប់រៀន ព្រោះខ្វះខាតជីវភាព តែចំណាប់មិនយល់ព្រម ។ ចំណាប់យល់ថា កូនស្រីក៏ត្រូវតែបានរៀនសូត្រជ្រៅជ្រះដូចកូនប្រុសដែរ ។ គេសុខចិត្តរៀនបណ្តើរ ជួយរកប្រាក់បណ្តើរ ។

នៅពេលវិស្សមកាល ចំណាប់បានទៅជួលទូកអ្នកជិតខាងយកទៅនេសាទ ហើយឱ្យប្អូនស្រីយកទៅលក់ ។ គេសន្សំបានប្រាក់មួយចំនួន ។

ព្រឹកមួយ ចំណាប់ចេញទូកទៅនេសាទ ។ គេពុំឃើញមានអ្នកនេសាទណាម្នាក់ឡើយ ។ ថ្ងៃនោះ គេនេសាទបានត្រីច្រើនខុសពីធម្មតា ។ កំពុងសប្បាយនឹងចាប់ត្រី ស្រាប់តែចំណាននិយាយទូរស័ព្ទមកប្រាប់ថា នឹងមានខ្យល់ព្យុះនៅពេលបន្តិចទៀត ។ ភ្លាមនោះ ខ្យល់ចាប់ផ្តើមបក់បន្តិចៗ មេឃខ្មៅងងឹតៗ ចំណាប់បញ្ឆាទូកឱ្យត្រឡប់មកច្រាំងវិញយ៉ាងតក់ក្រហល់ ។ ចំណាប់មកដល់ច្រាំងស្ទើរមិនទាន់ មេឃប្រែខ្មៅងងឹត រលកធំៗ បោកផ្ទប់ច្រាំងគួរឱ្យព្រឺខ្លាច ។ គេនឹកអរគុណប្អូនស្រី ដែលផ្តល់ដំណឹងបានទាន់ពេល បើមិនដូច្នោះទេគេនឹងជួបគ្រោះថ្នាក់មិនខាន ។

### លំហាត់

អ្នកបានអានរឿង វាសនាអ្នកនេសាទ និងរឿងដំណើរកម្សាន្តរបស់គន្ធា រួចហើយដែរ ។ ចូរអ្នកសរសេររឿងខ្លីមួយ ដោយមានការពណ៌នាតួអង្គ និងទីកន្លែងច្បាស់លាស់ត្រឹមត្រូវ ។ មុននឹងសរសេរ ចូរអ្នកគ្រោងធាតុផ្សេងៗនៃរឿងដូចជា ចំណងជើងរឿង តួអង្គ កាលអាកាស (ទីកន្លែង និងពេលវេលា) និងព្រឹត្តិការណ៍ ។



www.elibraryofcambodia.org

មេរៀនទី ៧

# ម្ហូបអាហារខ្មែរ



ម្ហូបអាហារខ្មែរ មានច្រើនមុខណាស់ដូចជា ស្ងោរជ្រក់ អន្លក់ ទឹកគ្រឿង ម្ជូរ កកូរ
ហើរ ... ។ អាហារពិសេសទាំងនេះ សម្បូរជីវជាតិ អាចជួយរាងកាយយើងឱ្យធំធាត់
មានសុខភាពមាំមួន ។



www.elibraryofcambodia.org

## ទំនាក់ទំនងរវាងហេតុនិងផល

ពេលអានអ្វីមួយ អ្នកតែងស្វែងយល់អំពីទំនាក់ទំនងរវាងហេតុការណ៍មួយទៅ ហេតុការណ៍ផ្សេងមួយទៀត ។ ជួនកាល ហេតុការណ៍មួយជាដើមហេតុ ដែលបង្កឱ្យ ហេតុការណ៍មួយទៀតកើតឡើង ។ ទំនាក់ទំនងបែបខាងលើនេះ ហៅថាទំនាក់ទំនង រវាងហេតុ និងផល ។

ចូរអានឧទាហរណ៍ខាងក្រោម ។ ល្បះដែលមានគំនូសពីក្រោមជាហេតុ ឯល្បះ ដែលសរសេរអក្សរទ្រេតជាផល ។

១. <u>ការបរិភោគត្រីច្រើន</u> *នាំឱ្យមានអាយុវែង* ។

២. <u>គ្រួសារសំចូលចិត្តបរិភោគទឹកគ្រឿង</u> *ព្រោះវាមានរសជាតិឈ្ងុយឆ្ងាញ់* ។

៣. <u>ខ្មែរយើងតែងតែនាំគ្នាធ្វើប្រហុក ផ្អក</u> *មកពីគេអាចទុកវាបានយូរ* ។

អ្នកអាចស្គាល់ទំនាក់ទំនងរវាងហេតុ និងផល តាមរយៈពាក្យ : ដោយសារ ព្រោះ ពីព្រោះ ទើប ហេតុនេះ ហេតុនេះហើយ មកពី បណ្តាលមកពី នាំឱ្យ ធ្វើឱ្យ... ។

ទំនាក់ទំនងរវាងហេតុ និងផល គឺទំនាក់ទំនងរវាងអំពើ និងផលដែលបាន មកពីអំពើនោះ ។ ហេតុជាហេតុការណ៍កើតឡើងមុន ឯផលជាលទ្ធផលនៃហេតុ ។

### លំហាត់

ចូរចម្លងល្បះខាងក្រោម រួចគូសគំនូសមួយពីក្រោមល្បះណា ដែលប្រាប់ហេតុនិង គូសគំនូសពីរ ពីក្រោមល្បះណាដែលប្រាប់ផល ។

១. ប្រហុក ផ្អកឆ្នាំនេះឡើងថ្លៃ ព្រោះប្រទេសយើងមិនសូវសម្បូរត្រី ។

២. មីងសនពូកែធ្វើម្ហូបណាស់ ទើបគាត់លក់ម្ហូបដាច់ជាងគេ ។

៣. សុខាឈឺពោះ ព្រោះនាងញុំចំណីអាហារមិនស្អាត ។

៤. អ្នកជំងឺពក ក ភាគច្រើន បណ្តាលមកពីបរិភោគអាហារប្រចាំថ្ងៃខ្វះជាតិ អ៊ីយ៉ូត ។



www.elibraryofcambodia.org

# ការបរិភោគអាហារនៅភោជនីយដ្ឋាន

ចូរអានអត្ថបទ រួចឆ្លើយនឹងសំណួរ ។



ថ្ងៃអាទិត្យនេះ ម្តាយឪពុកខ្ញុំបាននាំខ្ញុំទៅបរិភោគអាហារ នៅភោជនីយដ្ឋានមួយនៅក្រុងភ្នំពេញ ។ ភោជនីយដ្ឋាននោះ មានទីធ្លាធំទូលាយសម្រាប់ចតរថយន្ត និងមានការរៀបចំតុបតែងលម្អគួរឱ្យចាប់អារម្មណ៍ ។

នៅខាងក្នុងភោជនីយដ្ឋាន មានការរៀបចំទីកន្លែងស្អាតបាតសមរម្យ ប្រកបដោយផាសុកភាព ។ ចុងភៅមានស្នាដៃចំណានក្នុងការចម្អិនអាហារខ្មែរគ្រប់មុខ ហើយអាហារមានរសជាតិឈ្ងុយឆ្ងាញ់គួរឱ្យចង់ទទួលទាន ។ មិនតែប៉ុណ្ណោះអាហារ និងសម្ភារៈប្រើប្រាស់មានអនាម័យល្អ ។ អ្នកបម្រើរហ័សរហួន ថែមទាំងរួសរាយរាក់ទាក់ចំពោះភ្ញៀវជានិច្ច ។ គ្រួសារខ្ញុំ ពេញចិត្តសម្លកកូរគ្មោត និងញាំស្ដៅ ។ ភ្ញៀវដែលបានមកទីនេះពេញចិត្ត និងកោតសរសើរថាម្ហូបឆ្ងាញ់គ្រប់មុខ ហើយតម្លៃក៏សមរម្យ ។ អាស្រ័យហេតុនេះទើបធ្វើឱ្យភ្ញៀវចេញចូលបរិភោគអាហារយ៉ាងច្រើនកុះករ ជារៀងរាល់ថ្ងៃ ។

ខ្ញុំរីករាយក្នុងចិត្តណាស់ ព្រោះបានបរិភោគអាហារដែលមានឱជារសនៅទីនេះ បានស្រូបយកខ្យល់អាកាសបរិសុទ្ធ និងស្ដាប់តូរ្យតន្ត្រីយ៉ាងសែនពីរោះទៀតផង ។



www.elibraryofcambodia.org

## សំណួរ

១. តើគ្រួសារនោះ នាំគ្នាទៅណា ?
២. តើភោជនីយដ្ឋាននោះ បានរៀបចំដូចម្ដេចខ្លះ ?
៣. តើចុងភៅនៅទីនោះ មានស្នាដៃដូចម្ដេច ?
៤. តើម្ហូបអាហារនៅទីនោះ មានលក្ខណៈដូចម្ដេច ?
៥. ហេតុអ្វីបានជាភោជនីយដ្ឋាននេះ មានភ្ញៀវចេញចូលច្រើនកុះករ ?
៦. តើក្មេងក្នុងអត្ថបទនេះ មានចិត្តដូចម្ដេច ចំពោះការបរិភោគអាហារនៅទីនោះ ?

## លំហាត់

ក. **ចូរអានល្បះនីមួយៗខាងក្រោម រួចបង្ហាញហេតុ និងផល ។**

១. ភោជនីយដ្ឋាននេះលក់ដាច់ជាងគេ ព្រោះម្ហូបអាហារមានអនាម័យ ។
២. ភោជនីយដ្ឋាននេះមានភ្ញៀវច្រើន ដោយសារអ្នកបម្រើរហ័សរហួន ។
៣. កុមារក្នុងអត្ថបទសប្បាយចិត្ត មកពីគេបានបរិភោគអាហារមានរសជាតិឆ្ងាញ់ ។

ខ. **ចូរភ្ជាប់ឃ្លាក្នុងផ្នែកលេខ ទៅនឹងឃ្លាក្នុងផ្នែកព្យញ្ជនៈ ឱ្យទៅជាល្បះដែលបង្ហាញទំនាក់ទំនងហេតុ និងផល(ដោយប្រើពាក្យ មកពី ទើប ធ្វើឱ្យ ព្រោះដោយសារ) ។**

| | |
|---|---|
| ១. ពួកគេចូលចិត្តភោជនីយដ្ឋាននេះ | ក. នាងបានញ៉ាំអាហារបំប៉នបានត្រឹមត្រូវ ។ |
| ២. ចុងភៅមានបទពិសោធន៍ច្រើន | ខ. មានបន្លែច្រើនមុខ ។ |
| ៣. អ្នកបម្រើរួសរាយរាក់ទាក់ | គ. ភ្ញៀវពេញចិត្ត ។ |
| ៤. កុមារនេះ មានសុខភាពល្អ | ឃ. មានទីកន្លែងស្អាត ខ្យល់អាកាសបរិសុទ្ធ ។ |
| ៥. ខ្ញុំចូលចិត្តសម្លកកូរ | ង. គាត់ស្ងួឆ្ងាញ់លើសគេ ។ |



www.elibraryofcambodia.org

# ការបំពេញបែបបទងាយៗ

មនុស្សម្នាក់ៗ តែងមានតម្រូវការចាំបាច់ក្នុងការបំពេញបែបបទងាយៗដូចជា ពាក្យសុំចូលរៀន សលាកបត្រ ឬសរសេរប្រវត្តិរូបផ្ទាល់ខ្លួន ។

ចូរពិនិត្យពាក្យសុំចូលរៀនខាងក្រោម ។ តើគេសរសេរដូចម្តេចខ្លះ ?

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ពាក្យសុំចុះឈ្មោះចូលរៀនថ្នាក់ទី ៦

ឆ្នាំសិក្សា ២០០៩-២០១០

ខ្ញុំបាទ/ នាងខ្ញុំឈ្មោះ យិម វ៉ាន់ទូ ភេទ ប្រុស ជាតិ ខ្មែរ

កើតនៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៩៨

នៅឃុំ/ សង្កាត់ អំពិលតាពក ស្រុក/ខណ្ឌ កោះសូទិន ខេត្ត/ក្រុង កំពង់ចាម

ជាសិស្សថ្នាក់ទី៥ នៃសាលា បឋមសិក្សាអូរាំងឪ

ឪពុកឈ្មោះ យិម ណារិទ្ធិ មុខរបរ កសិករ

អាណាព្យាបាលឈ្មោះ ហែម វ៉ាន់នី មុខរបរ មន្ត្រីក្រសួងសុខាភិបាល

អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៩០ ផ្លូវ ៤៦៨ ក្រុមទី ១ សង្កាត់ ទួលទំពូងទី១

ខណ្ឌ ចំការមន រាជធានីភ្នំពេញ ទូរស័ព្ទលេខ ០១៦ ៧៨ ៦៩ ៧៧

**សូមគោរពជូន**

លោកនាយកសាលាបឋមសិក្សា ទួលទំពូង

តាមរយៈ លោកនាយកសាលាបឋមសិក្សា អូរាំងឪ

សូមលោកនាយកមេត្តាពិនិត្យលទ្ធភាពចុះឈ្មោះខ្ញុំបាទ/ នាងខ្ញុំឱ្យបានចូលរៀន ថ្នាក់ទី៦ ក្នុងឆ្នាំសិក្សា ២០០៩-២០១០នៅគ្រឹះស្ថានសិក្សារបស់លោកដោយ អនុគ្រោះ ។



www.elibraryofcambodia.org

សូមជូនភ្ជាប់មកជាមួយ ៖

១. ពាក្យសុំចុះឈ្មោះចូលរៀន..............................០១ច្បាប់
២. សៀវភៅតាមដានការសិក្សា..............................០១ក្បាល
៣. សលាកបត្រឯកត្តជន ( បិទរូបថត)..............................០២សន្លឹក
៤. អត្តសញ្ញាណប័ណ្ណ..............................០១សន្លឹក
៥. លិខិតផ្សេងៗ..............................០១សន្លឹក

ខ្ញុំបាទ/ នាងខ្ញុំសូមសន្យាថា នឹងគោរពតាមបទបញ្ជាផ្ទៃក្នុងសាលាឱ្យបានដាច់ខាត ។ បើខ្ញុំបាទ/ នាងខ្ញុំប្រព្រឹត្តផ្ទុយនឹងចំណុចណាមួយ ខ្ញុំសូមទទួលកំហុសតាមច្បាប់ជាធរមាន ។

សូមលោកនាយកមេត្តាទទួលនូវសេចក្ដីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/ នាងខ្ញុំ ។

ភ្នំពេញថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០០៩

ហត្ថលេខា

ឈ្មោះ យឹម រ៉ាវុទ្ធ

## លំហាត់

**ក. ចូរចម្លងគំរូពាក្យសុំចូលរៀនខាងលើ រួចបំពេញព័ត៌មានផ្ទាល់ខ្លួនអ្នកក្នុងចន្លោះ ។**

**ខ. ចូរបំពេញល្បះខាងក្រោមឱ្យបានសមស្រប ។**

១. ខ្មែរចូលចិត្តបរិភោគ........... ជាមួយអន្លក់ស្រស់ដូចជា................. ។
២. ម្ដាយខ្ញុំចិញ្ច្រាំ................... យកទៅហួបជាមួយត្រសក់នៅឯ........... ។
៣. យើងត្រូវលាងបន្លែឱ្យស្អាតទើប.............. ។
៤. ខែនេះត្រីក្រាញ់អាំងមាន.......... ឆ្ងាញ់ណាស់ ។
៥. គេដាក់ទ្រូបាន........... និង.......... ជាច្រើន ។



www.elibraryofcambodia.org

# កិរិយា

ចូរអានឧទាហរណ៍ខាងក្រោម ។ តើពាក្យណាខ្លះជាកិរិយា ?

១. ធីតាញ៉ាំបាយ ។

២. ជីដូនសំធ្វើនំបញ្ចុក ។

៣. ម្ដាយសុភីចម្អិនម្ហូបអាហារ ។

៤. មាន់គករងាវ ។

៥. ទឹកជ្រោះហូរ ។

ពាក្យ "ញ៉ាំ ធ្វើ ចម្អិន រងាវ ហូរ" សម្គាល់អំពើ ឬសកម្មភាព ។ ពាក្យទាំងនេះ ជាកិរិយា ។

> កិរិយា ជាពាក្យសម្ដែងអំពើ ឬបង្ហាញសកម្មភាព ។

## លំហាត់

**ក. ចូររកពាក្យជាកិរិយានៅក្នុងចំណោមពាក្យខាងក្រោម ។**

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ហូប | សម្អាត | បន្លែ | សាច់ | ឆ្ងាញ់ | អង្គុយ | ដើរ | ត្រី | ស្ល | មើល |

**ខ. ចូររកពាក្យជាកិរិយាឱ្យបាន២ពាក្យ ។**

**គ. ចូររកកិរិយានៅក្នុងល្បះនីមួយៗខាងក្រោម ។**

១. សុខស្ទូចបានត្រីផ្ទក់មួយ ។

២. មីងសានភ្លក្សត្រីក្អែក ។

៣. ជីដូនខ្ញុំពិសា ខត្រីកញ្ចូក ។

៤. សម្លប្រហើរននោងមានរសជាតិឆ្ងាញ់ ។

៥. ខែវស្សាអ្នកស្រែចូលចិត្តហូបផ្អកកំពឹស ។



www.elibraryofcambodia.org

## ១៦ ជំងឺគ្រុនផ្តាសាយថ្មី អេ អេច១ អិន១ (A /H1 N1)

ចូរស្តាប់អត្ថបទ រួចឆ្លើយនឹងសំណួរ ។



## សំណួរ

១. តើជំងឺគ្រុនផ្តាសាយថ្មី អេ អេច១ អិន១ (A /H1 N1) កើតឡើងនៅថ្ងៃណា ? ខែណា ? ឆ្នាំណា ?

២. តើជំងឺនេះ អាចចម្លងពីមនុស្សទៅមនុស្សដោយរបៀបណា ?

៣. តើជំងឺនេះ មានអាការសង្ស័យដូចម្តេចខ្លះ ?

៤. ពេលជំងឺកំពុងរាលដាល តើអង្គការសុខភាពពិភពលោកណែនាំដូចម្តេចខ្លះ ?

## លំហាត់

ចូរអានល្បះខាងក្រោមនេះ ។ តើល្បះណាជាហេតុ ល្បះណាជាផល ?

១. នៅប្រទេសកម្ពុជា អ្នកឆ្លងជំងឺផ្តាសាយថ្មីមួយចំនួនមិនបណ្តាលឱ្យស្លាប់ទេ *ព្រោះបានព្យាបាលទាន់ពេលវេលា ។*

២. យើងមិនគួរចូលរួមទស្សនាការប្រកួតកីឡា ការប្រគុំតន្ត្រី ពិធីបុណ្យសាសនាផ្សេងៗ ព្រោះជំងឺនេះឆ្លងពីមនុស្សទៅមនុស្សដោយអ្នកជំងឺក្អក កណ្តាស់ ។



www.elibraryofcambodia.org

## គុណកិរិយា

ចូរអានឧទាហរណ៍ខាងក្រោម ។ ពាក្យដែលសរសេរជាអក្សរដិត ជាគុណកិរិយា ។

១. វីរៈញ៉ាំច្រើន ។

២. ម្ដាយជីតាស្លន្ឆាញ់ ។

៣. គាត់ជាចុងភៅល្បីអស្ចារ្យ ។

៤. នារីរាំសមណាស់ ។

៥. ជីតាខ្ញុំដើរលឿនណាស់ ។

៦. គាត់ចូលចិត្ត ហូបសម្លសាបល្មម ។

ពាក្យ "ច្រើន ឆ្ងាញ់" បញ្ជាក់លក្ខណៈរបស់កិរិយា "ញ៉ាំ ស្ល" ។ ពាក្យ "អស្ចារ្យ ល្មម" បញ្ជាក់លក្ខណៈរបស់គុណនាម "ល្បី សាប" ។ ពាក្យ "ណាស់" បញ្ជាក់លក្ខណៈរបស់គុណកិរិយា "សម លឿន" ។ ពាក្យទាំងនេះ ជាគុណកិរិយា ។

គុណកិរិយា ជាពាក្យបញ្ជាក់លក្ខណៈរបស់កិរិយា គុណនាម ឬគុណកិរិយា ។

## លំហាត់

ក. **ចូររកគុណកិរិយានៅក្នុងល្បះខាងក្រោម ។**

១. ជីដូនខ្ញុំមានសុខភាពល្អណាស់ ។

២. សុខានិយាយពួតិចៗ ។

៣. សម្លនេះប្រៃពេក ។

៤. ជីតាខ្ញុំពិសាបាយយឺតៗ ។

៥. ពូសំហូបតិច ប៉ុន្តែធ្វើការច្រើន ។

**ចូរតែងល្បះដោយប្រើគុណកិរិយា៖ ច្រើន យូរ ខ្លាំង ។**



www.elibraryofcambodia.org

# រឿង អន្ទង់វែងឆ្នាំងវែង

ចូរអានរឿង រួចឆ្លើយនឹងសំណួរ ។



ក្នុងកាលកន្លងទៅហើយ មានមនុស្សពីរនាក់ជាប្ដីប្រពន្ធ ។ ថ្ងៃមួយ ប្ដីចេញទៅរក
អន្ទង់ ដើម្បីធ្វើជាអាហារ ។ ប្ដីរកបានអន្ទង់មួយ មកប្រគល់ឱ្យប្រពន្ធ ហើយប្រាប់ឱ្យយក
ទៅស្ល ។ ប្រពន្ធឆ្លើយ ៖“ ចុះអន្ទង់នេះវែងម្ល៉េះ បានឆ្នាំងវែងពីណាមកស្ងោរអន្ទង់នេះ
បាន ? ” ។ ប្ដីឮហើយនឹកថា ប្រពន្ធខ្លួនល្ងង់ណាស់ក៏ប្រាប់ទៅប្រពន្ធ ៖“ បើឯងរកឆ្នាំង
វែងពុំបានទេ ឯងយកអន្ទង់នេះទៅព្យួរទុកទៅ” ។ ប្រពន្ធក៏យកអន្ទង់ទៅព្យួរទុក ហើយ
គេចទៅបំបៅកូនក្នុងមុង ។ ប្ដីយកអន្ទង់នោះមកកាប់ចិញ្ច្រាំ ហើយយកឆ្នាំងមកដា
ស្លកកូរ ។ លុះឆ្អិន គាត់ដោះដួស រួចហៅប្រពន្ធឱ្យមកស៊ី ស៊ីរួចលាងចានទុកតែស
អន្ទង់នោះសល់បន្តិចនៅបាតឆ្នាំង ។ ប្ដីមិនលាងឆ្នាំងនោះទេ ហើយចេញទៅភ្ជួរស្រែបា
ទៅ ។ ឯប្រពន្ធដឹងថាប្ដីចេញទៅបាត់ នឹកដល់សម្លឆ្ងាញ់ក៏ស្ទុះក្រោកឡើងទៅយកឆ្នាំង
នោះមកលិទ្ធ ។ នាងនោះខំលិទ្ធណាស់ទៅ ក្បាលនាងចូលទៅក្នុងឆ្នាំងគ្របជាប់ពីលើ
មិនដឹងធ្វើដូចម្ដេចនឹងយកឆ្នាំងចេញបាន ក៏វារទៅពួនក្នុងមុង ។ លុះប្ដីត្រឡប់មកពីភ្ជួ
ស្រែវិញរកប្រពន្ធមិនឃើញ ក៏ស្រែកហៅ ស្រាប់តែឮសូរសំឡេងឆ្លើយរាងក្ខួរវល់ ។ គា
នឹកសង្ស័យក៏ចូលទៅបើកមុងមើល ឃើញប្រពន្ធជាប់ក្បាលនៅក្នុងឆ្នាំង ។ គាត់យ
ដំបងវាយឆ្នាំងនោះបំបែក ។ ប្រពន្ធលាន់មាត់ស្រែក ៖“ យ៉ា! អញពួននឹងគាត់ឯ
សោះ ” ។ ប្ដីនឹកអស់សំណើចក៏ដើរចេញទៅ ។



www.elibraryofcambodia.org

## សំណួរ

១. តើបុរសទៅរកបានអ្វីមកធ្វើម្ហូប ?

២. ពេលបុរសនោះប្រគល់អន្ទង់ឱ្យ តើប្រពន្ធគាត់ឆ្លើយថាដូចម្ដេច ?

៣. តើបុរសនោះ ចាំបាច់រកឆ្នាំងវែងមកស្លដែរ ឬទេ ? តើគាត់ធ្វើដូចម្ដេច ទើបស្ល អន្ទង់បាន ?

៤. តើអ្នកយល់ថា ប្រពន្ធបុរសនោះជាមនុស្សដូចម្ដេច ?

## លំហាត់

ចូរអានអត្ថបទឡើងវិញ រួចរកពាក្យជាកិរិយា និងគុណកិរិយាឱ្យបានមួយមុខចំនួន ៣ ពាក្យ ។

## សំណេរ

ក. ចូររៀបពាក្យក្នុងជួរនីមួយៗជាល្បះត្រឹមត្រូវ ។

១.

| | | | | | |
|---|---|---|---|---|---|
| ម្ហូប | មុខ | ខ្មែរ | ច្រើន | ណាស់ | មាន |

២.

| | | | | |
|---|---|---|---|---|
| យើង | ខ្មែរ | ហូប | ប្រហុក | និយម |

៣.

| | | | | | | | |
|---|---|---|---|---|---|---|---|
| ឱ្យ | ដៃ | ត្រូវ | លាង | មុននឹង | ញ៉ាំ | ស្អាត | អាហារ |

ខ. ចូរតែងល្បះ ៣ ទាក់ទងគ្នាតាមរូបភាពខាងក្រោម ។





www.elibraryofcambodia.org

# មេសូត្រ ៖ បញ្ជីម្ហូបអាហារខ្មែរ

ចូរសូត្រមេសូត្របទកាកគតិ រួចឆ្លើយនឹងសំណួរ ។



ម្ហូបខ្មែរច្រើនមុខ
ត្រីងៀតត្រីប្រៃ
មានសម្រាប់ទុក
រសព្រៃប្រសើរ
ប្រហុកត្រីឆ្អើរ
ទោះធ្វើដំណើរ
ងាយខ្ចប់តាមខ្លួន ។

កក្កូរស្ងោរជ្រក់
ប្រហើរហ្មុកត្រី
ទឹកគ្រឿងអន្លក់
បក្សីលាក់ខ្លួន
ផ្កាស្ងោត្រកួន
ខួរក្តាមក្រមួន
ជួយកាយមាំល្អ ។

ម្ជូរព្រៃត្រីកប់
ចេះហើយកត់ទុក
ខ្មែរប៉ិនប្រសប់
គ្រប់មុខបន្ត
ថ្មែម្ហូបបវរ
ជាកេរតំណ
បញ្ជីម្ហូបខ្មែរ ។



www.elibraryofcambodia.org

## សំណួរ

១. តើម្ហូបអាហារខ្មែរ ក្នុងមេសូត្រនេះ មានឈ្មោះអ្វីខ្លះ ?

២. តើម្ហូបអ្វីខ្លះងាយខូចតាមខ្លួន ?

៣. ដើម្បីរក្សាមុខម្ហូបដល់ជំនាន់ក្រោយ តើគេធ្វើដូចម្ដេច ?

៤. តើមេសូត្រនេះ អប់រំអ្នកដូចម្ដេច ?

## លំហាត់

ចូរសូត្រមេសូត្រឡើងវិញ រួចរកពាក្យចួនក្នុងវគ្គនីមួយៗ ។

ក. ពាក្យចួននឹងពាក្យ " មុខ "

☐ ១. ប្រហុក

☐ ២. ទុក

☐ ៣. ទោះ ។

ខ. ពាក្យចួននឹងពាក្យ " ជ្រក់ "

☐ ១. អន្លក់

☐ ២. ហ្មុក

☐ ៣. ត្រកួន ។

គ. ពាក្យចួននឹងពាក្យ " គប់ "

☐ ១. កត់

☐ ២. បវរ

☐ ៣. ប្រអប់ ។



www.elibraryofcambodia.org

ឃ. ចូរជ្រើសរើសពាក្យក្នុងប្រអប់ មកបំពេញវគ្គកាព្យខាងក្រោមនេះឱ្យបានត្រឹមត្រូវ ។

| គោក | កាយា | មានះ | សំចៃ | ប៉ង | រំខាន |
|---|---|---|---|---|---|

មុនបរិភោគ ទោះម្ហូបទឹក ... ត្រូវលាងជម្រះ
ដៃឱ្យស្អាតផង កុំ... ចង់ឈ្នះ បើរឹង ...
កើតរោគក្នុងប្រាណ ។

កូនអើយរក្សា ថែចូន ... រស់នៅក្សេមក្សាន្ត
មានអនាម័យ ... ប្រាក់បាន ស្រួលមិន ...
ជីវិតគ្រួសារ ។

## សំណេរ

ក. ចូរស្រង់កិរិយានៅក្នុងល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។

១. ម្ហូបខ្មែរមានច្រើនមុខ ។
២. ត្រីងៀត ត្រីប្រៃ មានរសជាតិប្រសើរ ។
៣. ខ្មែរយើងពូកែច្នៃម្ហូបអាហារ ។
៤. គេច្រើនខ្ចប់ម្ហូបក្រៀមតាមខ្លួន ពេលធ្វើដំណើរ ។
៥. ចាស់បុរាណ បានកត់ទុកមុខម្ហូបខ្មែរជាច្រើន ។

ខ. ចូររកគុណកិរិយានៅក្នុងល្បះខាងក្រោម ។

១. ជីតាខ្ញុំហូបសម្លប្រៃណាស់ ។
២. គាត់ពិសាទឹកច្រើន ។
៣. គ្រួសារខ្ញុំហូបបាយយូរណាស់ ។
៤. យើងចូលចិត្តអាហារសាបបន្តិច ។



www.elibraryofcambodia.org

# ការសម្តែងការចូលចិត្តនិងមិនចូលចិត្ត

ពេលចេញលេង បុប្ផាបបួលសុខា ទៅទិញចំណីអាហារដែលគេលក់នៅសាលារៀន ។ ចូរអានការសន្ទនា ។ តើបុប្ផាចូលចិត្តញ៉ាំអ្វី ហើយសុខាចូលចិត្តញ៉ាំអ្វី ?

បុប្ផា ៖ សុខា! ចេញលេងហើយ មកយើងនាំគ្នាទៅទិញចំណីញ៉ាំ ។

សុខា ៖ សុំទោសបុប្ផា! ខ្ញុំមិនទៅទេ ព្រោះខ្ញុំបានយកបាយកញ្ចប់មកពីផ្ទះហើយ ។

បុប្ផា ៖ ម្យ៉ាងដែរសុខា! តែខ្ញុំចូលចិត្តទិញចំណីអាហារនៅសាលារៀនវិញ ព្រោះខ្ញុំអាចជ្រើសរើសចំណីអាហារណា ដែលខ្ញុំចូលចិត្តញ៉ាំដូចជា មីកញ្ចប់ ប្រហិតបំពង ស្លាបមាន់អាំង ឬទឹកកកឈូស ។

សុខា ៖ ត្រូវហើយបុប្ផា! ប៉ុន្តែខ្ញុំចូលចិត្តរសជាតិចំណីអាហារ ដែលម្តាយខ្ញុំចម្អិនជាងអាហារនៅទីនេះ ។ ម្យ៉ាងទៀត អាហារយកមកពីផ្ទះមានសុវត្ថិភាពជាង ។

បុប្ផា ៖ មែនហើយសុខា ឯងនិយាយត្រូវណាស់ ។ ម្តាយឪពុកខ្ញុំក៏តែងប្រដៅខ្ញុំ ឱ្យញ៉ាំតែចំណីអាហារណា ដែលមានអនាម័យល្អ ។ ពីថ្ងៃនេះទៅ ខ្ញុំនឹងយកអាហារមកពីផ្ទះដូចឯងដែរ ។

## សំណួរ

១. តើបុប្ផាបបួលសុខាទៅណា ?

២. តើសុខាព្រមទៅជាមួយបុប្ផាដែរ ឬទេ ? ព្រោះអ្វី ?

៣. ហេតុអ្វីបានជាសុខា មិនចូលចិត្តញ៉ាំចំណីអាហារនៅសាលារៀន ?

៤. តើបុប្ផាចូលចិត្តចំណីអាហារអ្វីខ្លះ ?

៥. តើម្តាយឪពុកបុប្ផាប្រដៅបុប្ផាដូចម្តេច ?

## លំហាត់

ចូររាប់ឈ្មោះចំណីអាហារណាដែលអ្នកចូលចិត្ត និងមិនចូលចិត្ត និងគ្រឿងផ្សំរបស់វាប្រាប់ដល់ក្រុមតូចៗរបស់អ្នក ឬថ្នាក់ទាំងមូល ។



www.elibraryofcambodia.org

# ការបំពេញកម្រងសំណួរ

ក. ចូរអានកម្រងសំណួរខាងក្រោម រួចសរសេរចម្លើយ ។

១. តើចំណីអាហារដែលយើងបរិភោគរាល់ថ្ងៃ មានប៉ុន្មានប្រភេទ ? អ្វីខ្លះ ?

២. តើប្រភេទនីមួយៗមានអ្វីខ្លះ ?

៣. តើប្រភេទចំណីអាហារនីមួយៗនោះ ជួយរាងកាយយើងដូចម្ដេចខ្លះ ?

៤. តើមនុស្សម្នាក់ៗ អាចរស់នៅដោយមិនបាច់បរិភោគចំណីអាហារទាំងនោះបានដែរ ឬទេ ?

៥. ដើម្បីឱ្យមានតុល្យភាពក្នុងការចិញ្ចឹមរូបរាងកាយលូតលាស់ល្អ តើអ្នកត្រូវធ្វើដូចម្ដេច ?

ខ. ចូរអាន និងបំពេញកម្រងសំណួរខាងក្រោមនេះ ។

១. តើរាល់ថ្ងៃ អ្នកបរិភោគ ................ ?

២. នៅក្នុងគ្រួសារអ្នក តើអ្នកណាជាអ្នកចម្អិន ................ ?

៣. តើអ្នកជួយធ្វើ .......... នៅពេលហូបបាយ ?

៤. តើការបរិភោគអាហារខ្វះអនាម័យនាំឱ្យ ................ ?

៥. តើអាហារអ្វីខ្លះ ដែលជួយ ................ យើងឱ្យមានកម្លាំង ?

៦. មុននឹងហូបបាយ តើ..................... ?

៧. តើអ្នកចូលចិត្ត........................ អ្វីជាងគេ ?

៨. ហេតុអ្វីបានជា យើងត្រូវបរិភោគ ................ ឱ្យបានច្រើន ?

៩. តើអ្នកចេះធ្វើម្ហូប ..................... ?

១០. តើការញ៉ាំផ្លែឈើ ជួយធ្វើឱ្យរាងកាយយើង ................... ?



www.elibraryofcambodia.org

# មេរៀនទី ៩ សណ្ឋានដីប្រទេសយើង



ប្រទេសយើង មានសណ្ឋានដីខុសប្លែកគ្នា ។ តំបន់ខ្លះជាភ្នំ ខ្លះជាវាលទំនាប ខ្លះជា រាប ឯតំបន់ខ្លះទៀតជាសមុទ្រ ឬទន្លេដែលមានកោះជាច្រើន ។ ស្ថានភាពដីខុសប្លែក នេះ ធ្វើឱ្យប្រជាជនមានរបររកស៊ី និងជីវភាពរស់នៅខុសប្លែកគ្នា ។

តើតំបន់ដែលអ្នករស់នៅមានសណ្ឋានដីដូចម្ដេច ?



www.elibraryofcambodia.org

# មេសូត្រ ៖ សម្រស់ទឹកដីកម្ពុជា

ចូរអានកំណាព្យបទកាកគតិខាងក្រោម ។ តើគេនិយាយពីអ្វីខ្លះ ?



ទឹកដីកម្ពុជា ល្អស្រស់សោភា គ្រប់ទឹកន្លែង
សមុទ្រព្រៃភ្នំ ខ្ពង់រាបវាលវែង គួរឱ្យស្ងប់ស្ងែង
ទាក់ចិត្តទេសចរ ។

ទំនាបនានា ដំណាំផ្លែផ្កា ល្អស្រស់បវរ
ដីកោះដីជាតិ ដុះជាបន្ត ខំថៃឱ្យល្អ
មរតកដូនតា ។

តំបន់ព្រៃភ្នំ ដើមឈើតូចធំ ប្រណីតអស្ចារ្យ
ជាទីជម្រក បក្សីបក្សា ម្រឹគីម្រឹគា
ហោលលេងពេញព្រៃ ។

កូនខ្មែរគ្រប់ប្រាណ ប្រទេសថ្កើងថ្កាន ដោយសារអ្នកថ្លៃ
ចេះថែរក្សា ចេះឱ្យតម្លៃ ស្គាល់ភាពប្រពៃ
នៃទឹកដីយើង ។



www.elibraryofcambodia.org

ណួរ

១. តើទឹកដីកម្ពុជា មានសណ្ឋានដូចម្ដេចខ្លះ ?

២. តើប្រជាជននៅវាលទំនាបគេធ្វើអ្វីខ្លះ ?

៣. តើនៅតំបន់ភ្នំសម្បូរអ្វីខ្លះ ?

៤. តើនៅប្រទេសកម្ពុជាមានអ្វីខ្លះ សម្រាប់ទាក់ទាញភ្ញៀវទេសចរ ?

៥. តើទ្រីតីទ្រីតារស់នៅឯណា ?

៦. តើអ្នកត្រូវធ្វើអ្វីខ្លះ ដើម្បីឱ្យទឹកដីអ្នកគង់វង្ស ?

## វំហាត់

. ចូរអានអត្ថបទកំណាព្យឡើងវិញ រួចពន្យល់ន័យរបស់ពាក្យខាងក្រោម ។

| សោភា | ទេសចរ | មរតក | ប្រណីត | ទ្រីតីទ្រីតា |

. តើកំណាព្យខាងលើនិយាយពីអ្វី ? ចូរជ្រើសរើសចម្លើយមួយសមស្រប ។

☐ ១. ការថែរក្សាសម្រស់ទឹកដីកម្ពុជា

☐ ២. សម្រស់ទឹកដីកម្ពុជា នៅតាមតំបន់នានា

☐ ៣. ទឹកដីកម្ពុជានៅតំបន់ព្រៃភ្នំ ។



## សំណេរ

ក. ចូរបំពេញកថាខណ្ឌដោយប្រើនាម និងគុណនាម ឱ្យបានសមស្រប ។

គ្រាន់តែមកដល់មាត់សមុទ្រភ្លាម ខ្យល់អាកាស ... និងក្លិនប្លែកបានបក់មកប៉ះ ... និង ... ខ្ញុំ ។ ខ្ញុំឃើញផ្ទៃសមុទ្រ ... ល្វឹងល្វើយ រហូតដល់ជើងមេឃ ។ ទូកក្ដោងនេសាទអណ្ដែតយឺតៗ ។ ទិដ្ឋភាពនេះ ធ្វើឱ្យខ្ញុំរីករាយក្រៃលែង ។ ខ្ញុំដើរកាត់ឆ្នេរខ្សាច់យកជើងលេងទឹករលក ។ ទឹកសមុទ្រមានពណ៌ ... ឆ្លុះឃើញខ្សាច់ ។ ជួនកាល ខ្ញុំឃើញហ្វូងត្រី ...ៗ ហែលរលេញ ។



www.elibraryofcambodia.org

ខ. ចូរបំពេញវគ្គនៃកំណាព្យខាងក្រោមឱ្យបានត្រឹមត្រូវ ។

ទឹកដីកម្ពុជា ទីនានាសែនសម្បូរ
ទន្លេ ស្ទឹង បឹង ... ព្រៃសាគរឈើត្បូងរ៉ែ ។
វាល ... ច្បារចម្ការ ផ្តល់ផល្លារៀងរាល់ ... ។
ដូច្នេះយើងត្រូវតែ នាំគ្នា... និង ... ។

## ផលកសិកម្មនៅកម្ពុជា

ក្រោយពីស្តាប់អត្ថបទកាព្យចប់ ចូរអ្នកឆ្លើយនឹងសំណួរខាងក្រោម ។

១. តើជនជាតិភាគតិចរស់នៅឯណា ?

២. តើពួកគេប្រកបរបរអ្វីខ្លះ ?

៣. តើប្រជាជននៅវាលទំនាប ដាំដំណាំអ្វីខ្លះនៅពេលទឹកស្រក ?

៤. តើកសិកររស់នៅខ្ពង់រាបដាំដំណាំអ្វីខ្លះ ?

៥. តើដំណាំហូបផ្លែអ្វីខ្លះដែលអ្នកចូលចិត្ត ?

៦. តើគេយកកៅស៊ូ និងកាហ្វេទៅលក់ឯណា ?

## លំហាត់

ក. តើកំណាព្យនេះនិយាយអំពីអ្វី ? ចូរជ្រើសរើសចម្លើយមួយសមស្រប ។

☐ ១. ផលកសិកម្មនៅតាមតំបន់នានា

☐ ២. សម្រស់ទេសភាពនៅតាមតំបន់នានា

☐ ៣. របៀបប្រកបអាជីវកម្មរបស់ជនជាតិយើង ។

៦. ចូរប្រាប់ពាក្យចួននៅក្នុងវគ្គទី១ និងទី២ នៃកំណាព្យ ។

**វគ្គទី១**

មើលភ្នំធំធេងវែងស្រណោះ មើលព្រៃល្អស្រស់គ្រប់ទិសទី
ផនជាតិភាគតិចរស់មូលមីរ ចិញ្ចឹមជីវីគ្រាប់ដូនតា ។

**វគ្គទី២**

បុកដាំស្រូវពោតល្ងសណ្តែក ផ្តល់ផលល្អឯកគាប់ចិន្តា
ប្រមូលផលទុកស្រេចកាលណា ជួបជុំគ្រួសាររាំរបាំ ។

## ល្បះនិងផ្នែកទាក់ទងនៃល្បះ

ក. ល្បះ

ចូរអានឧទាហរណ៍ខាងក្រោម ។ តើឧទាហរណ៍ណាខ្លះជាល្បះ ?

១. ខ្ញុំរស់នៅតំបន់ភ្នំ ។

២. កសិករនាំគ្នាដាំពោត ។

៣. រដូវទឹកស្រក

៤. យី! ទេសភាពលើកោះនេះស្អាតអ្វីម្ល៉េះ!

៥. អ្នកណានេសាទត្រី ?

ឧទាហរណ៍ទី ១ - ២ - ៤ -៥ ជាល្បះ ព្រោះវាមានន័យគ្រប់គ្រាន់ស្តាប់បាននិងបញ្ចប់ដោយសញ្ញាខណ្ឌ ( ។ ) សញ្ញាឧទាន ( ! ) សញ្ញាសួរ ( ? ) ។រីឯឧទាហរណ៍ទី ៣ មិនមែនជាល្បះទេ ព្រោះវាពុំមានន័យគ្រប់គ្រាន់ស្តាប់បាន ។

> ល្បះ គឺជាក្រុមពាក្យមានន័យគ្រប់គ្រាន់ស្តាប់បាន ហើយបញ្ចប់ដោយសញ្ញាខណ្ឌ( ។ ) សញ្ញាសួរ ( ? ) ឬសញ្ញាឧទាន ( ! ) ។



www.elibraryofcambodia.org

## ១. ផ្នែកនៃល្បះ

ចូរស្វែងយល់ផ្នែកនៃល្បះនីមួយៗ ។

| កន្សោមនាមប្រធាន | កន្សោមកិរិយា |
|---|---|
| ខ្ញុំ | រស់នៅតំបន់ភ្នំ ។ |
| កសិករ | ភ្ជួរដីដាំដំឡូង ។ |
| គ្រួសារពូសុខ | ដាំសណ្ដែកដីនៅពេលទឹកស្រក ។ |

ល្បះនីមួយៗមានកន្សោមពាក្យពីរសំខាន់គឺ កន្សោមនាមប្រធាននិងកន្សោមកិរិយា ។ កន្សោមនាមប្រធាន គឺអ្វីដែលគេលើកយកមកនិយាយ ។ ឯកន្សោមកិរិយា និយាយអំពីសកម្មភាព ឬអំពើរបស់កន្សោមនាមប្រធាននោះ ។ វាមានកិរិយានៅជាមួយជានិច្ច ។

## លំហាត់

ក. ចូរអានឧទាហរណ៍ខាងក្រោមរួចគូសសញ្ញា ✓ ក្នុងប្រអប់ពីមុខឧទាហរណ៍ណាជាល្បះ ។

- ☐ ១. ខ្ញុំស្រោចបន្លែក្រោយផ្ទះ ។
- ☐ ២. អូ! គាត់មកពីស្រុកវិញហើយ!
- ☐ ៣. តើឯងចូលរៀននៅថ្ងៃណា ?
- ☐ ៤. ការអានសៀវភៅនៅពេលទំនេរ
- ☐ ៥. កសិករដកសណ្ដែកដី ។

ខ. ចូរអានល្បះខាងក្រោម រួចបង្ហាញកន្សោមនាមប្រធាន និងកន្សោមកិរិយា ។

១. ជនជាតិភាគតិចច្រើនរស់នៅតំបន់ភ្នំ ។

២. នៅខេត្តរតនគិរីមានត្បូងល្អៗណាស់ ។

៣. អ្នកនេសាទសមុទ្រមានជីវភាពធូរធារ ។

៤. តើគោអ្នកណាស៊ីអំពៅពូសំ?

៥. សៅច្រូតស្មៅតាមភ្លឺស្រែ ។



www.elibraryofcambodia.org

. ចូរគូសភ្ជាប់កន្សោមនាមប្រធាន និងកន្សោមកិរិយាជាល្បះត្រឹមត្រូវ ។

| ក | ខ |
|---|---|
| ១. សុខនិងតារា | ឡើងភ្នំដើម្បីបោចរលិ ។ |
| ២. ជនជាតិភាគតិច | ជិះទូកទៅសាលារៀន ។ |
| ៣. គ្រួសារខ្ញុំ | យកទឹកសមុទ្រធ្វើអំបិល ។ |
| ៤. ខេត្តមួយចំនួន | ស្ថិតនៅជាប់ទន្លេមេគង្គ ។ |
| ៥. គេ | ទៅលេងកោះតាគាវ ។ |

## ទេសភាពភ្នំបូកគោ

ចូរអានអត្ថបទខាងក្រោម ។ តើភ្នំបូកគោមានទេសភាពល្អដូចម្ដេចខ្លះ ?



អ្នកដំណើរ ឬទេសចរភាគច្រើន កាលបើបានធ្វើដំណើរទៅលេងខេត្តកំពត គេមិនភ្លេចទៅកម្សាន្តលើភ្នំបូកគោឡើយ ។ បើគេមើលពីចម្ងាយ ពេលមេឃស្រឡះ គេឃើញទ្រង់ទ្រាយភ្នំបូកគោយ៉ាងច្បាស់ ។ ភ្នំនេះ មានរាងដូចជាបូករបស់គោដែលផុសចេញពីព្រៃព្រឹក្សាដ៏ក្រាស់ឃ្មឹក ។ គេអាចទៅដល់កំពូលភ្នំដោយរថយន្ត ឬយានជំនិះផ្សេងៗតាម



www.elibraryofcambodia.org

ផ្លូវមួយដែលព័ទ្ធព័ន្ធពីជើងភ្នំរហូតដល់កំពូលភ្នំ ។ ពេលទៅដល់ នៅលើខ្នងភ្នំ គេឃើញសំណង់ចាស់ៗបាក់បែក នៅពាសពេញលើខ្នងភ្នំ ។ មិនតែប៉ុណ្ណោះ មានផ្ទាំងសិលាធំៗហាក់ដូចជាកន្លែងអង្គុយលេងយ៉ាងល្អអស្ចារ្យ ។ ជារឿយៗ ពពករសាត់មកប៉ះខ្លួនអ្នកដំណើរ ធ្វើឱ្យពួកគេទទួលបាន អាកាសធាតុត្រជាក់ស្រេង ។

បើគេមើលពីលើកំពូលភ្នំមកក្រោម គេឃើញទេសភាពព្រៃព្រឹក្សាខៀវស្រងាត់ និងលម្ហសមុទ្រដ៏ធំល្វឹងល្វើយគួរឱ្យចង់គយគន់ ។ អាស្រ័យហេតុនេះហើយទើប នៅរដូវប្រាំងភ្ញៀវទេសចរនាំគ្នាទៅលេងលើភ្នំបូកគោ ព្រោះនៅទីនោះធ្វើឱ្យពួកគេមានអារម្មណ៍ជ្រះថ្លា ទឹកចិត្តសប្បាយរីករាយ ភ្លេចអស់ទុក្ខកង្វល់ ភ្លេចការនឿយហត់ ដោយសារអាកាសធាតុបរិសុទ្ធ ។

សម្រស់ភ្នំបូកគោ អាចទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិ ឱ្យនាំគ្នាទៅកាន់ទីនោះជាហូរហែឥតអាក់ ។

## សំណួរ

១. តើភ្នំបូកគោស្ថិតនៅក្នុងខេត្តណា ?

២. តើគេអាចមើលភ្នំបូកគោពីចម្ងាយច្បាស់នៅពេលណា ?

៣. តើមានផ្លូវឡើងទៅលើភ្នំបូកគោដែរ ឬទេ ?

៤. តើនៅលើខ្នងភ្នំបូកគោមានអ្វីខ្លះ ?

៥. តើគេឃើញអ្វីខ្លះ ពីលើកំពូលភ្នំបូកគោ ?

៦. តើភ្ញៀវទេសចរមានអារម្មណ៍បែបណា ពេលទៅដល់ភ្នំបូកគោ ?

## លំហាត់

ចូរជ្រើសរើសឈ្មោះ ដែលអ្នកយល់ថាជាប្រធានបទរបស់អត្ថបទខាងលើ ។

១. ការកម្សាន្តនៅលើភ្នំបូកគោ

២. សម្រស់ភ្នំបូកគោ

៣. អាកាសធាតុនៅភ្នំបូកគោ ។



www.elibraryofcambodia.org

## ការពណ៌នាអំពីមុខរបរ

ចូរអានអត្ថបទខ្លីខាងក្រោម ។ តើគេពណ៌នាពីអ្វីខ្លះ ?

### មុខរបរអ្នកភូមិខ្ញុំ

គ្រួសារខ្ញុំ រស់នៅក្នុងភូមិសំរោង ។ សំរោងស្ថិតនៅតាមមាត់ព្រែក ក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង ។ នៅរដូវវស្សាភូមិនេះ លិចទឹកជារៀងរាល់ឆ្នាំ ។ គ្រប់គ្រួសារក្នុងភូមិ មានទូកមួយសម្រាប់ធ្វើដំណើរនៅរដូវទឹកលិច ។ ប្រជាជនរស់នៅក្នុងភូមិខ្ញុំក្រៅពីជនជាតិខ្មែរមានចិន វៀតណាម និងចាម ។ ជនជាតិចិនមិនធ្វើស្រែទេ ។ ពួកគេច្រើនរកស៊ីលក់ដូរ ។ ឪពុកម្ដាយខ្ញុំនិងអ្នកភូមិខ្លះទៀត ប្រកបរបរធ្វើស្រែ ។ នៅរដូវវស្សា គេធ្វើស្រូវឡើងទឹក ។ នៅរដូវទឹកស្រក គេធ្វើស្រូវប្រដេញទឹកទុកសម្រាប់លក់ ។ ក្រៅពីធ្វើស្រែឪពុកម្ដាយខ្ញុំធ្វើចម្ការ និងដាំបន្លែសម្រាប់ដោះស្រាយជីវភាពប្រចាំថ្ងៃ ។ ប្រជាជនភូមិខ្ញុំមាននេសាទុបករណ៍ស្ទើរគ្រប់ផ្ទះ ព្រោះពេលទំនេរពីការងារគេនាំគ្នានេសាទត្រី ។ គ្រួសារខ្ញុំ ពេញចិត្តនឹងរស់នៅទីនេះណាស់ ព្រោះវាជាទឹកដីកំណើត ។ ពិសេសទៅទៀតទីនេះ ប្រជាជនចេះសាមគ្គីគ្នា ជួយធុរៈគ្នា ស្រឡាញ់គ្នា និងមានអធ្យាស្រ័យចំពោះគ្នាជានិច្ច ។

### លំហាត់

ចូរអ្នកសរសេរអត្ថបទខ្លីមួយ រៀបរាប់ពីមុខរបររបស់ប្រជាជនក្នុងតំបន់ដែលអ្នករស់នៅ ។ សំណេរនេះត្រូវធ្វើតាមលំនាំសំណួរខាងក្រោម ។

១. តើអ្នករស់នៅភូមិណា ? តើភូមិនោះស្ថិតនៅតំបន់ណា ?

២. តើភូមិអ្នកមានជនជាតិណាខ្លះរស់នៅ ?

៣. តើគ្រួសារអ្នកនិងប្រជាជនភាគច្រើន ប្រកបរបរអ្វីខ្លះ ?

៤. តើប្រជាជនភូមិអ្នក មានជីវភាពដូចម្ដេច ? ហេតុអ្វី ?

៥. តើពួកគេមានទឹកចិត្តដូចម្ដេចចំពោះគ្នា ?

៦. តើអ្នកមានអារម្មណ៍ដូចម្ដេច ចំពោះកន្លែងដែលអ្នកកំពុងតែរស់នៅ ?



www.elibraryofcambodia.org

# រឿង កំណើតភ្នំនិងទន្លេ

ចូរអានអត្ថបទខាងក្រោម រួចឆ្លើយនឹងសំណួរ ។



កាលពីព្រេងនាយ មានបុរសពីរនាក់ ឪពុកនិងកូន បានចែវទូកទៅរកស៊ីឆ្លងកាត ភូមិស្រុកជាច្រើន ។ តាមផ្លូវធ្វើដំណើរ កូនបានឃើញភ្នំ ទន្លេ បឹង ក៏សួរឪពុក ។ បុរស ឪពុកបានលើកយករឿងមួយមកនិទានឱ្យកូនស្តាប់ ៖

មានតំណាលថា ក្រោយក្រុងរាពណ៍បានឆក់យកនាងសីតាទៅបាត់ ព្រះរាមរួ ដំណើរជាមួយព្រះលក្សណ៍ជាប្អូន និងមានហនុមានជាសេនាទៅតាមយកនាងសីតាម វិញ ។ ពេលទៅណាមកណា ព្រះរាមតែងយកព្រះខ័នទៅតាមជាប់ខ្លួនជានិច្ច ។ ដោយ ធ្វើដំណើរវែងឆ្ងាយ ព្រះរាមកាន់ព្រះខ័នយូរពេកទៅក៏រួយដៃ លោកក៏អូសព្រះខ័ន ។ ពេលព្រះរាមអូសព្រះខ័នចុងវាឆូតព្រះធរណីប្រេះជាពីរក្លាយជាស្ទឹង ទន្លេរហូតដ សព្វថ្ងៃ ។

អស់រយៈពេលជាច្រើនថ្ងៃ ព្រះរាម និងអ្នករួមដំណើរបានទៅដល់មាត់សមុទ្រដ៏ មួយ ។ នៅត្រើយម្ខាងនៃសមុទ្រ គឺនគរលង្កា ។ ព្រះរាមបានត្រាស់បង្គាប់ឱ្យហនុមាន



www.elibraryofcambodia.org

ថ្មល់កាត់សមុទ្រ ដើម្បីឆ្លងទៅយកនាងសីតាមកវិញ ។ ហនុមានបានទៅនិយាយលួងលោមនាងសុវណ្ណមច្ឆាឱ្យនាំពួកត្រីជួយជញ្ជូនថ្ម រៀបត្រៀមថ្នល់នៅបាតសមុទ្រ ។ ឯហនុមានបានយកដី និងដុំថ្មធំៗមកចងនឹងរោមជើង ។ ដីមួយដុំៗ មានទំហំប៉ុនភ្នំមួយ ។ ពេលហោះជញ្ជូនថ្ម និងដុំដី ហនុមានជួបព្យុះភ្លៀងធ្វើឱ្យដាច់រោមជើង ជ្រុះថ្ម និងដុំដីរប៉ាត់រប៉ាយ ក្លាយជាកូនភ្នំតូច ធំ ជាច្រើន ។ ដុំដី និងថ្មខ្លះ ធ្លាក់ជាប់គ្នារជិតក្លាយជាជួរភ្នំរហូតសព្វថ្ងៃនេះ ។

## សំណួរ

១. តើកូនសួរឪពុកអំពីរឿងអ្វី ?

២. តើទន្លេកើតឡើងពីអ្វី ? ភ្នំកើតពីអ្វី ?

៣. តើហនុមានទទួលបញ្ជាពីព្រះរាមដូចម្ដេចខ្លះ ?

៤. តើរឿងនេះ ជាពិតកថា (រឿងពិត) ឬមិនមែន ? ហេតុអ្វី ?

## លំហាត់

ក. ចូរអានល្បះខាងក្រោម តើល្បះណាបង្ហាញមូលហេតុ នៃព្រឹត្តិការណ៍នៅក្នុងរឿង ។

១. ក្រុងរាពណ៍ឆក់នាងសីតា ព្រះរាមទៅតាមយកនាងសីតាមកវិញ ។

២. ក្រុងរាពណ៍ចង់ល្បងរិទ្ធិជាមួយព្រះរាម ។

៣. ក្រុងរាពណ៍ចង់បញ្ចេញរិទ្ធិអំណាចគំរាមព្រះរាម ។

ខ. ចូរអានល្បះខាងក្រោម តើល្បះណាបង្ហាញហេតុ ? តើល្បះណាបង្ហាញផល ?

១. ព្រះរាមត្រូវធ្វើដំណើរទៅនគរលង្កា ព្រោះព្រះអង្គចង់ដណ្ដើមយកនាងសីតាពីក្រុងរាពណ៍មកវិញ ។

២. ពេលហោះ ហនុមានជួបនឹងព្យុះភ្លៀង ទើបធ្វើឱ្យវាដាច់រោមជើង ជ្រុះថ្ម និងដុំដី ។

៣. ព្រះរាមពុំអាចទៅនគរលង្កាបាន ពីព្រោះមានសមុទ្ររាំងផ្លូវ ។



www.elibraryofcambodia.org

# ការពណ៌នាពីទីកន្លែង

ចិន្តា និងសុគន្ធា កំពុងនិយាយប្រាប់គ្នាអំពីទីកន្លែងដែលពួកគេបានទៅលេងកម្សាន្ត ពីចុងសប្តាហ៍កន្លងមកនេះ ។

ចូរអ្នកអានអ្វីដែលពួកគេបាននិយាយ ។

កាលពីចុងសប្តាហ៍នេះ ខ្ញុំបានទៅលេងនៅភ្នំតាម៉ៅ ។ ទីនោះ មានខ្យល់អាកាសត្រជាក់បរិសុទ្ធមានដើមឈើ និងផ្ទាំងថ្មធំៗដែលធ្វើឱ្យយើងមានអារម្មណ៍រីករាយ ។យើងនាំគ្នាហូបបាយនៅក្រោមដើមឈើ ។ តែអ្វីដែលខ្ញុំជាប់ចិត្តខ្លាំងនោះគឺសួនសត្វ ។





ចំណែកខ្ញុំ បានទៅលេងវត្តអំពែភ្នំ ។ ខ្ញុំបានឆ្លងស្ពានយោល រួចឡើងទៅថ្វាយបង្គំព្រះ ។ ខ្ញុំបានដើរលេងតាមឆ្នេរខ្សាច់មាត់ស្ទឹង និងបានអង្គុយលេងលើផ្ទាំងថ្ម រួចក្បង់ទឹកលេងយ៉ាងសប្បាយរីករាយ ។

## សំណួរ

១. តើអ្វីខ្លះដែលធ្វើឱ្យអ្នកឃើញថា ភ្នំតាម៉ៅសប្បាយ ?

២. តើពាក្យពណ៌នាណាខ្លះដែលទាញអារម្មណ៍អ្នក ឱ្យសប្បាយជាមួយនឹងវត្តអំពែភ្នំ ?

## លំហាត់

ចូរពណ៌នាអំពីកន្លែងណាមួយដែលអ្នកបានស្គាល់ច្បាស់ ។



www.elibraryofcambodia.org

# ការពណ៌នាពីទីកន្លែង

អត្ថបទខាងក្រោមពណ៌នាអំពីរមណីយដ្ឋានគិរីរម្យ ។ ចូរអានអត្ថបទនេះ និងស្វែងយល់របៀបពណ៌នា នៅក្នុងកថាខណ្ឌនីមួយៗ ។

## រមណីយដ្ឋានគិរីរម្យ

គិរីរម្យជារមណីយដ្ឋានមួយ ឋិតនៅក្នុងភូមិត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។

បើគេធ្វើដំណើរតាមផ្លូវជាតិលេខ៤ ហួសពីទីរួមខេត្តបន្តិច គេនឹងឃើញភ្នំមួយលាតសន្ធឹងខាងស្តាំដៃ គឺជួរភ្នំគិរីរម្យ ។ កាលណាគេធ្វើដំណើរដល់ផ្សារត្រែងត្រយឹង គេឃើញផ្លូវមួយឆ្ពោះទៅកាន់ខ្នងភ្នំ ។ នៅអមសងខាងផ្លូវ មានចម្ការស្វាយ ភ្វៀរ ក្រូចថ្លុង បំពេញរាជ្យជាដើម ។ អាស្រ័យទីនោះមានអាកាសធាតុត្រជាក់ ទើបធ្វើឱ្យដំណាំស្រស់ដុះលូតលាស់ល្អ ក្លាយជាឧទ្យានមួយយ៉ាងខៀវស្រងាត់ ។ មិនតែប៉ុណ្ណោះ ទីនោះមានភូមិគ្រឹះរបស់ប្រជាជន ផ្ទះសំណាក់ និងមានវត្តយ៉ាងល្អប្រណីត សម្រាប់ពុទ្ធសាសនិកជនប្រារព្ធពិធីបុណ្យតាមប្រពៃណីពុទ្ធសាសនាទៀតផង ។ នៅពេលគេបន្តដំណើរទៅមុខ គេឮសូរសន្ធឹកទឹកហូរគួរឱ្យចង់ងូតណាស់ ។ នៅសងខាងផ្លូវ មានកន្លែងលក់អាហាររបស់របរសម្រាប់លម្អផ្ទះ និងឱសថបុរាណទៀតផង ។

ទេសចរទាំងឡាយ ដែលបានមកកម្សាន្តនៅទីនេះ តែងមានអារម្មណ៍ជិតជាប់នឹងទេសភាពដ៏ស្រស់ត្រកាលជានិច្ច ។

### លំហាត់

- អ្នកបានអានអត្ថបទពណ៌នាអំពីភ្នំបូកគោ មាត់សមុទ្រ និងរមណីយដ្ឋានគិរីរម្យរួចហើយ ។ ចូរអ្នកសរសេរអត្ថបទខ្លីពណ៌នាពីទីកន្លែងណាមួយ ដែលអ្នកធ្លាប់ទៅកម្សាន្តឬធ្លាប់ឮគេនិយាយប្រាប់ ។



www.elibraryofcambodia.org

ដើម្បីពណ៌នាពីទីកន្លែង គេត្រូវពណ៌នាតាមលំដាប់លំដោយដូចក្នុងគម្រោងខាងក្រោម ។

## គម្រោងតែង

១. ផ្តើមសេចក្តី

ទីតាំង (ភូមិ ឃុំ ស្រុក ខេត្ត) នៅតាមផ្លូវជាតិ (លេខ ...) ឬតាមដងទន្លេ ឬស្រុកស្រែ និងចម្ការ ។

២. តួសេចក្តី

ក. ទិដ្ឋភាពដែលយើងមើលឃើញពីចម្ងាយ (ទំហំ រាង ពណ៌ ...)

ខ. ទិដ្ឋភាពដែលយើងបានឃើញ ពេលចូលទៅជិត (ដំបូលផ្ទះ ដំបូលព្រះវិហារ ... )

គ. ទិដ្ឋភាពពេលចូលទៅដល់ (ត្រូវរៀបរាប់ពីអ្វីដែលនៅជុំវិញខ្លួន និងអ្វីដែលនៅឆ្ងាយពីខ្លួន) ។

៣. បញ្ចប់សេចក្តី

បង្ហាញមនោសញ្ចេតនា ឬចំណាប់អារម្មណ៍ចំពោះទីកន្លែងដែលបានលើកយកមកធ្វើការពណ៌នា (ហេតុអ្វីបានជាអ្នកស្រឡាញ់ ឬអាល័យទីនោះ) ។

**ខ. ចូរអ្នកពណ៌នាអំពីទីកន្លែងដែលមាននៅក្នុងរូបភាពខាងក្រោម ។ កន្លែងនេះគឺវត្តភ្នំ**





www.elibraryofcambodia.org

មេរៀនទី ៩

# ប្រភពទឹកនៅកម្ពុជា



ពាក្យចាស់លោកពោលថា " ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ " ឬ " មានទឹកមានត្រី " ។ តាមន័យរបស់ពំនោលនេះ តើអ្នកយល់ថា ទឹកមានសារៈសំខាន់យ៉ាងណាខ្លះចំពោះយើង ? តើយើងបានទឹកប្រើប្រាស់ពីប្រភពណាខ្លះ ? បើប្រភពទឹកមិនស្អាត តើវានាំឱ្យប៉ះពាល់ដល់អ្វីខ្លះ ?



www.elibraryofcambodia.org

# ការសន្សំសំចៃទឹក

ចូរអានអត្ថបទ សម្តែងទស្សនៈខាងក្រោម តើគេនិយាយពីអ្វីខ្លះ ។



មនុស្ស សត្វ និងរុក្ខជាតិ សុទ្ធតែត្រូវការទឹកដើម្បីរស់ ។ បច្ចុប្បន្ននេះ បរិមាណទឹក ហាបមានចំនួនតិចណាស់ ប៉ុន្តែបរិមាណមនុស្សកាន់តែកើនឡើង ។ អ្នកវិទ្យាសាស្ត្របាន ទស្សន៍ទាយថា នៅឆ្នាំ២០១៥ ប្រទេសជាច្រើននៅលើពិភពលោកនេះ នឹងខ្សត់ទឹក ប្រើប្រាស់ ។ ដូច្នេះ បើយើងទាំងអស់គ្នាមិនបានយកចិត្តទុកដាក់ក្នុងការប្រើប្រាស់ទឹក ដោយសន្សំសំចៃទេនោះ យើងនឹងជួបនូវកង្វះទឹក នៅថ្ងៃអនាគតមិនខាន ។

ដើម្បីសន្សំសំចៃទឹក មានមនុស្សមួយចំនួនបញ្ចេញទស្សនៈផ្សេងៗដូចជា មនុស្ស ខ្លះយល់ថា ត្រូវងូតទឹករយៈពេលខ្លី ដើម្បីកុំឱ្យអស់ទឹកច្រើន ។ នៅពេលបោកខោអាវ ត្រូវដាក់ទឹកឱ្យស្របនឹងបរិមាណខោអាវនោះ ។ ម្យ៉ាងទៀត ត្រូវចេះច្នៃប្រឌិតយកទឹក ដែលប្រើរួច ទៅចាក់បង្គន់ ឬស្រោចដំណាំ ។ ចំណែកអ្នកខ្លះទៀតយល់ថា ត្រូវងូតទឹក ដោយចាក់បង្ហូរតិចៗ (ចំពោះអ្នកប្រើទឹកម៉ាស៊ីន គួរងូតទឹកផ្កាឈូក) មិនត្រូវបង្ហូរទឹក សម្រាប់ដុសធ្មេញ ឬលាងវត្ថុផ្សេងៗ ហើយត្រូវបិទក្បាលម៉ាស៊ីនទឹកឱ្យជិតល្អ នៅពេល ប្រើរួច ។

ហេតុនេះ យើងត្រូវនាំគ្នាសន្សំសំចៃទឹក ទោះប្រើវិធីណាក៏ដោយ ដើម្បីទប់ស្កាត់ សង្គ្រាមដណ្តើមទឹកគ្នានៅពេលអនាគត ។

(ដកស្រង់ពីសៀវភៅគុណភាពជីវិតផ្តោតលើការអប់រំសុខភាព អនាម័យ និងទឹកស្អាត



www.elibraryofcambodia.org

## សំណួរ

១. តើមនុស្ស សត្វ រុក្ខជាតិត្រូវការអ្វី ?

២. តើបរិមាណទឹកសាប អាចឱ្យមនុស្សប្រើប្រាស់គ្រប់គ្រាន់ដែរ ឬទេ ? ហេតុអ្វី ?

៣. តើប្រទេសជាច្រើននឹងជួបបញ្ហាអ្វីនៅឆ្នាំ២០១៥ ?

៤. តើយើងត្រូវសន្សំសំចៃទឹកដូចម្តេចខ្លះ ?

៥. ចំពោះអ្នកផ្ទាល់ អ្នកត្រូវធ្វើដូចម្តេចខ្លះ ?

៦. បើយើងមិននាំគ្នាសន្សំសំចៃទឹក តើនឹងមានអ្វីកើតឡើងនៅពេលអនាគត ?

## លំហាត់

ក. ចូរប្រាប់ន័យរបស់ពាក្យខាងក្រោម ដោយជ្រើសរើសចម្លើយមួយត្រឹមត្រូវ ។

| បរិមាណគឺ | ទស្សនៈគឺ |
|---|---|
| ១. ការកើនឡើង | ១. ការទាយ |
| ២. ការថយចុះ | ២. ការយល់ឃើញ |
| ៣. ចំនួន | ៣. ការគិត |

ខ. ចូរបង្ហាញគំនិតសំខាន់ៗនៃអត្ថបទ ដោយជ្រើសរើសចម្លើយខាងក្រោម ។

១. បរិមាណទឹកសាបតិច មនុស្សចេះតែកើនឡើង ។

២. អ្នកវិទ្យាសាស្ត្រទាយថា ប្រទេសជាច្រើននឹងខ្វះទឹកនៅឆ្នាំ២០១៥ ។

៣. ប្រទេសណាមានទឹក គប្បីប្រើប្រាស់តាមត្រូវការ ។

៤. ត្រូវនាំគ្នាប្រើប្រាស់ទឹក ដោយសន្សំសំចៃតាមវិធីផ្សេងៗ ។

៥. សង្គ្រាមដណ្តើមទឹក នឹងកើតមាននៅពេលអនាគត ។



www.elibraryofcambodia.org

# សំណេរ

ក. ចូរបំពេញពាក្យក្នុងកថាខណ្ឌ ដោយជ្រើសរើសពាក្យក្នុងប្រអប់ ។

| | | | | | | | |
|---|---|---|---|---|---|---|---|
| ប្រៃ | ប្រើប្រាស់ | សាប | ដី | វស្សា | រុក្ខជាតិ | ភ្លៀង | សមុទ្រ |

## ប្រភពទឹក

មនុស្ស សត្វ និង ... ទទួលទឹកពីប្រភពទឹកផ្សេងៗ ។ ប្រភពទឹក ដែលមានបរិមាណច្រើនជាងគេគឺទឹក ... ។ ទឹកសមុទ្រ មានរសជាតិ ... ។ មនុស្ស សត្វជាច្រើនមិនអាចយកទឹកសមុទ្រមក ... បានទេ ។

ប្រភពទឹក ... មានទន្លេ បឹង ត្រពាំង ។ល។ បណ្ដាទឹកសាបទាំងនោះ មួយចំនួនមានទឹកជាប្រចាំ ប៉ុន្តែប្រភពទឹកសាបខ្លះទៀត មានទឹកនៅរដូវ ... ប៉ុណ្ណោះ ។ ប្រភពទឹកសាបខ្លះ មានក្រោម ... ដូចជាទឹកអណ្ដូង ។ ទឹកសាបខ្លះ មានប្រភពមកពីជ្រលងភ្នំ ។ ប្រភពទឹកសាបភាគច្រើនបានមកពីទឹក ... ។

ខ. ចូរបំពេញល្បះខាងក្រោមឱ្យបានសមស្រប ។

១. នៅលើពិភពលោក មានប្រជាជនជាច្រើនរស់នៅ ដោយខ្វះ ... ប្រើប្រាស់ ។

២. ទឹកកខ្វក់ អាចធ្វើឱ្យយើងមាន ... ។

៣. ជំងឺដែលបណ្ដាលមកពីការប្រើប្រាស់ទឹកកខ្វក់ មានជំងឺ ... ជំងឺ ... និង ... ។

៤. រោគសញ្ញានៃការខ្សោះជាតិទឹករួមមាន ស្រេកទឹក បត់ជើងតូច ... មាត់ស្ងួត សាច់ដុំខ្សោយ ភ្នែក ... ។

៥. ជំងឺរាគច្រើនកើតចំពោះ ... ហើយងាយធ្វើឱ្យកុមារស្លាប់ទៀតផង ។



www.elibraryofcambodia.org

# ការបំពុលប្រភពទឹក

ចូរស្តាប់អត្ថបទសម្តែងទស្សនៈ រួចឆ្លើយនឹងសំណួរ ។



១. តើប្រភពទឹក ត្រូវបានបំពុលដោយសារកត្តាអ្វីខ្លះ ?

២. មនុស្សធ្វើសកម្មភាពអ្វីខ្លះ ដែលនាំឱ្យទឹកកខ្វក់ ?

៣. តើការរីកចម្រើនផ្នែករោងចក្រ ធ្វើឱ្យប្រភពទឹកកខ្វក់ដោយសារហេតុអ្វី ?

៤. ហេតុអ្វីបានជាគេថា ជីគីមីធ្វើឱ្យប្រភពទឹកកខ្វក់ ?

៥. តើធម្មជាតិបំពុលប្រភពទឹកដោយវិធីណា ?



www.elibraryofcambodia.org

## សញ្ញាបដិសេធ ឬទណ្ឌឃាត (៍)

តួអក្សរមួយចំនួននៅក្នុងពាក្យខ្លះ មិនត្រូវបានបន្លឺទេ ព្រោះវាមានសញ្ញាបដិសេធនៅខាងលើ ។ តើអ្នកស្គាល់សញ្ញាបដិសេធដែរ ឬទេ ?

ចូរពិនិត្យមើលឧទាហរណ៍ខាងក្រោម ។ តើតួអក្សរណាខ្លះ ដែលមានសញ្ញាបដិសេធនៅខាងលើ ? តើតួអក្សរទាំងនោះត្រូវអាន ឬទេ ?

១. ទឹកមានប្រយោជន៍ណាស់ សម្រាប់មនុស្ស សត្វ និងរុក្ខជាតិ ។

២. យើងសម្រាកក្រោមដើមពោធិ៍ក្បែរមាត់បឹង ។

៣. កាលពីសប្ដាហ៍មុន ខ្ញុំបានទៅងូតទឹកនៅបារាយណ៍ទឹកថ្លា ។

៤. កូនខ្មែរត្រូវថែរក្សាកេរ្តិ៍ឈ្មោះឱ្យបានរុងរឿង ។

៥. ប្រជាជននាំគ្នាស្ទូចត្រីក្នុងស្ទឹងពោធិ៍សាត់ ។

សញ្ញាបដិសេធ សម្រាប់លុបសូរព្យញ្ជនៈ ឬស្រៈមិនឱ្យអានតាមសំណេរ ។

## លំហាត់

ក. ចូរអានពាក្យ ៖ រោទ៍ អាចម៍ ពាក្យពេចន៍ ព្រហស្បតិ៍ នាំអាទិ៍ សហគមន៍ គមនាគមន៍ អាពាហ៍ពិពាហ៍ ទេសចរណ៍ ។
តើអក្សរណាខ្លះមិនត្រូវបានអាន ? ហេតុអ្វី ?

ខ. ពាក្យឬកន្សោមពាក្យខាងក្រោមពុំទាន់ត្រឹមត្រូវទេ ។ ចូរចម្លងពាក្យ កន្សោមពាក្យទាំងនេះរួចបំពេញផ្នែកខ្វះរបស់ពាក្យ ឬកន្សោមពាក្យនីមួយៗឱ្យបានត្រឹមត្រូវ ។

១. ឧស្សាហ
២. ឧបករណ
៣. វេយ្យាករណ
៤. ឧទាហរណ
៥. គមនាគមន
៦. របាយការណ
៧. អភិវឌ្ឍន
៨. បដិវត្តន
៩. អារម្មណ
១០. ហេតុការណ



www.elibraryofcambodia.org

# កំណាព្យ ៖ ទំនួញព្រះគង្គា

ចូរអានកំណាព្យ រួចឆ្លើយនឹងសំណួរខាងក្រោម ។



(បទកាកគតិ)

មនុស្សជាតិទាំងឡាយ ម្ដេចធ្វើអន្តរាយ ចំពោះខ្លួនឯង
កាប់ឈើព្រៃព្រឹក្ស បង្កើតភ្លើងផ្សេង រីងរាំងក្ដៅហែង
បរិស្ថានខ្វះទឹក ។

សំរាមសំណល់ គីមីនាំដល់ ជាតិពុលសន្ធឹក
លាមក មនុស្ស សត្វ បង្ហូរចូលទឹក កខ្វក់ពន្លឹក
គ្មានអនាម័យ ។

ខ្ញុំសូមអង្វរ ប្រើខ្ញុំឱ្យល្អ គ្រប់អ្នកអាស្រ័យ
ខ្ញុំពិតមានគុណ ដល់អ្នកពេកក្រៃ សន្សំកែច្នៃ
ទឹកជាជីវិត ។

(ដកស្រង់ចេញពីសៀវភៅ គុណភាពជីវិតផ្ដោតលើការអប់រំសុខភាពអនាម័យនិងទឹកស្អាត)



www.elibraryofcambodia.org

## សំណួរ

១. តើការកាប់ព្រៃឈើ នាំឱ្យមានផលអាក្រក់អ្វីខ្លះ ?

២. តើមនុស្សយើងបានធ្វើអ្វីខ្លះ ប៉ះពាល់ដល់ប្រភពទឹក ?

៣. តើទឹកអង្ករយើងឱ្យធ្វើអ្វីខ្លះ ?

៤. បើគ្មានទឹក តើមនុស្សអាចរស់នៅបាន ឬទេ ?

៥. ដើម្បីថែរក្សា និងការពារប្រភពទឹក តើយើងត្រូវធ្វើអ្វីខ្លះ ?

## លំហាត់

ក. ចូរអានកំណាព្យឡើងវិញ រួចរកពាក្យចួននឹងពាក្យខាងក្រោម ។

| | |
|---|---|
| ១. ទាំងឡាយ ចួននឹង ... | ឯង ចួននឹង ... |
| ២. សំណាល់ ចួននឹង ... | សន្ទឹក ចួននឹង ... |
| ៣. អង្ករ ចួននឹង ... | អាស្រ័យ ចួននឹង ... |
| ៤. ទឹក ចួននឹង ... | អនាម័យ ចួននឹង ...(ពាក្យចួន ឆ្លងវគ្គ) |

ខ. ចូរច្រៀងចម្រៀងខាងក្រោម រួចឆ្លើយនឹងសំណួរ ។

### បើស្រីស្លកុក

បើស្រីស្លកុក ស្លនឹងទឹកថ្លា
ត្បិតកុកវាថា សាច់វាស្អាតណាស់ ។
ទាំងរោមទាំងស្លាប ដុះរាបក្រៃក្រាស់
មុខគួរស្អាតណាស់ កុំឱ្យមានហ្មង ។
វាបានជាឆ្ងោយ មកជាប់ជង់បង ។
អាណិតវាផង ត្បិតវាអង្ករ ។

១. ហេតុអ្វីបានជាកុកប្រាប់គេថា បើស្លវា ឱ្យស្លនឹងទឹកថ្លា ?

២. ចូររកពាក្យចួននឹងពាក្យ ៖ ថ្លា ណាស់ ក្រាស់ ហ្មង ។



www.elibraryofcambodia.org

# សំណេរ

ក. ចូរបំពេញចន្លោះនៃអត្ថបទពាក្យកាព្យខាងក្រោម ដោយជ្រើសរើសពាក្យក្នុងប្រអប់ ។

| ថ្ងៃ | ភ្លេច | បរិស្ថាន | ពេជ្រ | រាក់ | ថ្លៃ | ប្រាណ | ប្រែ | តម្លៃ | អ្នក | សំចៃ |
|---|---|---|---|---|---|---|---|---|---|---|

ទឹកជាភាវ មាន... ព្រឹកល្ងាច យប់... ខ្វះមិនបាន
បោកគក់សម្អាតលុបលាង... ធ្វើឱ្យ... យើងល្អជាក់ ។
មនុស្ស សត្វ រុក្ខជាតិផងទាំងឡាយ បានរស់គ្រប់កាយយ៉ាងប្រត្យក្ស
ទឹកសាប ទឹក... ទោះជ្រៅ... ចិញ្ចឹមរូប... រៀងរាល់ថ្ងៃ ។
ដូច្នេះទឹកប្រៀបថ្លៃលើស... គ្រប់ប្រាណកុំ... អនាម័យ
សម្អាត បន្សុទ្ធហើយកែ... ប្រើដោយ... ជានិរន្តរ៍ ។

ខ. ចូរបំពេញចន្លោះល្បះខាងក្រោម ឱ្យបានសមស្រប ។

១. យើងត្រូវហូបទឹក... ជាប្រចាំ ។
២. ការប្រើប្រាស់ទឹក... នាំឱ្យមានជំងឺភ្នែក ជំងឺ... ។
៣. បើយើងធ្វើឱ្យទឹកកខ្វក់ ប្រៀបដូចជាបំផ្លាញ... ខ្លួនឯង ។
៤. ជំងឺដែលឆ្លងតាមការហូបទឹកកខ្វក់ មាន... ... ... ... ។
៥. យើងត្រូវចូលរួម... ...ប្រភពទឹកឱ្យបាន... ។

គ. ចូរតែងល្បះនឹងពាក្យខាងក្រោមឱ្យបានមួយល្បះក្នុងមួយពាក្យ ។

១. ទឹកស្អាត ៖ ................................................................ ។
២. ទឹកកខ្វក់ ៖ ................................................................ ។
៣. ទឹកភ្លៀង ៖ .............................................................. ។
៤. ទឹកអណ្តូង ៖ ............................................................ ។



www.elibraryofcambodia.org

# រឿង ទឹកជ្រោះបរិសុទ្ធ

ចូរអានរឿងខាងក្រោម រួចឆ្លើយនឹងសំណួរ ។



រដូវប្រាំង ព្រះអាទិត្យផ្សព្វផ្សាយកម្ដៅ ក្ដៅគ្រប់ទិសទី ។ អ្នកដំណើរបីនាក់ បានចូលឈប់សម្រាក ក្រោមម្លប់ឈើជិតក្បាលជ្រោះមួយ ហើយនាំគ្នាចូលទៅអាស្រ័យទឹកជ្រោះដ៏ថ្លាយង់នោះ ។ នៅពីលើប្រភពនៃទឹកនេះ មានស្លាកថ្មមួយចារឹកជាអក្សរថា ៖ “ សូមឱ្យទឹកជ្រោះនេះ បានជាតួយ៉ាងដល់មនុស្សគ្រប់គ្នា” ។

លុះអ្នកដំណើរទាំងបី បានអានប្រស្នានេះចប់ក៏នាំគ្នា ដោះស្រាយសេចក្ដី តាមបញ្ញារៀងខ្លួន ។

អ្នកដំណើរម្នាក់ បញ្ចេញយោបល់មុនគេ ៖“ ទឹកជ្រោះហូរចេញពីដីជានិច្ច ហូរទៅឆ្ងាយជាមួយនឹងទឹកជ្រោះឯទៀត ហើយប្រមូលគ្នាបង្កើតបានជាស្ទឹងមួយ យ៉ាងណាមិញ “ ចំណែកមនុស្សយើង ត្រូវខំធ្វើការដូចទឹកជ្រោះដែលហូរមិនឈប់យ៉ាងនោះដែរ ទើបមានសម្បត្តិស្ដុកស្ដម្ភ ” ។

អ្នកដំណើរម្នាក់ មានវ័យក្មេងជាងគេ បានឆ្លើយកាត់ឡើង ៖“ បើតាមខ្ញុំយល់ បញ្ហានេះបានសេចក្ដីថា មនុស្សត្រូវតាំងចិត្តគំនិតឱ្យស្អាតស្អំ ឱ្យល្អបរិសុទ្ធដូចទឹកជ្រោះនេះឯងដើម្បីឱ្យមនុស្សទូទៅ មានយើងជាដើមបានចូលពំនាក់អាស្រ័យយកកម្លាំង ។ តើមានប្រយោជន៍អ្វី ទឹកដែលហូរពាសដីប្រកបដោយកករល្អក់ អ្នកណាផឹកទឹកនោះបាន?” ។



www.elibraryofcambodia.org



អ្នកដំណើរដែលចាស់ជាងគេ ញញឹមហើយនិយាយ៖“ យុវជនយើងនិយាយត្រូវណាស់ នេះជាមេរៀនមួយដែលយើងរកឃើញនៅទីនេះ ។ អ្នកណាស្រេកឃ្លាន ជ្រោះបានបញ្ចេញទឹកបរិសុទ្ធ ឱ្យផឹកតាមតម្រូវការ ។ ជ្រោះជាតួយ៉ាងសម្រាប់មនុស្ស ឱ្យតាំងចិត្តធ្វើល្អចំពោះជនទូទៅ ដោយលះបង់ប្រយោជន៍គ្រប់យ៉ាង ដោយគ្មានទារសំណង គ្មានទាររង្វាន់ ឬអំណរគុណឡើយ” ។

## សំណួរ

១. ហេតុអ្វីបានជាអ្នកដំណើរទាំងបី ចូលជ្រកក្រោមម្លប់ឈើ?

២. តើអ្នកដំណើរយើងធ្វើអ្វី នៅពេលចូលជ្រកក្បែរទឹកជ្រោះ?

៣. តើទឹកជ្រោះមានលក្ខណៈដូចម្តេច?

៤. តើពួកគេបានឃើញអ្វី នៅលើប្រភពទឹក? តើស្លាកនោះមានសេចក្តីដូចម្តេច?

៥. តើអ្នកដំណើរទី១ យល់ថា ប្រស្នានោះមានន័យដូចម្តេច?

៦. តើអ្នកដំណើរទី២ យល់ថា ប្រស្នានោះមានន័យដូចម្តេច?

៧. តើអ្នកដំណើរទី៣ យល់ថា ប្រស្នានោះមានន័យដូចម្តេច?



www.elibraryofcambodia.org

## លំហាត់

ក. ចូរប្រាប់តួអង្គ និងកាលអាកាស (ពេលវេលា និងទីកន្លែង ) នៅក្នុងរឿងខាងលើ ។

ខ. តើរឿងនេះចង់អប់រំដូចម្ដេច ? ចូរជ្រើសរើសចម្លើយមួយត្រឹមត្រូវ ។

- [ ] ១. រឿងនេះអប់រំមនុស្សឱ្យខំធ្វើការងារ ដើម្បីឱ្យមានទ្រព្យសម្បត្តិ ។
- [ ] ២. រឿងនេះអប់រំមនុស្សឱ្យចេះសាមគ្គីគ្នា ដើម្បីបានជាកម្លាំងរឹងមាំ ។
- [ ] ៣. រឿងនេះអប់រំមនុស្សឱ្យព្យាយាមធ្វើចិត្តល្អ ចំពោះមនុស្សទូទៅ ។

## សំណេរ

ចូរពិនិត្យរូបភាពទឹកព្រែក រួចសរសេរកថាខណ្ឌទាក់ទងនឹងរូបភាព ។





www.elibraryofcambodia.org

# ការសម្តែងមតិអំពីទឹកស្អាត

សុគន្ធនិងមិត្តភក្តិបានពិភាក្សាគ្នា អំពីប្រភពទឹកស្អាត ។

ចូរអានការបញ្ចេញមតិរបស់ពួកគេ ។ តើគេនិយាយដូចម្តេចខ្លះ ?

សុគន្ធ : សព្វថ្ងៃមនុស្សយើងប្រើប្រាស់ ទឹកបឹង ទឹកស្ទឹង ទន្លេ ទឹកអណ្តូង ឬទឹកភ្លៀង ។ គេនិយាយថា ត្រូវប្រើទឹកស្អាតទើបមានសុវត្ថិភាព ប៉ុន្តែយើងមិនដឹងថា ទឹកប្រភេទណាជាទឹកស្អាត ?

វារី : ខ្ញុំយល់ថា ទឹកដែលយើងផឹកទៅពុំមានគ្រោះថ្នាក់ដល់សុខភាព នោះហើយជាទឹកស្អាត ឬទឹកមានអនាម័យ ។

ពិដោរ : ចំណែកខ្ញុំវិញយល់ថា ទឹកស្អាតប្រកបដោយសុវត្ថិភាព ជាប្រភពទឹកដែលគ្មានក្លិន គ្មានមេរោគបង្កជំងឺ និងគ្មានជាតិគីមី ។

វារី : ម្យ៉ាងទៀត ទឹកស្អាតសម្គាល់លើទឹកគ្មានពណ៌ ថ្លាគ្មានភាពល្អក់ឡើយ ។

សុគន្ធ : ខ្ញុំយល់ហើយ អរគុណ!

ដើម្បីសម្តែងមតិ គេច្រើនប្រើពាក្យ : ខ្ញុំយល់ថា ខ្ញុំគិតថា តាមគំនិតខ្ញុំ តាមខ្ញុំយល់... ។

## លំហាត់

ចូរអ្នកនិយាយសម្តែងមតិ អំពីប្រធានបទណាមួយដោយប្រើកាយវិការ ឥរិយាបថ និងទឹកមុខឱ្យបានត្រឹមត្រូវ ។

អ្នកអាចជ្រើសរើសប្រធានបទណាមួយខាងក្រោម ។

- ផលអាក្រក់នៃការហូបទឹកមិនស្អាត
- ការថែរក្សាប្រភពទឹកឱ្យបានស្អាត ។



www.elibraryofcambodia.org

# ការពណ៌នាអំពីប្រយោជន៍នៃទឹក

ចូរអានអត្ថបទខាងក្រោម ។ តើអត្ថបទនេះរៀបរាប់អំពីអ្វីខ្លះ ?

ខ្ញុំរស់នៅក្នុងភូមិមួយ ដែលស្ថិតនៅតាមមាត់ព្រែកមុខកំពូល ។ ព្រែកនេះ ផ្តល់ទឹក សម្រាប់អ្នកភូមិប្រើប្រាស់សព្វបែបយ៉ាង ។ ពួកគេដងទឹកព្រែកយកទៅងូត បោកខោអាវ ដាំស្ល និងផឹក ។ ក្រៅពីនេះ ព្រែកមុខកំពូលផ្តល់ទឹកសម្រាប់ស្រោចបន្លែ និងសម្រាប់ធ្វើ ស្រែប្រាំងថែមទៀត ។ ព្រែកនេះ បង្កលក្ខណៈងាយស្រួលដល់ការធ្វើដំណើរទៅមក របស់អ្នកភូមិ ។ មិនតែប៉ុណ្ណោះ ព្រែកនេះមានត្រីច្រើនប្រភេទដូចជាត្រីឆ្ពិន ត្រីលេញ ត្រី ក្អែក ត្រីសណ្តាយ ... ។ គេអាចរកត្រី លៀស និងគ្រុំ នៅក្នុងព្រែកយកទៅធ្វើអាហារ និងលក់ទៀតផង ។ រដូវសម្រកនៅតាមមាត់ព្រែក អ្នកភូមិខ្ញុំដាំពោត ដំឡូង សណ្តែកដី បានផលណាស់ ។

ព្រែកនេះ ផ្តល់ផលប្រយោជន៍ច្រើនយ៉ាងទើបអ្នកភូមិខ្ញុំ ខិតខំថែទឹកព្រែកឱ្យស្អាត ជានិច្ច ។

## លំហាត់

ចូរអ្នកសរសេរអត្ថបទខ្លីមួយ ពណ៌នាអំពីប្រយោជន៍នៃប្រភពទឹកណាមួយនៅក្នុង ភូមិអ្នក ដោយប្រើប្រាស់អត្ថបទខាងលើ និងសំណួរខាងក្រោមជាជំនួយ ។

១. តើនៅក្នុងភូមិអ្នកមានទន្លេ ស្ទឹង ឬព្រែកដែរ ឬទេ ?

២. តើស្ទឹង ឬទន្លេ ព្រែកនោះមានឈ្មោះអ្វី ?

៣. តើប្រភពទឹកនោះមានប្រយោជន៍អ្វីខ្លះ ? (ប្រើប្រាស់ ងូត ស្រោចដំណាំ ធ្វើ ស្រែ ផ្តល់ត្រី ...)

៤. តើអ្នកពេញចិត្តនឹងទន្លេ ស្ទឹង ឬព្រែកនោះដែរ ឬទេ ? ព្រោះអ្វី ?

៥. តើអ្នកត្រូវធ្វើដូចម្តេច ដើម្បីឱ្យប្រភពទឹកនោះស្អាតជានិច្ច ?



www.elibraryofcambodia.org

មេរៀនទី ១០

# សត្វនៅប្រទេសយើង







សត្វស្រុកជាច្រើនជួយការងារកសិករ ។ សត្វព្រៃកុះករកំដរធម្មជាតិ ។
ដើម្បីរក្សាពូជសត្វឱ្យនៅសម្បូរ តើអ្នកត្រូវចូលរួមធ្វើអ្វីខ្លះ ?



www.elibraryofcambodia.org

# កំណាព្យបទកាកគតិ

កំណាព្យខ្មែរមានច្រើនបទ ហើយបទនីមួយៗខុសប្លែកគ្នាអាស្រ័យចំនួនព្យាង្គ និងឃ្លាច្រើន ឬតិច ។ បទកាកគតិមានន័យថា"ដំណើរក្អែក" ជាបទដែលគេនិយមប្រើច្រើនជាងគេ ។

ចូរអានកំណាព្យខាងក្រោមនេះ ។ អក្សរដិតក្នុងឃ្លានីមួយៗ ជាពាក្យចួនក្នុងបទកាកគតិ ។

## ទំនួញសត្វព្រៃ

សត្វព្រៃជាតិជា ម្រឹគីម្រិគា រស់នៅសែនឆ្ងាយ
ពីភូមិពីស្រុក ចង់សុខរូបកាយ នៅតែខ្វាត់ខ្វាយ
បែកបាក់គ្រួសារ ។

ថ្ងៃភ័យយប់ព្រួយ ក្នុងចិត្តរញ្ជួយ ញាប់ញ័រឱរា
ខ្លាចព្រាត់ប្តីកូន ឬសូន្យសង្ខារ ដោយដៃឫស្យា
ព្រានចិត្តកំណាច ។

ក. **វង្វាស់កាព្យ**

បទកាកគតិក្នុងមួយវគ្គមាន៧ឃ្លា ។ ក្នុងមួយឃ្លាមាន៤ព្យាង្គ ។

ខ. **ចំណាប់ចួន**





www.elibraryofcambodia.org

១. ចួនក្នុងវគ្គ

ព្យាង្គទី៤ នៃឃ្លាទី១ចួននឹងព្យាង្គទី៤ នៃឃ្លាទី២ ។ ព្យាង្គទី៤ នៃឃ្លាទី៣ចួននឹងព្យាង្គទី៤ នៃឃ្លាទី៥ ចួននឹងព្យាង្គទី៤ នៃឃ្លាទី៦ ។

កំណាព្យខ្លះ ព្យាង្គទី៤នៃឃ្លាទី៤ ចួននឹងព្យាង្គទី២នៃឃ្លាទី៥ ។

២. ចួនឆ្លងវគ្គ

ព្យាង្គទី៤ នៃឃ្លាទី៧ក្នុងវគ្គទី១ចួននឹងព្យាង្គទី៤ នៃឃ្លាទី៣ក្នុងវគ្គទី២ ។

គ. ចង្វាក់ ៖ បទនេះ មានចង្វាក់ស្មើមិនលើកដាក់ តែរន្ថើន ហើយទម្លាក់សំឡេងលើព្យាង្គទី២នៃឃ្លានីមួយៗ ។

ឃ. បរិយាកាស ៖ បទនេះ គេប្រើសម្រាប់ពណ៌នាទីកន្លែង តួអង្គ ធម្មជាតិ ។ គេអាចយកបទនេះ ប្រើក្នុងការសម្ដែងទុក្ខសោកផងដែរ ។

> កំណាព្យ ជាអត្ថបទដែលតាក់តែងឡើងជាពាក្យកាព្យ ដោយរៀបចំជាឃ្លា ជាវគ្គតាមក្បួនខ្នាតត្រឹមត្រូវ ប្រកបដោយចំណាប់ចួន និងចង្វាក់ដែលអាចនាំអារម្មណ៍អ្នកអាន ឬអ្នកស្ដាប់ឱ្យរំភើប ឬលន្លង់លន្លោចតាមបទនីមួយៗ ។

## លំហាត់

ចូរជ្រើសរើសពាក្យ ដើម្បីបំពេញចន្លោះអត្ថបទកាព្យឱ្យបានត្រឹមត្រូវ ។

| រស់ | មេបា | បាន | គប់ | ល្បីឈ្មោះ | ឱភា | ថ្កើងថ្កាន | គ្រប់ប្រាណ |
|---|---|---|---|---|---|---|---|

| | | |
|---|---|---|
| មេត្តាបញ្ឈប់ | បរបាញ់កាប់... | អស់សត្វរុក្ខា |
| ឱ្យយើងបានសុខ | បាត់ចុក... | ជួបជុំ... |
| | ក្នុងព្រៃស្មសាន ។ | |
| ពួកយើងបាន... | ជាតិក៏... | រុងរឿង... |
| អ្នករួមការពារ | រាល់គ្នា... | ជម្នះឱ្យ... |
| | មានព្រៃមានសត្វ ។ | |



www.elibraryofcambodia.org

# មេសូត្រ ៖ ប្រយោជន៍នៃសត្វស្រុក

ចូរសូត្រមេសូត្របទកាកគតិ រួចឆ្លើយនឹងសំណួរ ។



សត្វឆ្កែនិងឆ្មា ពួកវាធ្វើការ ឥតមានឈរឈប់
ឆ្កែនៅយាមផ្ទះ ឆ្មាទះសង្គ្រប់ កណ្ដុររាល់យប់
មិនហ៊ាននៅក្បែរ ។

គោក្របីសេះ វាមានចំណេះ ចេះភ្ជួររាស់ស្រែ
និងអូសរទេះ ឥតវេះគេចកែ ជួយម្ចាស់ផងដែរ
ធ្វើស្រែចម្ការ ។

ក្ងានជ្រូកមាន់ទា គេចិញ្ចឹមវា ធ្វើជាអាហារ
វាផ្ដល់សាច់ស៊ុត ផ្គង់ផ្គត់គ្រួសារ មិនខាតថវិកា
យកទៅទិញគេ ។

ចិញ្ចឹមបានច្រើន ប្រាក់កាសនឹងកើន មិនខ្វះចាយទេ
កូនអើយចូរខំ សន្សំនឹងគេ ឆ្លៀតពេលទំនេរ
ជួយមើលថែផង ។



www.elibraryofcambodia.org

## សំណួរ

១. តើសត្វឆ្កែឆ្មាជួយធ្វើអ្វីខ្លះ ?

២. គោក្របីសេះជួយធ្វើអ្វីខ្លះ ?

៣. តើក្ងានជ្រូកមាន់ទាផ្តល់អ្វីខ្លះដល់យើង ?

៤. ដើម្បីឱ្យបានថវិកាច្រើន តើអ្នកត្រូវធ្វើអ្វីខ្លះ ?

## លំហាត់

ក. តើវគ្គទី១នៃកំណាព្យនិយាយអំពីអ្វី ? ចូរជ្រើសរើសចម្លើយមួយត្រឹមត្រូវ ។

☐ ១. ឆ្កែឆ្មាប្រឡែងនិងកណ្តុរ ។

☐ ២. ឆ្កែចេះយាមផ្ទះ ឆ្មាចេះចាប់កណ្តុរ ។

☐ ៣. ឆ្កែឆ្មាពូកែចាំផ្ទះ ។

ខ. តើវគ្គទី២នៃកំណាព្យនិយាយអំពីអ្វី ? ចូរជ្រើសរើសចម្លើយមួយត្រឹមត្រូវ ។

☐ ១. ក្របី គោ សេះ ចូលចិត្តគេចវេះ ។

☐ ២. ក្របី គោ សេះ ចេះជួយការងារស្រែចម្ការ ។

☐ ៣. ក្របី គោ សេះ ផ្តល់សាច់ជាអាហារ ។

គ. តើវគ្គទី៣នៃកំណាព្យនិយាយអំពីអ្វី ? ចូរជ្រើសរើសចម្លើយមួយត្រឹមត្រូវ ។

☐ ១. គេចិញ្ចឹមមាន់ ទា ជ្រូក ក្ងាន ដើម្បីយកសាច់ស៊ុតជាអាហារ ។

☐ ២. គេចិញ្ចឹមមាន់ ទា ជ្រូក ក្ងាន ដើម្បីស្តាប់សំឡេងយំរបស់វា ។

☐ ៣. គេចិញ្ចឹមមាន់ ទា ជ្រូក ក្ងាន ដើម្បីយកស្លាប ឬស្បែកធ្វើវត្ថុផ្សេងៗ ។

ឃ. តើវគ្គទី៤នៃកំណាព្យនិយាយអំពីអ្វី ? ចូរជ្រើសរើសចម្លើយមួយត្រឹមត្រូវ ។

☐ ១. គេដាស់តឿនកូនឱ្យខិតខំដាំដំណាំឱ្យបានច្រើន ។

☐ ២. គេដាស់តឿនកូនឱ្យខិតខំចិញ្ចឹមនិងជួយថែរក្សាសត្វ ។

☐ ៣. គេដាស់តឿនកូនឱ្យខិតខំធ្វើស្រែចម្ការឱ្យទាន់ពេលវេលា ។



www.elibraryofcambodia.org

## សំណេរ

ឃ្លាខាងក្រោមនេះនៅក្នុងកំណាព្យបទកាកគតិ ដែលមានចំណងជើងថា“បក្សីចង់បានសេរីភាព” ។ ចូររៀបឃ្លាក្នុងវគ្គទី១ និងវគ្គទី២ នៃកំណាព្យនេះ ឱ្យទៅជាកំណាព្យបទកាកគតិដែលមានចំណាប់ចួនត្រឹមត្រូវ ។

**វគ្គទី១ ៖** បក្សីបក្សា (ឃ្លាទី១)

មិនចង់ជាប់ទ្រុង
ម្ចាស់តាមទៀតណា ។ (ឃ្លាទី៧)
រស់ក្រោមគំនាប
រស់នៅត្រូវការ
សិទ្ធិសេរីភាព
ក្នុងវង់ដ៏ទាប

**វគ្គទី២ ៖** យើងចង់ហោះហើរ (ឃ្លាទី១)

ចំណង់ប្រាថ្នា
ទៅគ្រប់ទិសា
មិនដូចជាប់ទ្រុង ។ (ឃ្លាទី៧)
ចង់ធ្វើដំណើរ
រីករាយកាយា
តាមចិត្តយើងចង់

## គំនិតសំខាន់

នៅពេលអាន ឬស្តាប់អត្ថបទ កំណាព្យ ឬចម្រៀង យើងតែងចង់ដឹងថា តើអត្ថបទ កំណាព្យ ឬចម្រៀងនោះនិយាយអំពីអ្វី ។ យើងមិនអាចឆ្លើយបានភ្លាមទេ លុះត្រាតែអានអត្ថបទទាំងនោះ ដោយវិភាគគំនិតនៅក្នុងឃ្លាល្បះនីមួយៗ រួចសំយោគគំនិតតូចៗ ឬសេចក្តីលម្អិតសំខាន់ៗនៅក្នុងអត្ថបទនោះ ។

ចូរអានកំណាព្យខាងក្រោមនេះ រួចសន្និដ្ឋានគំនិតសំខាន់ ។

មាតុភូមិយើងតូចតែខ្លឹម
ធម្មជាតិប៉ប្រិមសម្បូរប្លែក
ត្បូងមាសស្ពាន់ថ្មសំណដែក
រ៉ែច្រើនអនេកមិនខ្វះអ្វី ។
ព្រៃមានរមាំងរមាសក្ដាន់
ទន្សោងខ្ទីងថ្លាន់ខ្លាដំរី
ជ្រូកព្រៃឈ្លូសច្រើសគោក្របី
បក្សាបក្សីច្រើនក្រៃក្រាស់ ។
ដើមឈើល្អៗមានតម្លៃ
យើងចេះកែច្នៃយកប្រើប្រាស់
សុក្រំនាងនួនបេងល្អល្អះ
កកោះធ្វើផ្ទះមាំកន្លង ។



www.elibraryofcambodia.org

សមុទ្រទន្លេសម្បូរត្រី បឹងបួស្ទឹងក្តិមិនខ្វះផង
ទឹកសាបទឹកប្រៃត្រីបង្កង ផលលើសនាំឆ្លងទៅបរទេស ។

គំនិតសំខាន់របស់កំណាព្យខាងលើនេះគឺ"មាតុភូមិយើងសម្បូរសម្បត្តិធម្មជាតិ" ។




## លំហាត់

ចូរអ្នកអានចម្រៀងខាងក្រោម រួចប្រាប់គំនិតសំខាន់នៃចម្រៀង ។

(អើយ) ស្រណោះទឹកដី មានព្រៃព្រឹក្សា
ស្រណោះៗមច្ឆា ហែបហែលក្នុងទឹក ។
(អើយ) ស្រណោះសត្វយំ ឱ្យខ្ញុំរែងនឹក
ចង់ឃើញៗល្ងាចព្រឹក ប្រទេសកំណើត ។



www.elibraryofcambodia.org

៦ ចម្រៀង "ត្រូវការពារសត្វព្រៃ"

ក្រោយពីស្ដាប់បទចម្រៀង ចូរឆ្លើយនឹងសំណួរខាងក្រោម ។



១. តើចម្រៀងនេះអប់រំអ្នកណា ? ឱ្យធ្វើអ្វី ?

២. តើសត្វព្រៃមានប្រយោជន៍អ្វីខ្លះ ?

## លំហាត់

ក. ចូរច្រៀងចម្រៀងឡើងវិញ រួចរកពាក្យចួននិងពាក្យ ៖

| ស្វាយ | ប្រយ័ត្ន | ដូនតា | ក្ដាន់ | បក្សា |
|---|---|---|---|---|

ខ. តើចម្រៀងនេះនិយាយអំពីអ្វី ? ចូររកគំនិតសំខាន់នៃចម្រៀង ដោយជ្រើសរើសចម្លើយមួយសមស្រប ។

☐ ១. កូនខ្មែរមិនស្គាល់សត្វព្រៃ ។

☐ ២. កូនខ្មែរត្រូវជួយការពារសត្វព្រៃ ។

☐ ៣. កូនខ្មែរកុំបំភ្លេចដូនតា ។



www.elibraryofcambodia.org

## សញ្ញាលេខទោ " ៗ "

ចូរអានឧទាហរណ៍ខាងក្រោម ។ តើសញ្ញាលេខទោសម្រាប់ប្រើដូចម្តេច ?

១. អ្នកភូមិខ្ញុំចិញ្ចឹមសត្វផ្សេងៗ តាមការចូលចិត្តរបស់ពួកគាត់ ។

២. គ្រួសារនីមួយៗធ្វើរបងព័ទ្ធជុំវិញផ្ទះ ដើម្បីកុំឱ្យសត្វចូលស៊ីដំណាំ ។

៣. ពេលទៅដើរលេងម្តងៗ ប្អូនខ្ញុំទិញតុក្កតារូបសត្វខ្លាជានិច្ច ។

៤. ក្នុងមួយថ្ងៃៗ ម្តាយខ្ញុំដាក់ចំណីឱ្យមាន់ទាស៊ីមួយដង ឬពីរដង ។

ឧទាហរណ៍ខាងលើបញ្ជាក់ឱ្យឃើញថា សញ្ញាលេខទោ " ៗ " សម្រាប់សរសេរខាងស្តាំពាក្យដែលត្រូវថាផ្ទួនពីរដង ឱ្យថាដដែលៗដូចជាពាក្យ ផ្សេងៗ នីមួយៗ ម្តងៗ មួយថ្ងៃៗ ។

> សញ្ញាលេខទោ " ៗ " សម្រាប់ផ្ទួនពាក្យមួយម៉ាត់ ឬច្រើនម៉ាត់ឱ្យថាពីរដងដដែលៗ ។

**កត់សម្គាល់ ៖** លេខទោប្រើបានចំពោះតែពាក្យខ្មែរសុទ្ធ ។

ពាក្យ " នានា " ជាពាក្យបាលី មិនត្រូវប្រើសញ្ញាលេខទោ " ៗ " ទេ ។

ឧទាហរណ៍ ៖ ប្រទេសនានា ខេត្តនានា ។

## លំហាត់

**ក. ចូរជ្រើសរើសពាក្យក្នុងប្រអប់ ដើម្បីបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។**

| រឿយៗ | គ្រប់ៗ | ដដែលៗ | ថ្មមៗ | ប្លែកៗ |
|---|---|---|---|---|

១. ជីតាខ្ញុំ បានដាស់តឿនខ្ញុំជា ... ថា កុំឱ្យរត់លេងក្បែរសត្វគោ ក្របី ។

២. ឥឡូវនេះ ក្នុងសួនសត្វភ្នំតាម៉ៅ មានចិញ្ចឹមសត្វ ... ជាច្រើន ។

៣. ឪពុកខ្ញុំ អង្អែលក្បាលអាពាលឆ្កែខ្ញុំយ៉ាង ... ។

៤. យើងត្រូវចូលរួមការពារសត្វព្រៃ ឱ្យបាន ... គ្នា ។

៥. សៀវភៅរូបសត្វនេះ មានរូបភាព ... ។

**ខ. ចូរតែងល្បះដោយប្រើពាក្យ ដែលមានសញ្ញាលេខទោឱ្យបានពីរល្បះ ។**



www.elibraryofcambodia.org

# ជីវិតសត្វព្រៃ

ចូរអានអត្ថបទ រួចឆ្លើយនឹងសំណួរ ។



មុនឆ្នាំ១៩៧០ ប្រទេសកម្ពុជាយើងសម្បូរទៅដោយព្រៃឈើ និងសត្វព្រៃច្រើនអនេក ។ សត្វទាំងនោះមានដូចជា ខ្លា ដំរី រមាស រមាំង ទន្សោង គោព្រៃ ខ្ទីង ប្រើស ក្តាន់ ឈ្លូស ត្រដក់ កុក ក្រសារ ក្អែក ទីទុយ មៀម ... ។

បច្ចុប្បន្ននេះ សត្វទាំងនោះបានបាត់បង់មួយចំនួនធំ ហើយសត្វខ្លះទៀតឈានទៅដល់ការផុតពូជដូចជា រមាស គោព្រៃ ខ្លាដំបង ក្ងោក ... ។ មូលហេតុដែលធ្វើឱ្យសត្វព្រៃទាំងនោះចេះតែហិនហោចទៅៗ គឺសង្គ្រាម ។ សង្គ្រាម បានធ្វើឱ្យសត្វព្រៃស្លាប់ជាច្រើន ហើយខ្លះទៀតបានរត់ទៅជ្រកពួននៅប្រទេសជិតខាង ។ ការកាប់ទន្ទ្រានព្រៃឈើ ដើម្បីយកដីធ្វើអាជីវកម្ម ក៏ជាមូលហេតុដែលនាំឱ្យសត្វព្រៃវិនាសគ្មានសល់ដែរ ។

ដូច្នេះ ដើម្បីការពារសត្វព្រៃ ឱ្យគង់វង្សបានយូរអង្វែង យើងទាំងអស់គ្នា គប្បីចូលរួមដាំដើមឈើឱ្យបានច្រើន តាមសហគមន៍រៀងខ្លួន និងមិនត្រូវកាប់ព្រៃឈើ ឬបរបាញ់សត្វខុសច្បាប់ឡើយ ។



www.elibraryofcambodia.org

## សំណួរ

១. ចូររាប់ឈ្មោះសត្វព្រៃនៅប្រទេសកម្ពុជាដែលប្អូនធ្លាប់ស្គាល់ ។

២. ហេតុអ្វីបានជាសត្វទាំងនោះ រងនូវការវិនាសបាត់បង់ ?

៣. ដើម្បីការពារសត្វព្រៃ តើអ្នកត្រូវធ្វើដូចម្តេចខ្លះ ?

៤. តើព្រៃឈើ និងសត្វព្រៃផ្តល់ប្រយោជន៍អ្វីខ្លះដល់ប្រទេសជាតិ ?

## លំហាត់

ចូរបង្ហាញទំនាក់ទំនងហេតុ និងផល ក្នុងល្បះខាងក្រោម ។ តើឃ្លាណាជាហេតុ ឃ្លាណាជាផល ?

១. ប្រទេសកម្ពុជាសម្បូរសត្វព្រៃ ព្រោះមានព្រៃឈើច្រើន ។

២. សត្វព្រៃខ្លះឈានដល់ការផុតពូជ ដោយសារគ្មានការអភិរក្ស ។

៣. សត្វព្រៃនៅគង់វង្សបាន ព្រោះយើងចូលរួមការពារវា ។

## សំណេរ

ក. **ចូរសរសេរល្បះខាងក្រោមនេះឡើងវិញឱ្យបានត្រឹមត្រូវ ។**

១. ក្នុងមួយឆ្នាំមួយឆ្នាំ សត្វបានបាត់បង់ទៅបាត់បង់ទៅ ដោយសារមនុស្ស ។

២. សត្វ វត្ថុផ្សេងផ្សេងដែលដាក់តាំងនេះ គេយកមកពីខេត្តនានាក្នុងប្រទេស ។

៣. សំនិងប្អូនប្អូនវា ចេះជួយដាក់ចំណីឱ្យមាន់ទាស៊ី ជំនួសឪពុកម្តាយវា ។

៤. ប្រជាជនភូមិខ្ញុំ តែងតែភ្ញាក់ពីព្រលឹម ហើយទៅប្រកបមុខរបររៀងរៀងខ្លួន ។

ខ. **ចូរប្រើសញ្ញាលេខទោ "ៗ" ក្នុងល្បះខាងក្រោម ដើម្បីឱ្យមានន័យត្រឹមត្រូវ ។**

១. នៅស្រុកស្រែ តាមផ្ទះនីមួយគេច្រើនចិញ្ចឹមគោក្របី ។

២. ព្រឹកព្រលឹមស្រាង ឪពុកខ្ញុំដឹកគោក្របីទៅភ្ជួរស្រែ ។

៣. ក្នុងមួយថ្ងៃ ខ្ញុំឃើញគេដឹកសត្វ និងទិញទំនិញផ្សេង ។

គ. **ចូរតែងល្បះទាក់ទងនឹងសត្វឱ្យបានបីល្បះដោយប្រើសញ្ញាលេខទោ ។**



www.elibraryofcambodia.org

# រឿង កញ្ជ្រោងនិងមាន់ថៃ

ចូរអានអត្ថបទ រួចឆ្លើយនឹងសំណួរ ។



មានកញ្ជ្រោងមួយ ដើរទៅឃើញមាន់ថៃទំលើប្រគាបឈើ ។ វាចង់ស៊ីមាន់ថៃ ទើបនិយាយជាឧបាយកលទៅកាន់មាន់ថៃថា ៖

- នែមាន់ថៃសម្លាញ់អើយ! ព្រះឥន្ទ្រទ្រង់ត្រាស់ប្រើខ្ញុំឱ្យកាន់អាជ្ញាមកប្រកាសប្រាប់បណ្ដាមិត្ត ដែលធ្លាប់ចងពៀរសត្រូវនឹងគ្នា ឱ្យរាប់អានគ្នាពីថ្ងៃនេះទៅ ។ ដូច្នេះ យើងជាសម្លាញ់នឹងគ្នា ចាប់ពីពេលនេះទៅ ចូរអ្នកចុះមកឱ្យខ្ញុំថើបបន្តិចមកអេះ ។ ឯមាន់ថៃមានប្រាជ្ញាវាងវៃក៏តបភ្លាម ៖
- អើបងកញ្ជ្រោងអើយ! ខ្ញុំចង់ទៅទទួលសេចក្ដីស្និទ្ធស្នាលនឹងបងដែរ ។ តែខ្ញុំមកជាមួយបងឆ្កែ គាត់ទៅរកស៊ីទីព្រៃបាត់ពុំទាន់មកដល់ ។ យើងចាំ ជួបជុំគ្នាទាំងបីប្រាណនឹងបានក្រសោបឱបគ្នា តាមក្ដីស្និទ្ធស្នាលតែម្ដង ។
- មាន់ថៃនិយាយចប់ហើយ ធ្វើបែរសម្លឹងរកមើលឆ្កែ ហើយស្រែកថា ៖



www.elibraryofcambodia.org

- អើយបងសុនខអញ្ជើញមកហើយ! ឆាប់ចូលមក! បងកញ្ជ្រោងគាត់មករង់ចាំបង ។ ឯកញ្ជ្រោងឮថា ឆ្កែមកក៏ភិតភ័យ ព្រោះខ្លួនខ្លាចឆ្កែខាំស៊ី ទើបមិ៑ម្នារត់ចេញពីទីនោះចូលព្រៃទៅ ។ មាន់ថៃរឹតតែបង្ខោ ៖
- បងកញ្ជ្រោងកុំអាលទៅណា បងសុនខមកដល់ហើយ! ឯកញ្ជ្រោងក៏ឆ្លើយ ៖
- អាផ្លាក្តៅណាស់នៅមិនបានទេ! ថាហើយកញ្ជ្រោងរត់ចូលព្រៃទៅ ។ មាន់ថៃក៏ស្រែកឡកឱ្យកញ្ជ្រោង ៖
- ចោលម្សៀត! ចេះមកពោលពាក្យថាកាន់ព្រះរាជអាជ្ញា មកប្រកាសឱ្យសត្វជាសត្រូវនឹងគ្នាជានានឹងគ្នាតែឯងនិងអញ ចុះបងឆ្កែនិងឯងត្រឡប់ជាមិនសាមគ្គីវិញ ។ នរណាជឿបានពាក្យមិនទូទៅយ៉ាងនេះ ។

(ដកស្រង់ពីកម្រងរឿងនិទានថ្នាក់ទី ២ បោះពុម្ព ឆ្នាំ១៩៨៦)

## សំណួរ

១. ក្នុងរឿងនេះ តើមានតួអង្គអ្វីខ្លះ ?

២. តើកញ្ជ្រោង ឃើញមាន់ថៃនៅឯណា ?

៣. តើកញ្ជ្រោង និយាយដូចម្តេចខ្លះទៅកាន់មាន់ថៃ ?

៤. តើមាន់ថៃជឿតាមការប្រកាសរបស់កញ្ជ្រោងដែរ ឬទេ ? ព្រោះអ្វី ?

៥. ហេតុអ្វីបានជា កញ្ជ្រោងរត់ចូលព្រៃបាត់ទៅ ?

៦. តើរឿងនេះ កើតនៅពេលណា ? នៅកន្លែងណា ?

## លំហាត់

ក្រោយពីអានរឿងនេះចប់ ចូរអ្នកបង្ហាញចម្លើយមួយដែលសមស្រប ជាតម្លៃអប់រំរបស់រឿងនិទាននេះ ។

- ☐ ១. ត្រូវចេះប្រើឧបាយកល ដើម្បីបោកប្រាស់អ្នកទន់ខ្សោយជាង ។
- ☐ ២. ត្រូវប្រមូលកម្លាំង ដើម្បីកម្ចាត់សត្រូវដែលខ្លាំងជាង ។
- ☐ ៣. ត្រូវប្រើប្រាជ្ញាទប់ទល់ ចំពោះឧបាយកលសត្រូវដែលខ្លាំងជាង ។



www.elibraryofcambodia.org

## ពណ៌នាអំពីសត្វឆ្កែ

ចូរអានអត្ថបទពណ៌នាខាងក្រោម រួចឆ្លើយនឹងសំណួរ ។



គ្រួសារខ្ញុំជាកសិករ ។ក្រៅពីចិញ្ចឹមគោក្របី មាន់ ទា គ្រួសារខ្ញុំបានចិញ្ចឹមឆ្កែឈ្មោលមួយក្បាល ដោយឱ្យឈ្មោះថា អាព្រីង ។

អាព្រីងមានសម្បុរខ្មៅរលើប រោមខ្លីក្រាស់តែទន់ ។ មុខវាស្រួច ធ្មេញ និងចង្កូមមុតអណ្ដាតពាំព្រីង ត្រចៀកកញ្ជ្រឹប ដងខ្លួនធំមាំជើងវែង កន្ទុយវាត់ឡើងលើ ។

អាព្រីងកាចបន្តិច តែឆ្លាតណាស់ ។ ពេលខ្ញុំមកពីសាលារៀន ឬឪពុកម្ដាយខ្ញុំមកពីធ្វើស្រែចម្ការ វាតែងតែរត់ទៅកន្ត្រាង លិទ្ធដៃជើងទទួលរាក់ទាក់ ហាក់ដូចជានឹករឭកពួកយើងខ្លាំងណាស់ ។ ពេលណាគ្រួសារខ្ញុំមិននៅផ្ទះ ក៏មានការកក់ក្ដៅ ព្រោះមានវានៅចាំផ្ទះ ។ ក្រៅពីនេះ អាព្រីងក៏បានជួយគ្រួសារខ្ញុំក្នុងការឃ្វាលគោក្របីដែរ ។

ដោយសារតែអាព្រីងឆ្លាត និងចេះបែបនេះហើយ ទើបធ្វើឱ្យគ្រួសារខ្ញុំស្រឡាញ់ និងថែទាំអាព្រីងបានល្អជារៀងរហូតមក ។

### សំណួរ

១. តើក្នុងអត្ថបទនេះ គេរៀបរាប់អំពីសត្វអ្វី ?

២. តើឆ្កែនោះមានរូបរាងដូចម្ដេច ?

៣. តើឆ្កែនោះបានជួយការងារម្ចាស់វាអ្វីខ្លះ ?

៤. ហេតុអ្វីបានជាគ្រួសារនោះស្រឡាញ់ និងថែទាំឆ្កែនោះ ?



www.elibraryofcambodia.org

## លំហាត់

ចូរប្អូនពណ៌នាអំពីសត្វណាមួយ ដែលគ្រួសារប្អូនបានចិញ្ចឹម ។
ដើម្បីជាជំនួយក្នុងការពណ៌នា ចូរប្អូនមើលគម្រោងខាងក្រោមនេះ ។

១. ឈ្មោះសត្វដែលប្អូនបានចិញ្ចឹម

២. លក្ខណៈរូបរាង ៖ សម្បុរ ក្បាល ត្រចៀក ដងខ្លួន ជើង...

៣. ចរិត ៖ កាច ស្លូត ឆ្លាត ល្ងង់ ខ្ជិល ឧស្សាហ៍...

៤. ផលប្រយោជន៍

៥. ការថែទាំ ៖ ធ្វើជម្រក ផ្តល់ចំណី...

៦. ចំណាប់អារម្មណ៍... ។

## សំណេរ

ក. ចូរបំពេញឃ្លានៃកំណាព្យបទកាកគតិខាងក្រោម តាមរូបភាពឱ្យបានសមស្រប ។





www.elibraryofcambodia.org

នាមជាគជសារ ទោះទៅទីណា មានជនប្រុស ...
ក្មេងចាស់ក្រមុំ ហៅខ្ញុំ ... មានខ្លាប្អូនបី
ប្រៀបមិនបានទេ ។

ខ្ញុំមានភ្នែក ... មិនអាចប្រដូច នឹងក្បាលធំទេ
ត្រចៀកកំប៉ាង សងខាងទាំងទ្វេ ធំអ្វីម្ល៉េះ ...
ស្បែកជ្រួញហើយក្រាស់ ។

ជើងធំទាំង ... ស្នក់តែម៉ាំមួន ថ្វីបើខ្ញុំ ...
តែមានភ្លុក ... សែនល្អពេកណាស់ ប្រមោយរហ័ស
ឈោងចាប់អាហារ ។

ខ. **ចូរតែងកំណាព្យបទកាកគតិ១វគ្គ រៀបរាប់ពីផលប្រយោជន៍នៃសត្វស្រុក ។**

គ. **ចូរសរសេរអត្ថបទខ្លីមួយ ពណ៌នាអំពីសត្វអ្វីមួយដែលអ្នកបានចិញ្ចឹម ។**

## គម្រោងតែង

១. ផ្ដើមសេចក្ដី

- ពេលវេលាដែលអ្នកបានចិញ្ចឹម
- ឈ្មោះសត្វចិញ្ចឹម ញី ឬឈ្មោល ។

២. តួសេចក្ដី

- សណ្ឋានរាងរៅ ៖ មាឌ (កម្ពស់ ទំហំ) សម្បុរ ក្បាល ដងខ្លួន ជើង កន្ទុយ ស្លាប រោម ...
- លក្ខណៈសម្បត្តិ ៖ កាច ស្លូត ល្មោភស៊ី ការអត់ធន់ ខ្ជិល ឧស្សាហ៍ ឆ្លាត...
- ការថែទាំ ៖ ឱ្យចំណី ធ្វើទ្រុង...
- ផលប្រយោជន៍... ។

៣. បញ្ចប់សេចក្ដី

មនោសញ្ចេតនារបស់អ្នកចំពោះសត្វនោះ ។



www.elibraryofcambodia.org

# បទានុក្រម

## ក

កញ្ជ្រឹប (កញ់ ច្រឹប) គុ. ដែលបះឡើងខ្ទឹមទៅលើ ។
កន្ត្រាង (កន់ ត្រាង) កិ. លោតខាំ លោតចាប់ ។
ការ កិ. មូរសរសៃសូត្រ សរសៃអំបោះជាដើមដោយខ្នារ : ការសូត្រ ។
ការណ៍ (កា) ន. ហេតុ ដំណើរ រាយការណ៍ ។
ការអភិរក្ស (កា អៈ - ភិ - រាក់) ន. ការរក្សាដោយប្រយ័ត្ន ។
ការអភិវឌ្ឍ (- អៈ- ភិ- វ៉ត) ន. ការលូតលាស់ចម្រើន ការចម្រើនក្រៃលែង ។
កិច្ចកល (កិច- កល់) ន. ពុតត្បុត ល្បិច ឧបាយកលយ៉ាងល្អិត ។
កេរដំណែល (កេ- ) ន. អ្វីៗជារបស់រក្សាទុកមកពីដូនតា បុព្វបុរស : ស្រែនេះ ជាកេរដំណែលរបស់ជីតាខ្ញុំ ប្រាសាទអង្គរវត្ត ជាកេរដំណែលរបស់ព្រះមហាក្សត្រខ្មែរ ។
ក្លើ ន. មិត្តជិតស្និទ្ធ រួមសុខទុក្ខជាមួយគ្នា កាលណាធ្វើក្លើគេអាចហៅគ្នា អាមឹងបាន ។
ក្លែង កិ ធ្វើឱ្យប្លែកចាករូបរាងដើមទៅជារូបរាងថ្មី ដើម្បីកុំឱ្យគេស្គាល់ ។
ក្ស័យ (ក្សៃ) ន. សេចក្ដីបាត់បង់ សេចក្ដីវិនាស ការអស់ទៅ: ក្ស័យជីវិត ក្ស័យធន ។
ក្សេមក្សាន្ត (ក្សេម - ក្សាន)គុ. ដែលមានសេចក្ដីសុខ ។

## ខ

ខ្ទាល់ កិ. ទិង : ស្ដេចខ្ទាល់ លោកសង្ឃខ្ទាល់ ។

## គ

គង់វង្ស (- វង់) កិ. ឬគុ. គង់ពូជវង្សនៅមិនសូន្យ គង់ដំណែល ឬប្រពៃណីនៅដូចដើម : យើងត្រូវរក្សា ប្រពៃណីឱ្យនៅគង់វង្ស ។
គជសារ (គជ់ ជៈ សា) ន. ដំរីមាឌធំសម្បើម ។
គុណ (គុន) ន. សេចក្ដីចម្រើនសេចក្ដីល្អ ។
គុណវិបត្តិ (គុន -វិ- បាត់)ន. ការប្រាសចាកគុណ ការខ្វះសេចក្ដីល្អ ការគ្មានផលប្រយោជន៍ ។
គុណសម្បត្តិ (គុន - ស័ម - ប័ត) ន. ការបរិបូណ៌ដោយសេចក្ដីល្អ : មនុស្សមានគុណសម្បត្តិគួរឱ្យសរសើរ ។
គំនាប ន. ប្រដាប់សម្រាប់គាប ឃ្នាប ។
ឃាតកៈ (ឃាតៈ កៈ) ន. អ្នកសម្លាប់ អ្នកធ្វើឃាត ។

## ច

ចរចា (ច - ចា) កិ. និយាយប្រស្រ័យ សំណេះសំណាលរកគ្នា : កំពុងចរចាគ្នា ។
ចរិត (ចៈ -រិត) ន. ការប្រព្រឹត្តិ កិរិយា មារយាទ ឫកពា បែបបទ : ចរិតល្អ ។
ចរិយាសម្បត្តិ (ចៈរិយ៉ា - សំ - ប័ត) ន. ការបរិបូណ៌ទៅដោយព្រេង សំណាង កិរិយាមារយាទ ។



www.elibraryofcambodia.org

ចល័ត (ចៈ- ល៉ាត់) គុ. ដែលមិនឋិតនៅនឹងតែមួយកន្លែង ។

ចិន្តា (ចិន - ដា) ន. សេចក្តីគិត (គំនិត) ។

ច្រឡាស កិ. ច្រឡោតទៅខាង ។

## ឆ

ឆី កិ. ស៊ី : ខ្ពុំជាឱ្យបាយឆី ដេកនៅដីចាំធនធាន ។

## ជ

ជូ គុ. ដែលអាក្រក់ ដែលឆ្គងមិនស្ទួវស្គាល់ក្តីគួរសម មនុស្សជូ អាក្រក់ជូជាតិ ។

ជម្រក ន. ទីកន្លែងសម្រាប់ជ្រក ទីជ្រក ។

## ញ

ញាតិ (ញាត) ន. អ្នកដែលរួមខ្សែលោហិតនឹងគ្នាខាងឪពុកនិងម្តាយ ហៅថាញាតិ៧សន្តាន ឬញាតិ៧ជួរ ។

## ដ

ដំបូន្មាន (ដំ-បូន -មាន) ន. ពាក្យប្រដៅ ការទូន្មាន ឱវាទ: ឱ្យដំបូន្មាន ។

## ត

តុល្យភាព (តុល - យ្យៈ - ភាប) ន. ការថ្លឹងឱ្យមានទម្ងន់ស្មើគ្នា ការស្មើភាពគ្នា ។

តូរ្យតន្ត្រី (ដូ =ដន់ - ត្រី) ន. គ្រឿងភ្លេង ដេញ ដំ ផ្លុំ កូត ។

តួយ៉ាង ន. គំរូ ឧទាហរណ៍ : យកជាតួយ៉ាងពុំកើត ។

ត្រិះរិះ ន. ការគិត ពិចារណា ។

## ថ

ថវិកា (ថៈ-វិ- កា)ន. ប្រាក់ លុយ : ថវិកាជាតិ ។

ថ្លៃថ្នូរ គុ. មានតម្លៃគួរលើកសរសើរ គួររាប់អាន : មនុស្សនេះ ឫកថ្លៃថ្នូរណាស់ ។

## ទ

ទន្ទ្រាន (ទន់-ទ្រាន) កិ. រុករានលើ ។

ទ័ល គុ. ដែលក្រីក្រទ្រព្យ ។

ទស្សនា (ទ័ស - សៈ - នំា) កិ. មើល មើលឃើញ : គេទស្សនាទូរស្សន៍ ។

ទិដ្ឋភាព (ទិត - ថៈ - ភាប) ន. ភាពនៃអ្វីៗដែលគេបានឃើញ បានជួបប្រទះ ។

ទិសា ន. ភាគចំណែកមុខ ក្រោយ ឆ្វេង ស្តាំព្រមទាំងជ្រុងជាចន្លោះទាំង៤ និងខាងលើ ខាងក្រោម ។

ទុក្ខ(ទុក) ន. សេចក្តីព្រួយ សេចក្តីលំបាក: កើតទុក្ខ មានទុក្ខ ។

ទូល កិ. ប្រាប់ ឱ្យដំណឹង : ទូលស្តេច ទូលព្រះសង្ឃ ។



www.elibraryofcambodia.org

ទេសចរណ៍ (ទេស - ច) ន. ការធ្វើដំណើរកម្សាន្តលម្ហែចិត្ត ។

ធ

ធនាគារ(ធៈ - នា - គា) ន. ឃ្លាំងដាក់ប្រាក់ ដាក់ទ្រព្យ កន្លែងផ្ញើប្រាក់ ។

ធម្មជាតិ (ធ័មមៈ - ជាតិ) ន. ធម៌ សភាវៈ សភាព ។ អ្វីៗដែលកើតឡើងឯកឯង ដូចជាទឹក ដី ព្រៃ ព្រឹក្សា សមុទ្រ ភ្នំ ... ។

ធុរៈ ន. ការរវល់ ដំណើរជំពាក់ដោយកិច្ចការ : ខ្ញុំទៅមិនបានដោយមានធុរៈ ។

ន

នគរ ន. បុរី ក្រុង ប្រទេស ។

និយម (និ - យំ)កិ. កំណត់ អនុលោមតាម : ប្រជាជនយើងនិយមលេងល្បែងប្រជាប្រិយនៅពេលចូលឆ្នាំ ។

ប

បក្សាបក្សី (ប័ក - សា - ប័ក - សី) ន. សត្វស្លាបឈ្មោល សត្វស្លាបញី ។

បច្ចុប្បន្ន (ប៉ុច - ចុ - បន់) ន. ពេលឥឡូវ ចំពោះមុខ ។

បទ(បត់) ន. ផ្លូវ ដំណើរ ទំនង លំនាំ នៃសំឡេងដែលសូត្រ ច្រៀង : បទចម្រៀង ។

បទពិសោធ (បត់-) ន. ដំណើរដែលបានធ្វើរួចហើយ កិច្ចការដែលធ្លាប់បានធ្វើ ។

បច្ចេកទេស (ប៉ុច - ចេកៈ - ទេស) ន. ចំណេះ ជំនាញផ្សេងៗ : បច្ចេកទេសខាងអគ្គិសនី បច្ចេកទេសខាងកសិកម្ម ។

បដិសេធ (ប៉ះ - ឌិ - សែត) ន. ការឃាត់ ការហាម ដំណើរលើកចោល លែងយកជាការ ។

បណ្ណាល័យ (ប៉ុន - ណា - ល៉ៃ)ន. ផ្ទះ កន្លែងសម្រាប់តម្កល់សៀវភៅ គម្ពីរ ក្បួនច្បាប់ផ្សេងៗ ។

បរិមាណ (បៈ - រិ - ម៉ាន) ន. ចំនួន ។

បរិសុទ្ធ (ប - រិ - សុត ) គុ. ស្អោះសអាតសៅហ្មង ។

បារម្ភ (បា - រុំ) ន. ដំណើរនឹកថប់ ឬនឹកព្រួយជាមុន ។

បុរាណ (បុ រ៉ាន) គុ. ដែលកើតមានមុន ដែលមានយូរហើយ ។

បំណាំ ន. ដំណើរបណ្តែតបណ្តោយ មិនស្តីថា មិនរំឭកដាស់តឿន ឬមិនជួយខ្នះខ្នែង មិនជួយធ្វើចាំតែមើលពុត មើលមារយាទ : មើលបំណាំគ្នា ។

បញ្ហា ន. ប្រស្នា ចំណោទ ។

ប្រជាប្រិយ (- ប្រី) គុ. ដែលជាទីពេញនិយមរបស់ប្រជាជន ដែលជាទីស្រឡាញ់របស់ប្រជាជន ។

ប្រជាពលរដ្ឋ (- ពល់ - រ័ត) ន. ពលរដ្ឋគឺប្រជាជន ឬប្រជាជនដែលជាពលរដ្ឋ ។

ប្រព្រឹត្ត (ប្រ - ព្រឹត)កិ. ធ្វើតាម ។

ប្រសប់ គុ. ប៉ិន ថ្នឹក ។

ប្រសាសន៍ (- សាស) ន. សម្តី បណ្តាំ ពាក្យបង្គាប់ ពាក្យផ្តាំផ្ញើ ។



www.elibraryofcambodia.org

ប្រហារ ន.កិ. វាយ កាប់ ចាក់ សម្លាប់ : ប្រហារជីវិត ប្រហារដោយដំបង ។
ប្រាជ្ញា (ប្រាច - ញ៉ា) ន. បញ្ញា សេចក្ដីដឹងទូទៅ សេចក្ដីដឹងកើតអំពីការរៀន ការដឹងច្បាស់នូវសេចក្ដីពិត ។
បារាយណ៍ទឹកថ្លា ន. ឈ្មោះបឹងធំមួយរាលត្លៃស្រឡះស្អាតផង ឥតមានស្មៅ ឬចកគ្រឹបអ្វីឡើយ មានទឹកថ្លាល្អេងជានិច្ច ។

## ផ

ផ្គត់ផ្គង់ កិ. ទំនុកបម្រុងមិនឱ្យខ្វះខាត រៀបបម្រុងទុក ៖ ផ្គត់ផ្គង់ស្បៀងសម្រាប់កងទ័ព ។
ផលិត(ផៈ - លិត) ន. ការបង្កើត ។

## ព

ព័ត៌មាន (ព័រ - ត៍ - មាន) ន. ដំណឹងផ្សេងៗក្នុងបច្ចុប្បន្ន ព្រឹត្តិការណ៍ ។
ពណ៌នា (ព័រ - ណៈ - នា) ន. ពាក្យពោលរៀបរាប់ ពាក្យអធិប្បាយសេចក្ដី ។
ព័ទ្ធ (ព័ត) កិ. ចងចោមជុំវិញ ចោមស្ទាក់ជុំវិញមិនឱ្យមានផ្លូវចេញរួច : ព័ទ្ធចោរ វល្លិព័ទ្ធដើមឈើ ។
ពន្លឹក (ពន់ - លឹក) គុ. ដែលគួរភ្ញាក់ , គួរស្បើម : ភ័យពន្លឹក ។
ពេចន៍ (ពេច) ន. ពាក្យ , សម្ដី : ពាក្យពេចន៍ ។
ពំនាក់ ន. ទីពឹងពាក់ ទីជ្រកអាស្រ័យ មានចៅហ្វាយនាយជាពំនាក់ ។
ព្រ័ត្រ (ព្រាត់) ន. ពួរ ឬខ្សែត្រកួញធ្វើដោយស្បែកគោ ស្បែកក្របី ។
ព្រឹត្តិការណ៍ (ព្រឹត - តិ - កា) ន. ហេតុ ឬដំណឹងដែលតែងកើតមានជាធម្មតា : ថ្ងៃនេះមានព្រឹត្តិការណ៍ប្លែកៗ ។

## ភ

ភារ: ន. ភាព ។
ភុជង្គ (-ជង់) ន. ពស់ នាគ ។
ភុជង្គលីលា (-ជង់-) ន. ឈ្មោះកាព្យមួយប្រភេទ : បទភុជង្គលីលា ។
ភោជនីយដ្ឋាន (ភោ - ជៈ - នី - យ៉ត ឋាន) ន. កន្លែងសម្រាប់បរិភោគអាហារ ។

## ម

មណ្ឌលសុខភាព(មន់-ឌល់- សុខៈ-ភាព)ន.កន្លែងពិនិត្យ ព្យាបាលជំងឺផ្សេងៗនៅតាម ឃុំ ឬសង្កាត់នីមួយៗ ។
មរណា(មៈ-រៈ-ណា) ន. សេចក្ដីស្លាប់ ក្ស័យ ។
មរតកឬមត៌ក(មៈ-រៈ-ដក់)ន.បុគ្គលដែលស្លាប់ហើយ: ទ្រព្យមរតក គឺទ្រព្យរបស់បុគ្គលដែលស្លាប់ហើយ
មហន្តរាយ (មៈ-ហន់ តៈ រ៉ាយ) គុ. អន្តរាយធំ: មានមហន្តរាយដោយភ្លើងឆេះផ្ទះ ។
មហិទ្ធិឫទ្ធិ (មៈ -ហិត - ធិរិត) ន. អំណាចធំ ឫទ្ធិខ្លាំងក្រៃលែង ។
មាឌ(មាត) ន. ទំហំ ។
មាតុភូមិ(មាតុ -ភូមិ) ន. ស្រុកកំណើត ប្រទេសកំណើត ។



www.elibraryofcambodia.org

មានះ កិ. ចចេសរឹងត្អឹង ។

មាយា ន. កល កិច្ចកល ល្បិច ពុត ពុតត្បុត ដំណើរលាក់ពុត ៖ មនុស្សមានមាយា មាយាស្ត្រី ។

មារយាទ(មា-យាត) ន. របៀប សណ្តាប់ធ្នាប់ ឫកពា៖ មារយាទថោក មារយាទថ្លៃ ឥតមារយាទ ។

មូលហេតុ (មូ លះ ហែត) ន. ហេតុដើម ដំណើរដើម ។

ម្រឹគ (ម្រឹក) ន. សត្វចតុប្បាទព្រៃទូទៅមាន ខ្លា ឈ្លូស គោជាដើម ។

ម្រឹគីម្រឹគា (ម្រឹក - គី - ម្រឹក - គា) ន. សត្វចតុប្បាទព្រៃញី ឈ្មោល ។

## យ

យុវជន (យុ - វៈ - ជន់) ន. ជនកម្លោះ ក្រមុំ ។

## រ

រក្សា (រ័ក - សា) កិ. ថែទាំ បីបាច់ ចិញ្ចឹម ។

រហ៊ុម គុ. ដែលមានក្លិនស្អុយ រងំ ដែលអាក្រក់ ឬស្អុយកេរ្តិ៍ឈ្មោះសាយពេញពាស ។

រាបសា គុ. ដែលមិនប្លែកពីគេ យ៉ាងកណ្តាល សាមញ្ញ ៖ មនុស្សរាបសា ។

រិទ្ធិ ឬឫទ្ធិ (រិត) ន. អំណាច សេចក្តីអស្ចារ្យ សម្បើម ។

ឫកពា ន. មារយាទ កិរិយា បែបបទ សណ្តាប់ធ្នាប់ ៖ ឫកពាល្អ ។

ឫស្យា (រឹស - ស្យា) ន. សេចក្តីច្រណែន សេចក្តីឈ្នានីស ។

រុក្ខជាតិ (រុក - ខៈ - ជាតិ) ន. ដើមឈើ ។

រុក្ខា (រុក ខា) ន. ដើមឈើ ។

រូបសម្បត្តិ (រូប - សំ - ប័ត) ន. ដំណើរមានរូបសមរម្យ មានរូបល្អ ។

## ល

លា ន. សត្វពាហនៈមួយប្រភេទ មានរូបរាងប្រហែលនឹងសេះ ។

លោភលន់ (លោប - ) ន. ការចង់មាន ចង់បានហួសហេតុ ។

## វ

វាងវៃ គុ. ប៉ិន ឈ្លាស ស្ទាត់ រហ័ស ជំនាញ ប្រាកដ ។

វាយនភ័ណ្ឌ (វាយៈ - នៈ - ភ័ន) ន. ការផលិតគ្រឿងសម្លៀកបំពាក់ មានហូល ផាមួង [illegible] ជាដើម ។

វិជ្ជា(វិច - ជា) ន. ចំណេះ ការចេះដឹង វេទមន្ត មន្តអាគមន៍ ។

វិនាស ន. ការបាត់បង់ ការខូចខាត សេចក្តីអន្តរាយ ។

វិស្សមកាល (វិៈ - សៈ - មៈ - កាល) ន. ពេលឈប់សម្រាក ។

វិទ្យាសាស្ត្រ ន. វិជ្ជាមួយប្រភេទ ដែលគេរកឃើញដោយការពិសោធ មានការផ្សំ [illegible]

www.elibraryofcambodia.org

## ស

ស័ក្តិសិទ្ធិ (ស័ក - សិត) ន. ការសម្រេចដោយអំណាច គុ. ដែលខ្លាំងពូកែ ដែលមានអំណាច សម្រេចប្រយោជន៍បាន ។

សូន្យសង្ខារ (សូន - សង់ - ខា) កិ. ស្លាប់ ។

សង្រ្គុប (សង់ - គ្រុប)កិ. ស្ទុះទៅសង្កត់ ស្ទុះទៅគ្របជាប់ : ឆ្មាសង្រ្គុបកណ្តុរ ។

សន្តាន (សន់ - ដាន) ន. ពូជពង្ស វង្សត្រកូល ។

សន្តិភាព (សន់ - តិ - ភាប) ន. សេចក្តីសាន្តត្រាណ ។

សន្ទិក (សន់ - ធិក) ន. ស្គរលាន់ខ្លាំង ស្គរដែលលាន់រំពងគួរឱ្យស្ញើចះ សន្ទិក ខ្យល់ព្យុះ ។

សមរម្យ(សំ- រំ)គុ. កិ. ដែលត្រូវបែបបទមិនទាស់ភ្នែក ។

សាមគ្គី (សា - ម៉ុក- គី) ន. សេចក្តីព្រមព្រៀង ដំណើរស្រុះគ្នា ។

សាធារណៈ(សា- ធា- រៈ- ណៈ)គុ. ដែលទូទៅដែលប្រើបានទាំងអស់គ្នា : សាលារៀនជាសម្បត្តិសាធារណៈ ។

សុវត្ថិភាព(សុ - វ៉ុត - ថិ - ភាប) ន. ការប្រកបដោយសេចក្តីសុខ ។

សេរីភាព (សេ -រ៉ី- ភាប) ន. អំណាចដែលអាចធ្វើបានតាមអំពើចិត្ត ប៉ុន្តែក្រោមច្បាប់ អំណាចពេញទី ។

ស្ថានីយ(ស្ថា - នី) ន. ទីសម្រាប់ស្នាក់ ទីសំចត ដំណាក់សម្រាប់ឈប់សម្រាក ។

ស្និទ្ធស្នាល គុ. ជិតដិតនឹងគ្នា ស្និទ្ធឥតរង្កៀស ។

ស្មារតី (ស្មា - រដី) ន. សេចក្តីនឹកឃើញ ការចាំបាន ។

ស្ទូរ គុ. កំណាញ់ រឹតត្បិតឥតអៀនខ្មាស ។

## ហ

ហិង្សា (ហឹង - សា) ន. ការធ្វើអាក្រក់រកគ្នា : មនុស្សត្រូវកុំឱ្យមានហិង្សារកគ្នា ។

ហិន កិ. វិនាស សាបសូន្យ លិចលង់ : ហិនទ្រព្យ ។

## អ

អន្តរាយ (អន់- តៈ - រ៉ាយ) ន. ការខូចខាត ការបាត់បង់ សេចក្តីវិនាស ។

អនេក (អៈ- នែក) គុ. ច្រើនរាប់មិនអស់ ប្រមាណ ។

អពមង្គល (អៈ -ប្អូអប់ - ពៈ - មង់- គល់) ន. សេចក្តីមិនចម្រើន ការមិនសុខ ហេតុនាំឱ្យវិនាស ។

អភិសេក (អៈ - ភិ - សែក) ន. ការរៀបអាពាហ៍ពិពាហ៍ ប្រើសម្រាប់ស្តេច ។

អាកប្បកិរិយា (អា- ក័ប- បៈ កិរិយ៉ា) ន. អាការនៃរាងកាយ ដំណើរ ឬលំនាំនៃរាងកាយឬកពា ។

អាការ (អា - កា - រៈ) ន. ភិនភាគ គ្រឿងសម្គាល់ បែបបទ ឫកពា កិរិយា សភាព ។

អាជ្ញា (អាច - ញ៉ា)ន. អំណាច ការគ្រប់គ្រង ការបង្គាប់ ច្បាប់បញ្ញត្តិ ។

អាស្រ័យ កិ. ពឹងពាក់ ជ្រកកោន ។

ឥរិយាបថ (អិ-រ៉ិ- យា - បត់) ន. ផ្លូវឬគន្លងនៃឥរិយា គឺការដើរ ឈរ អង្គុយ ដេក ។



www.elibraryofcambodia.org

## យើងបម្រើសេវាកម្ម៖

- អភិវឌ្ឍសៀវភៅនិងសម្ភារឧបទេស
- បោះពុម្ព
- ចែកផ្សាយដល់សាលារៀន

## WE SERVE:

- book and teaching-aid developm
- printing
- distribution to schools




## មានលក់៖

សៀវភៅសិក្សាគោលសម្រាប់សិស្ស សម្រាប់គ្រូ
សៀវភៅហ្វឹកហាត់ សៀវភៅអំណានបន្ថែម និង
សម្ភារឧបទេស ព្រមទាំងសម្ភារការិយាល័យគ្រប់មុខ !

## SELLING:

textbooks , teacher's manuals ,
workbooks , supplementary read
teaching-aids and stationary !

www.elibraryofcambodia.org